# ចរិតលក្ខណៈ និង ភាពជាព្រះ របស់ព្រះ

# សូមស្វាគមន៍

មានការនិយាយថា “អ្វីដែលចូលមកក្នុងគំនិតយើង នៅពេលដែលយើងគិតអំពីព្រះ គឺជាអ្វីដែលសំខាន់ជាងគេអំពីយើង” ។ គោលជំនឿរបស់យើងអំពីព្រះ គឺការកំណត់ពី តំលៃគ្រឹះរបស់យើង អទិភាពរបស់យើង របៀបយើងប្រើប្រាស់ពេលវេលា សមត្ថភាពរបស់យើង ហើយសំខាន់វាកំណត់ថាយើងចំណាយជីវិតរបស់យើងទៅលើអ្វី។ ដូច្នេះវាគឺជាការសំខាន់យ៉ាងខ្លាំង ក្រៃលែងក្នុងការ ឲ្យគំនិតទស្សនៈរបស់យើងអំពីព្រះ មានលក្ខណៈត្រឹមត្រូវគៀកជាមួយនឹង សេចក្តីពិតអំពីភាពជាព្រះ របស់ទ្រង់ តាមតែអាចធ្វើបាន។ សំនួរយ៉ាង សំខាន់បំផុតដែលយើងម្នាក់ៗនឹងធ្វើការឆ្លើយគឺ : តើព្រះរបស់លោកអ្នកគឺជា នរណា?

គោលដៅរបស់វគ្គសិក្សាមួយនេះ គឺដើម្បីជួយយើងឲ្យស្គាល់ព្រះ សមស្របតាមការ ដែលទ្រង់បានសំដែងអង្គទ្រង់ឲ្យយើងស្គាល់តាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺព្រះគម្ពីរ។ យើងនឹងធ្វើការនេះតាមរយៈការ ពិនិត្យមើលទៅលើចរិតលក្ខណៈ និង ភាពជាព្រះ របស់ទ្រង់។ មានមេរៀនចំនួន ៨ មេរៀន។

១៖ ព្រះអង្គគឺជាព្រះអាទិករ (ព្រះដែលបង្កើតអ្វីៗទាំងអស់)

២៖ ព្រះអង្គគឺជាប្រភពជីវិត និង ជាអង្គបុគ្គលទ្រទ្រង់ ជីវិតទាំងអស់

៣៖ ព្រះអង្គគឺជាព្រះអស់កល្ប ហើយគ្មានការប្រែប្រួល

៤៖ ព្រះអង្គគឺជាព្រះសព្វវត្តមាន (ទ្រង់មានព្រះវត្តមានគ្រប់ទីកន្លែងក្នុង ពេលតែមួយ)

៥៖ ព្រះអង្គគឺជាព្រះសព្វញ្ញូតញ្ញាណ (ជ្រាបគ្រប់ការទាំងអស់)

៦៖ ព្រះអង្គគឺជាព្រះមានសព្វានុភាព (មានគ្រប់ទាំងអំណាចចេស្ដា)

៧៖ ព្រះអង្គទ្រង់ជាព្រះសោយរាជ្យលើគ្រប់ទាំងអស់

៨៖ ព្រះអង្គទ្រង់បរិសុទ្ធ

នៅពេលចុងបញ្ចប់នៃការសិក្សានេះ លោកអ្នកនឹងស្គាល់ព្រះអង្គច្រើនជាង ការដែលលោកអ្នកធ្លាប់ស្គាល់ព្រះអង្គ។ ដើម្បីឲ្យយើងអាចស្គាល់ព្រះអង្គបាន យើងត្រូវតែអនុញ្ញាតឲ្យទ្រង់បើកសំដែងអង្គទ្រង់មកកាន់យើង។ ហើយព្រះអង្គបានជ្រើសរើសក្នុងការធ្វើការនេះ តាមរយៈព្រះគម្ពីរ ដែលជាព្រះបន្ទូលរបស់ទ្រង់។ ដូច្នេះ អ្វីដែលយើងត្រូវធ្វើគឺពិនិត្យមើលទៅកាន់ព្រះបន្ទូលរបស់ទ្រង់ ហើយធ្វើពិភាក្សាជាមួយគ្នាពីការ ដែល ព្រះបន្ទូលទ្រង់ប្រាប់យើងអ្វីខ្លះ អំពីអង្គទ្រង់។

ការស្គាល់ព្រះអង្គគឺជាចំនេះដឹងដ៏សំខាន់ជាងគេបំផុត។ ប៉ុន្តែសេចក្តីសង្ឃឹមរបស់យើងគឺថា លោកអ្នកនឹងមិនគ្រាន់តែទទួលបានចំនេះដឹងតែប៉ុណ្ណោះទេ។ នៅពេលដែលយើងបានស្គាល់ព្រះដ៏ធំមហិមា និងពេញដោយសិរីល្អ ដោយផ្ទាល់ ដែលទ្រង់គឺជាព្រះនៃព្រះគម្ពីរ នោះយើងនឹងទទួលការផ្លាស់ប្រែ ដោយសារតែទំនាក់ទំនង របស់យើងជាមួយនឹងទ្រង់។ ពេលដែលយើងកាន់តែស្គាល់ទ្រង់ ចិត្តរបស់យើងក៏កាន់តែពោរពេញដោយ សេចក្តីសុខសាន្ត សេចក្តីអំណរ និង ការស្កប់ចិត្តនៅក្នុងទ្រង់។

ព្រះអម្ចាស់មានព្រះបន្ទូលថា៖ «អ្នកប្រាជ្ញមិនត្រូវអួត ព្រោះខ្លួនមានប្រាជ្ញា អ្នកខ្លាំងពូកែមិនត្រូវអួត ព្រោះខ្លួនមានកម្លាំង ហើយអ្នកមានក៏មិនត្រូវអួត ព្រោះខ្លួនមានទ្រព្យសម្បត្តិដែរ។ បើអ្នកណាចង់អួតខ្លួន ត្រូវអួត ព្រោះតែការចេះដឹង និងស្គាល់យើង ជាព្រះអម្ចាស់ ដែលសម្ដែងសេចក្ដីសប្បុរស សេចក្ដីសុចរិត និងយុត្តិធម៌នៅលើផែនដី។ មនុស្សប្រភេទនេះហើយដែលយើងពេញចិត្ត » - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។ (យេរេមា ៩:២៣-២៤)

ចូរឲ្យយើងបានស្គាល់ព្រះយេហូវ៉ាចុះ ហើយមានព្យាយាមនឹងស្គាល់ទ្រង់តទៅ ឯដំណើរដែលទ្រង់យាងចេញមក នោះទៀងដូចជាអរុណរះ ហើយទ្រង់នឹងយាងមកឯយើងរាល់គ្នា ដូចជាទឹកភ្លៀង គឺដូចជាភ្លៀងចុងរដូវ ដែលតែងតែស្រោចស្រពផែនដី។ (ហូសេ ៦:៣)

លោក(ម៉ូសេ)ទូលឆ្លើយថា សូមទ្រង់មេត្តាបើកឲ្យទូលបង្គំឃើញសិរីល្អទ្រង់ផង (និក្ខមនំ ៣៣:១៨)

# មេរៀនទី១ : ព្រះអង្គគឺជាព្រះអាទិករ

កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី។ (លោកុប្បត្តិ ១:១)

នៅក្នុងខគម្ពីរដំបូងនៃព្រះគម្ពីរ បានប្រាប់យើងថាព្រះអង្គបានបង្កើត “ផ្ទៃមេឃ និងផែនដី” ។ នៅក្នុងភាសាហេព្រើរឃ្លានេះ និយាយសំដៅទៅលើចក្រវាឡទាំងមូល។ ដូច្នេះនៅក្នុងខដំបូងនេះប្រាប់យើងថា ចក្រវាឡមិនតែងតែរមានវត្តមាន នោះទេ។ វាក៏មានដើមកំណើតផងដែរ។ ចក្រវាឡមានដើមកំណើតកើតឡើង នៅពេលដែលព្រះបានបង្កើត វាមក។

នៅក្នុងភាសាហេព្រើរ ពាក្យថា “បានបង្កើត” មានន័យថា “បង្កើតចេញពីភាពទទេ” ។ ព្រះអង្គបានបង្កើតចក្រវាឡចេញពីភាពទទេ។ ព្រះអង្គមិនបានប្រមែលប្រមូលផ្តុំឲ្យមានចក្រវាឡ ដូចជាយើងដាក់គ្រឿងផ្សំ បញ្ចូលគ្នាដើម្បីចំអិនអាហារនោះទេ។ ព្រះអង្គទ្រង់បានបង្កើតគ្រឿងផ្សំទាំងអស់។ ពេលវេលា លំហរ និងរូបធាតុសុទ្ធតែជាអ្វីដែលព្រះអង្គបានបង្កើត។ គ្មានអ្វីទាំងអស់ មានតែព្រះអង្គ ហើយក្រោយមកទ្រង់បាន បង្កើតអ្វីៗទាំងអស់។

ចូរគិតពីពិភពលោកនៅជុំវិញលោកអ្នក ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ ភ្នំ សមុទ្រ មនុស្ស សត្វ ហើយពិចារណា: ហេតុអ្វីបានរបស់ទាំងអស់នេះមានវត្តមានឡើង? អ្វីៗទាំងអស់នេះមានវត្តមានឡើង ដោយសារតែព្រះអង្គ បានបង្កើតទាំងអស់នោះមក។ គ្រប់ទាំងជីវិតទាំងអស់ កើតមានឡើង ដោយសារតែព្រះអង្គរចនាបង្កើតឡើង។ ចក្រវាឡបានបង្ហាញឲ្យយើងស្គាល់ថាព្រះអង្គមហិមាប៉ុណ្ណា។ ដូចជាអ្វីដែលព្រះគម្ពីរបាននិយាយថា ចក្រវាឡ “សំដែងពីសិរីល្អនៃព្រះ” ។

ទំនុកតម្កើង ១៩:១-៤ក

ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ

ហើយលំហអាកាសក៏បង្ហាញការ

ដែលព្រះហស្តទ្រង់ធ្វើ

ថ្ងៃ១ពោលប្រាប់តដល់ថ្ងៃ១ទៀត

ហើយយប់១ក៏សំដែងចំណេះដល់យប់១ទៀតដែរ

ឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ

គ្មានអ្នកណាដែលឮសំឡេងនៃរបស់ទាំងនោះទេ

ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមក

ក៏បានចេញទៅគ្រប់លើផែនដី

ហើយសេចក្ដីនោះបានឮទៅដល់ទីបំផុតលោកីយ៍

នៅលើមេឃ ទ្រង់បានដំឡើងត្រសាលសំរាប់ព្រះអាទិត្យ

មនុស្សគ្រប់គ្នាអាចដឹងថាមានព្រះ តាមរយៈការសំលឹងមើលការដែលទ្រង់បានបង្កើតបានធ្វើ។ កន្លែងណាក៏ដោយដែលយើងនៅ នៅក្នុងផែនដីនេះ យើងអាចសំលឹងមើលទៅលើមេឃ ហើយដឹងថាមានព្រះអាទិករដ៏មហិមាមួយអង្គ។ មិនថាយើងមានអាយុច្រើនតិចប៉ុណ្ណា ការអប់រំប៉ុណ្ណា វប្បធម៌ ឬ សាសនាណា យើងទាំងអស់គ្នាអាចមានបទពិសោធន៍ជាមួយនឹងសិរីល្អរបស់ព្រះ។ ហើយហ៊ុំពាត់ដោយសិរីល្អរបស់ទ្រង់។ កិច្ចការស្នាព្រះហស្តរបស់ទ្រង់ គឺនៅជុំវិញយើង ទាំងអស់គ្នា។

**ពិភាក្សាជាមួយនឹងដៃគូ : តើលោកអ្នកមានការកោតសរសើរ ទៅកាន់ផ្នែកណាមួយជាងគេ នៅក្នុងអ្វីដែលព្រះអង្គបានបង្កើត?**

សក្ខីភាពរបស់ការបង្កើត មកកាន់យើងទាំងអស់គ្នា គឺបង្ហាញថាព្រះអង្គគឺជាព្រះពេញដោយសិរីល្អ។ ផ្ទៃមេឃប្រកាសពីការនេះរៀងរាល់យប់ថ្ងៃ។ ការទាំងអស់នេះ បើកសំដែងចំនេះដឹងអំពីព្រះ។ សក្ខីភាពរបស់ការទាំង អស់នេះគឺមិនមែនតាមរយៈការរៀបរាប់នោះទេ តែតាមលក្ខណៈនៃ ការទាំងអស់នេះវិញ : គឺជាការបើក បង្ហាញពីអំណាចចេស្តា និង ប្រាជ្ញារបស់ព្រះអាទិកររបស់ពួកគេ។

រ៉ូម ១:២០

តាំងពីកំណើតពិភពលោកមក ព្រះចេស្ដាដ៏អស់កល្ប និង និស្ស័យជាព្រះរបស់ព្រះអង្គ ដែលទោះជាគេមើលមិនឃើញក្ដី នោះក៏បានបង្ហាញឲ្យឃើញច្បាស់ ហើយយល់បាន តាមរយៈអ្វីៗដែលព្រះអង្គបង្កើតមក។ ដូច្នេះ គេមិនអាចដោះសា បានឡើយ។ (ព្រះគម្ពីរបរិសុទ្ធកែសម្រួលឆ្នាំ ២០១៦)

យេរេមាន ១០:១២

ព្រះទ្រង់បានបង្កើតផែនដី ដោយឫទ្ធិតេជះរបស់ទ្រង់ ទ្រង់បានតាំងលោកីយ៍ឡើង ដោយសារប្រាជ្ញារបស់ទ្រង់ ហើយបានលាតផ្ទៃមេឃ ដោយសារយោបល់។

យើងមិនអាចមានការដោះសា ដោយនិយាយថាយើងមិនអាចស្គាល់ទ្រង់ទេ ព្រោះទ្រង់បានបើកសំដែងអង្គ ទ្រង់ឲ្យយើងស្គាល់ "ព្រះចេស្ដាដ៏អស់កល្ប និងនិស្ស័យជាព្រះរបស់ព្រះអង្គ" តាមរយៈអ្វីៗដែលទ្រង់បង្កើត។ សេចក្ដីពិតអំពីព្រះទាំងអស់នេះមិនមែនជាការលាក់កំបាំងនៅក្នុង អ្វីៗដែលទ្រង់បង្កើតនោះទេ តែ "បាន បង្ហាញឲ្យឃើញច្បាស់" ។ តាមរយៈការសំលឹងទៅមើលអ្វីដែលទ្រង់បានបង្កើត មនុស្សគ្រប់អាច មានការ យល់ដឹងខ្លះអំពីព្រះ។ ជំហានបន្ទាប់នោះពួកគេត្រូវធ្វើការស្វែងយល់ស្រាវជ្រាវ ៖ តើព្រះអាទិករ គឺជានរណា? ការស្វែងរកចម្លើយរបស់យើងគឺចាប់ផ្ដើមឡើងនៅក្នុងជំពូកទីមួយនៃគម្ពីរលោកុប្បត្តិ។

## ការសិក្សាព្រះគម្ពីរ លោកុប្បត្តិ ១

**អាន លោកុប្បត្តិ ១:១-១៣** នៅពេលលោកអ្នកស្ដាប់ សូមសរសេរចូលនូវអ្វីដែលព្រះអង្គបង្កើតនៅក្នុងថ្ងៃ និមួយៗ។

ថ្ងៃទី១ :

ថ្ងៃទី២ :

ថ្ងៃទី៣ :

នៅក្នុងបីថ្ងៃដំបូងព្រះអង្គបានបង្កើតកន្លែងសម្រាប់ឲ្យជីវិតអាចមានវត្តមានបាន ផ្ទៃមេឃ ដី និង សមុទ្រ។ ហើយនៅបីថ្ងៃបន្ទាប់ទ្រង់បានបំពេញ ទីកន្លែងទាំងនោះ ដោយការបង្កើតជីវិតយ៉ាងវិសេសវិសាលត្រឹម ត្រូវសម្រាប់កន្លែងទាំង នោះ។

**អានលោកុប្បត្តិ ១:១៤-៣១** នៅពេលដែលលោកអ្នកស្តាប់ សរសេចូលនូវអ្វីដែលព្រះអង្គបង្កើតនៅក្នុងថ្ងៃ និមួយៗ។

ថ្ងៃទី៤ :

ថ្ងៃទី ៥ :

ថ្ងៃទី ៦ :

គ្រប់យ៉ាងត្រូវបានបង្កើតរចនាឡើងដោយសារ ព្រះដ៏មានព្រះចេស្តា ព្រះអាទិករ ដែលពេញដោយប្រាជ្ញា ហើយទ្រង់បានមានបន្ទូលថា ទាំងអស់គឺជាការល្អ។ ព្រះអង្គគឺជាជាងរចនា ស្ថាបត្យករ និងវិស្វករដ៏ល្អអស្ចារ្យបំផុត។ ទ្រង់បានរចនារបៀបសត្វស្លាបត្រូវហោះហើរយ៉ាងណា របៀបត្រីហែលទឹក រចនាឲ្យដើមឈើ បង្កើតឲ្យមានអុកស៊ីហ្សែន និងរបៀបដែលទារកធំឡើងក្លាយជាមនុស្សធំ។ នេះគឺជាការអស្ចារ្យយ៉ាងក្រៃលែង ដែលកំពុងមានឡើងនៅជុំវិញយើងជា រៀងរាល់ថ្ងៃ។

ហើយក៏មានការអស្ចារ្យដែលកំពុងកើតឡើងនៅក្នុងយើងផងដែរ។ ព្រះអង្គ ដែលទ្រង់គឺជាព្រះដែលបាន បង្កើតផ្ទៃមេឃ និងផែនដី ទ្រង់ក៏បានបង្កើតយើងម្នាក់ៗផងដែរ។ ព្រះគម្ពីរបានប្រាប់យើងថា “ទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោតគួរអស្ចារ្យ” (ទំនុកតំកើង ១៣៩:១៤)។ នៅក្នុងភាសាហេព្រើរ ពាក្យថា ‘គួរកោត’ មានន័យថា ‘គួរស្ញប់ស្ញែង’ ។ យើងនឹងមានការស្ញប់ស្ញែងយ៉ាងខ្លាំង នៅពេលដែលយើង យល់ដឹងថា រាងកាយរបស់យើងមានភាពអស្ចារ្យប៉ុណ្ណា។

**ការពិតជាក់ស្តែងយ៉ាងអស្ចារ្យអំពីរាងកាយរបស់មនុស្ស**

- បេះដូងរបស់លោកអ្នក លោតចំនួន បីរយពាន់លានដង (ក្នុងអាយុកាលមធ្យម)
- លោកអ្នកដកដង្ហើមចំនួនជាង ២០០០០ ដង ក្នុងមួយថ្ងៃ
- រាងកាយរបស់លោកអ្នកមាន កោសិកាចំនួន ៣៥ លានលាន (កោដិលាន)
- ច្រមុះលោកអ្នកអាចស្គាល់ក្លិន ចំនួនមួយកោដិលានក្លិន
- អាស៊ីតក្រពះរបស់អ្នកអាចរំលាយជាតិដែកបាន
- រាងកាយរបស់អ្នកផលិតស្រទាប់ស្បែកថ្មីរាល់ ៣០ ថ្ងៃម្តង
- ព័ត៌មានធ្វើដំណើរតាមសរសៃប្រសាទរបស់លោកអ្នកក្នុងរយៈពេលជាង ៣០០ គីឡូម៉ែត្រក្នុង មួយម៉ោង!
- គ្រោងឆ្អឹងរបស់លោកអ្នកត្រូវបានផ្លាស់ប្តូរថ្មីជារៀងរាល់ ១០ ឆ្នាំម្តង។
- ឈាមរបស់លោកអ្នកចរាចរប្រហែលជា ១៩.០០០ គីឡូម៉ែត្រ / ថ្ងៃ។ នេះគឺដូចជាការធ្វើដំណើរពីខាងកើតទៅខាងលិចឆ្លងកាត់ផ្នែកធំបំផុតនៃមហាសមុទ្រប៉ាស៊ីហ្វិក។
- មានសរសៃឈាមប្រវែងជាង ១៦០.០០០ គីឡូម៉ែត្រក្នុងខ្លួនរបស់លោកអ្នក។ ប្រសិនបើដាក់ជាខ្សែបន្ទាត់តែមួយ នោះសរសៃឈាមរបស់លោកអ្នកអាចព័ទ្ធជុំវិញផែនដី ៤ ដង។
- ប្រសិនជាលោកអ្នករមូ ឌីអិនអេរបស់លោកអ្នកចេញ វាអាចពន្លាតមានប្រវែង ១៦ ពាន់លាន គីឡូម៉ែត។ នេះគឺជាចម្ងាយដូចគ្នាពីផែនដីទៅភពព្រហស្បតិ៍និងត្រឡប់មកវិញដប់ដង។

**ធ្វើការពិភាក្សាជាមួយនឹងដៃគូ៖  តើការពិតជាក់ស្តែងណាមួយ ដែលធ្វើលោកអ្នកមានភាពអស្ចារ្យ ។**

ទំនុកតំកើង ១៣៩:១៣-១៤

ដ្បិតគឺទ្រង់ដែលបានបង្កើតចិត្តថ្លើមនៃទូលបង្គំ

ហើយបានផ្សំគ្រឿងនៃទូលបង្គំនៅក្នុងផ្ទៃម្តាយ

ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់

ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ

ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់

ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ

ឥឡូវចូរឲ្យយើងសំលឹងមើលលើសខ្លួនយើង នោះគឺជាការមើលទៅកាន់ភពផែនដី ដែលព្រះអង្គបានបង្កើត សម្រាប់យើង។ ទំហំ ចម្រុះភាព និងភាពស្មុគស្មាញនៃជីវិតនៅលើផែនដីនេះ គឺជាសក្ខីភាពទៅកាន់ប្រាជ្ញា និងអំណាចចេស្ដារបស់ព្រះ។ សូមរកដៃគូម្នាក់ ហើយសំលឹងទៅបញ្ជីខាងក្រោម ហើយទាយថាតើព្រះអង្គ បានបង្កើតឲ្យមានភាវរស់និមួយៗមានប៉ុន្មានប្រភេទ។

- ស្រមោច _________ ប្រភេទ,
- បក្សី _________ ប្រភេទ
- រុក្ខជាតិផ្កា _________ ប្រភេទ,
- ផ្សិត _________ ប្រភេទ
- ថនិកសត្វចំនួន _________ ប្រភេទ។

តាមរយៈការនេះយើងអាចឃើញថា ព្រះអង្គពិតជាចូលចិត្តផ្សិតណាស់ 😀 ប៉ុន្តែនិយាយឲ្យមែនទែនទៅ យើងឃើញថាភាពចម្រុះនៃអ្វី ដែលទ្រង់បានបង្កើតនៅលើផែនដីពិតជាមានភាពអស្ចារ្យយ៉ាងខ្លាំង! ព្រះអង្គមិនមែន គ្រាន់តែបង្កើតឲ្យមានស្រមោច ឬ បក្សី ឬ រុក្ខជាតិតែមួយប្រភេទនោះទេ។ ទ្រង់បានបំពេញផែនដីនេះ ដោយបង្កើតឲ្យគ្រប់ទាំងអស់មានភាពចម្រុះយ៉ាងធំធេង។

**ពិភាក្សា ៖ តើយើងរៀនបានអ្វីអំពីព្រះ តាមរយៈការឃើញពីភាពចម្រុះយ៉ាងធំធេងក្រៃលែង នៅក្នុងអ្វីៗដែលទ្រង់បានបង្កើត?**

ផែនដីពិតជាមានភាពអស្ចារ្យក្រៃលែង។ យ៉ាងណាមិញ ផែនដីគ្រាន់តែផ្នែកតូចមួយប៉ុណ្ណោះ នៅក្នុងចក្រវាឡ ដែលទ្រង់បានបង្កើត។ នៅក្នុងចំនុចបន្ទាប់ ចូរយើងគិតពិចារណាអំពី អ្វីដែលព្រះគម្ពីរហៅថា "ផ្ទៃមេឃ" នោះគឺជាគ្រប់យ៉ាងដែលខ្ពង់ខ្ពស់ហួសពីផែនដី នៅលំហខាងក្រៅផែនដី។ ព្រះអាទិត្យរបស់យើងគឺជាផ្កាយ ដែលមាន ទំហំធំជាងផែនដីចំនួន ១លានដង! នៅក្នុងកាឡាក់ស៊ីរបស់យើង មានផ្កាយចំនួន ១០០ ពាន់លានផ្កាយ។ ផ្កាយខ្លះមានទំហំធំធេងខ្លាំងជាងព្រះអាទិត្យទៅទៀត។ ប្រសិនបើលោកអ្នកគិតថាការនេះ គឺជាអ្វី ដែលអស្ចារ្យក្រៃលែង លោកអ្នកត្រូវដឹងថា កាឡាក់ស៊ីរបស់យើងគឺគ្រាន់តែជា កាឡាក់ស៊ីមួយនៅក្នុងចំណោ ម ១០០ ពាន់លាន កាឡាក់ស៊ី ដែលមាននៅក្នុងចក្រវាឡ!

ការនេះធ្វើឲ្យមនុស្សមួយចំនួនមានអារម្មណ៍ថាតូចណាស់ ប៉ុន្តែវាតែធ្វើឲ្យយើងគិតថា តើព្រះយើងទ្រង់ធំ មហិមាប៉ុណ្ណា! ចក្រវាឡដ៏ធំធេងនេះបានបង្កើតឡើងយ៉ាងព្រិតព្រៀង ហើយបើកសំដែងឲ្យយើងដឹងថា មានព្រះអាទិករ ដែលមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ឈ្លាសវៃ ហើយមានគ្រប់ទាំងព្រះចេស្តា។ ចក្រវាឡនេះមានភាពធំ ធេង ហើយស្មុគស្មាញណាស់ ហើយមានតែទ្រង់ទេ ដែលអាចបង្កើត ចក្រវាឡនេះបាន ដោយព្រោះថាទ្រង់ គឺជាព្រះអាទិករ ដែលអាចធ្វើគ្រប់ការទាំងអស់ បានជ្រាបគ្រប់ ការទាំងអស់ ហើយមានព្រះវត្តមានគ្រប់ទី កន្លែង។ ព្រះរបស់យើងមានអំណាចចេស្តាគ្មានដែនកំណត់។

**ការស្គាល់ព្រះអង្គក្នុងលក្ខណៈផ្ទាល់ខ្លួន**

នៅពេលយើងអានពីការបង្កើត វាគឺជាការសំខាន់សំរាប់យើងក្នុងការ កត់សំគាល់ទៅកាន់ចរិតលក្ខណៈរបស់ព្រះអង្គដែលបានបើកសំដែងឡើង។ សូមសរសេរមួយពាក្យ ដែលពណ៌នាពីការទ្រង់ធ្វើ នៅក្នុងខគម្ពីរទាំងនេះ ដែលបានដកស្រង់ចេញពីគម្ពីរលោកុប្បត្តិជំពូក១ :

<u>បង្កើត</u>______ (ខ 1, 21, 27)

__________ (ខ 3, 6, 9, 11, 14, 20, 24, 26, 29)

__________ (ខ 4, 10, 12, 18, 21, 25, 31)

__________ (ខ 5, 8, 10)

__________ (ខ 7, 16, 25)

__________ (ខ 22, 28)

__________ (ខ 29, 30)

យើងឃើញថាព្រះអង្គមិនមែនគ្រាន់តែ អំណាចឥទ្ធិឫទ្ធិនៅក្នុងចក្រវាឡនោះទេ តែទ្រង់គឺជាអង្គបុគ្គល ដែលយើងអាចស្គាល់បាន។ ទ្រង់គឺជាព្រះដ៏ខ្ពង់ខ្ពស់មានគ្រប់ទាំង អំណាចព្រះចេស្តាពេញដោយ ព្រះបញ្ញា សព្វញ្ញូវញ្ញាណ ដែលទ្រង់មានការពាក់ព័ន្ធផ្ទាល់ និង មានភាពរស់រវើកនៅក្នុង ការបង្កើត ចក្រវាឡរបស់ទ្រង់ ដោយការមានព្រះបន្ទូល ការទតឃើញ ត្រាស់ហៅ ធ្វើ ប្រទាន ពរ និងប្រទាន។ ព្រះអង្គក៏មានភាពពាក់ព័ន្ធ យ៉ាងសកម្មនៅក្នុងពិភពលោកតាំងពីដើមដំបូងរហូតមកដល់ពេលនេះ និងជារៀងរហូតតទៅ។ សេចក្តីពិតដ៏អស្ចារ្យមួយនៅក្នុងព្រះគម្ពីរនោះគឺ ព្រះអង្គគឺជាដែលដ៏មានព្រះជន្មរស់ ជាអង្គបុគ្គលមានទំនាក់ទំនង ហើយកំពុងធ្វើការនៅក្នុងពិភពលោកនេះ។ ព្រះអង្គនៅតែ មានបន្ទូល មើលឃើញ ត្រាស់ហៅ ធ្វើការ ប្រទានពរ និង ឲ្យផ្គត់ផ្គង់ ទៅកាន់មនុស្ស នៅថ្ងៃនេះ និងជានិច្ចតទៅ។

**ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន**

តាមរយៈការដែលយើងបានសិក្សាពីការទាំងនេះ យើងគួរតែពិចារណាពីការឆ្លើយតបទៅកាន់សំនួរទាំងនេះ :

- ប្រសិនបើព្រះអង្គមានបន្ទូល តើលោកអ្នកមានចំណាប់អារម្មណ៍ទៅកាន់អ្វីដែលព្រះអង្គមានបន្ទូល ដែរឬទេ?
- បើព្រះអង្គទតមើល តើលោកអ្នកចង់ដឹងពីអ្វី ដែលទ្រង់ទតឃើញនៅពេលទ្រង់ទតមើលមកកាន់ពិភពលោកនេះ?
- ប្រសិនបើព្រះអង្គប្រទានពរ និង ផ្គត់ផ្គង់ឲ្យ តើលោកអ្នកមានចំណាប់អារម្មណ៍ទៅកាន់ព្រះពរ និង អំណោយទានដែលទ្រង់មានដែរ ឬទេ?

ហើយសំនួរដ៏សំខាន់បំផុតសម្រាប់ឲ្យយើងម្នាក់ៗក្នុងការឆ្លើយតបគឺ

- តើលោកអ្នកចង់ស្គាល់ព្រះអង្គ ដែលទ្រង់ជាព្រះ ដែលបានបង្កើតលោកអ្នកមក ច្រើនប៉ុណ្ណា?

**ចំនុចចំបង**

ចំនុចចំបងដែលព្រះគម្ពីរបានបង្រៀនអំពីព្រះអង្គ គឺជាព្រះអាទិករគឺ :

១) ព្រះអង្គបានបង្កើតចក្រវាឡទាំងមូល ចេញពីភាពទទេ។

២) ការបង្កើត បង្ហាញពី សិរីល្អ អំណាចចេស្តា និង ប្រាជ្ញានៃព្រះ។

៣) ទ្រង់គឺជាព្រះដ៏ខ្ពង់ខ្ពស់មានគ្រប់ទាំង អំណាចព្រះចេស្តា ពេញដោយព្រះបញ្ញា សព្វញ្ញូវញ្ញាណ ដែលទ្រង់មានការពាក់ព័ន្ធផ្ទាល់ និង មានភាពរស់រវើក នៅក្នុងការបង្កើតចក្រវាឡរបស់ទ្រង់។

**ព្រះពរ**

សូមព្រះយេហូវ៉ាចំរើនឯងរាល់គ្នា ឲ្យកាន់តែច្រើនឡើង គឺឯងរាល់គ្នា ហើយនឹងកូនចៅរបស់ឯងរាល់គ្នាផង

ឯងរាល់គ្នាបានពរពីព្រះយេហូវ៉ា ជាព្រះដែលបាន បង្កើតផ្ទៃមេឃ និងផែនដី (ទំនុកតម្កើង ១១៥:១៤-១៥)

# មេរៀនទី២ : ព្រះអង្គគឺជាប្រភពជីវិត និង ជាអង្គបុគ្គលទ្រទ្រង់ជីវិតទាំងអស់

នៅក្នុងមេរៀនទីមួយរបស់យើង យើងឃើញថា មានព្រះអង្គមុនអ្វីៗទាំងអស់ ហើយក្រោយមកទ្រង់បាន បង្កើតអ្វីៗទាំងអស់។ នៅក្នុងមេរៀននេះ យើងនឹងរៀនអំពីព្រះ ដែលព្រះអង្គគឺជាប្រភពជីវិត និង ជាអង្គបុគ្គលទ្រទ្រង់ ជីវិតទាំងអស់។

**(១) ទ្រង់មានជីវិតនៅក្នុងទ្រង់ខ្លួនឯង**

ជាញឹកញយមានគេសួរសំនួរមួយថា "តើអ្នកណាបង្កើតព្រះ?" ។ ចម្លើយគឺ គ្មាននរណាបានបង្កើតព្រះទេ។ គ្មាននរណាបង្កើតព្រះអង្គនោះទេ។ ព្រះវត្តមានមិនបានកើតឡើងដោយសារអ្វីមួយ ឬ នរណាម្នាក់នោះទេ។ គ្មានពេលណាមួយ ដែលព្រះអង្គគ្មានវត្តមាននោះទេ។ គ្មាននរណាធ្វើឲ្យព្រះអង្គមានជីវិតនោះទេ។ ទ្រង់ ផ្ទាល់គឺជាជីវិត។ វាគឺជានិស្ស័យ និង ភាពជាព្រះរបស់ទ្រង់ ដើម្បីឲ្យទ្រង់អាចមានព្រះវត្តមានបាន។ ព្រះអង្គ គឺជាព្រះដ៏មានព្រះជន្មរស់ ដែលគង់នៅអស់កល្បជានិច្ច។

ព្រះអង្គមានវត្តមានខុសពីអ្វីៗគ្រប់យ៉ាងទាំងអស់។ គ្រប់ទាំងការបង្កើតទាំងអស់គឺមកពីព្រះអង្គ ហើយមាន ការពឹងពាក់ទៅលើទ្រង់ ប៉ុន្តែទ្រង់វិញ ទ្រង់មាន "ជីវិតនៅក្នុងព្រះអង្គទ្រង់" (យ៉ូហាន ៥:២៦)។ ព្រះជន្មរបស់ ទ្រង់មិនមែនពឹងផ្អែក ឬ បានមកពីនរណាម្នាក់ ឬ អ្វីមួយក្រៅពីទ្រង់នោះទេ។

**(២) ព្រះអង្គទ្រង់មានភាពគ្រប់គ្រាន់នៅក្នុងព្រះអង្គឯង**

ព្រះអង្គមិនត្រូវការអ្វីមួយ ដើម្បីឲ្យទ្រង់អាចទ្រទ្រង់ព្រះជន្មនោះទេ។ ព្រះអង្គមានព្រះជន្មរស់មុនគ្រប់យ៉ាង ទាំងអស់បានមានវត្តមានឡើង។ ដូច្នេះនេះមានន័យថា ព្រះជន្មទ្រង់មិនមានការពឹងពាក់ទៅលើអ្វីៗ ដែល ទ្រង់បានបង្កើតនោះទេ។ ទោះបីជាចក្រវាឡទាំងមូលរលាយសាបសូន្យ ទ្រង់នៅតែមានព្រះជន្មគង់នៅតទៅ មុខជារៀងរហូត។

សូមស្តាប់នូវអ្វីដែលសាវ័កប៉ុលបាននិយាយ ៖

"ដ្បិតព្រះដែលបង្កើតលោកីយ៍ និងរបស់សព្វសារពើ ព្រះអង្គនោះ ទ្រង់ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី ទ្រង់មិនគង់នៅក្នុងវិហារដែលដៃមនុស្សបានធ្វើទេ ក៏មិនបាច់មានដៃមនុស្សបំរើទ្រង់ ដូចជាទ្រង់ត្រូវការអ្វីនោះផងដែរ ដ្បិតគឺទ្រង់ដែលផ្គត់ផ្គង់ដោយព្រះអង្គទ្រង់ ឲ្យគ្រប់ទាំងអស់មានជីវិត មានដង្ហើមគ្រប់ជំពូក" (កិច្ចការ ១៧:២៤-២៥)

តើការនេះបង្រៀនអ្វីអំពីព្រះមកកាន់យើង?

_______________________________________________________________________________________

_____

_______________________________________________________________________________________

_____

លោកប៉ុលកំពុងតែប្រកាសព្រះបន្ទូលនៅក្នុងទីក្រុង អាថែន ទៅកាន់មនុស្សដែលមានជំនឿទៅលើព្រះក្លែងក្លាយ។ ពួកគេគិតថាព្រះរបស់ពួកគេ ត្រូវការ ការថ្វាយសំណែន ដើម្បីឲ្យព្រះទាំងរបស់គេអាចមាន ជីវិតរស់រានតទៅមុខ។ លោកប៉ុលបានបកស្រាយយ៉ាងច្បាស់ថា ព្រះដ៏ពិតទ្រង់មិនដូច្នោះនោះឡើយ! ព្រះអង្គមិនត្រូវការអ្វីសោះឡើយ ដើម្បីឲ្យទ្រទ្រង់ព្រះជន្មនោះទេ។ ផ្ទុយទៅវិញ គឺទ្រង់ហើយដែលជាអង្គបុគ្គលដែលប្រទានជីវិត ហើយទ្រទ្រង់ជីវិតនៃអ្វីៗ ទាំងអស់។

**(៣) គ្រប់ទាំងជីវិតទាំងអស់គឺសុទ្ធតែបានមកពី ព្រះជន្មរបស់ព្រះ**

**ព្រះអង្គមានគ្រប់ទាំងជីវិតទាំងអស់។** មានតែទ្រង់ទេដែលព្រះជន្មនៅក្នុងព្រះអង្គឯង។ គ្មានជីវិតណាដែលកើតឡើងដោយខ្លួនឯងទេ ហើយក្រៅពីទ្រង់ គ្មានជីវិតណាអាចកើតឡើងបានឡើយ ។ គ្រប់ទាំងជីវិតទាំងអស់គឺមក ពីព្រះ ហើយជាកម្មសិទ្ធិរបស់ព្រះ។

**ព្រះអង្គគឺជាព្រះ ដែលប្រទានឲ្យមានជីវិតគ្រប់ទាំងអស់។** ការបង្កើតគឺជា ការដែលព្រះអង្គបានបង្ហាញពី ព្រះគុណរបស់ទ្រង់ ដោយទ្រង់បានប្រទានជីវិតដែលទ្រង់មាន ផ្តល់ទៅឲ្យជីវិតទាំងអស់ ព្រោះថាដង្ហើមជីវិត គឺមកពីទ្រង់។

ហើយយើងទាំងអស់គ្នា អាចដកដង្ហើមឥឡូវនេះបាន គឺដោយសារតែខ្យល់ដង្ហើម ដែលទ្រង់ បានប្រទានឲ្យ។

លោកុប្បត្តិ ២:៧

ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជា មានព្រលឹងរស់ឡើង។

អេសាយ ៤២:៥

ឯព្រះដ៏ជាព្រះយេហូវ៉ា ជាព្រះដែលបានបង្កើតអស់ទាំងជាន់ផ្ទៃមេឃ ហើយបានលាតផង គឺជាព្រះដែលបានក្រាលផែនដី និងរបស់សព្វសារពើដែលចេញពីនោះមក គឺព្រះអង្គដែលប្រទានឲ្យប្រជាជាតិទាំងប៉ុន្មាននៅផែនដីមានដង្ហើម ព្រមទាំងឲ្យមនុស្សទាំងឡាយដែលដើរក្នុងលោកមានវិញ្ញាណផង ទ្រង់មានព្រះ បន្ទូលថា

សូមរកដៃគូម្នាក់ហើយ ពិភាក្សាជាមួយនឹងគ្នាថា តើមនុស្សអាចរស់បានយូរប៉ុណ្ណាប្រសិនបើគ្មាន :

- អាហារ?
- ទឹក?
- ខ្យល់ដកដង្ហើម?

មនុស្សមានការពឹងផ្អែកទៅលើការជាច្រើន។ យើងរស់មិនបានយូរប៉ុន្មានទេ បើសិនជាគ្មានខ្យល់ដកដង្ហើម។ យើងមានជីវិតនាពេលឥឡូវនេះ ដោយសារតែយើងមានដង្ហើមជីវិតនៅក្នុងយើង។ នៅពេលដែលព្រះអង្គដកដង្ហើមជីវិតចេញពីយើង នោះយើងនឹងស្លាប់។

ទំនុកតម្កើង ១០៤:២៩

កាលទ្រង់លាក់ព្រះភក្ត្រ នោះវាបានថប់ព្រួយវិញ

កាលទ្រង់ដកយកដង្ហើមចេញ នោះវាក៏ស្លាប់

ហើយត្រឡប់ទៅជាធូលីដីវិញ

យ៉ូប ៣៤:១៤-១៥

បើទ្រង់ផ្ចង់ព្រះហឫទ័យចំពោះតែព្រះអង្គទ្រង់ ហើយប្រមូលវិញ្ញាណ និងខ្យល់ដង្ហើមទ្រង់ ត្រឡប់ទៅវិញ នោះគ្រប់ទាំងសាច់នឹងត្រូវវិនាសទៅទាំងអស់ ហើយមនុស្សនឹងត្រូវត្រឡប់ទៅជាធូលីដីវិញ។

ព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ហើយបន្ទាប់ពីយើងស្លាប់ទៅ រូបកាយរបស់យើងនឹងក្លាយទៅជាធូលីដីវិញ។ តើអ្វីដែលធ្វើឲ្យយើង មានជីវិតរហូតមកដល់ពេលនេះ? គឺដោយសារខ្យល់ដង្ហើមរបស់ព្រះនៅក្នុងយើង។ ចូរឲ្យយើងកត់សំគាល់ថា គឺ “ព្រះវិញ្ញាណនៃទ្រង់” ហើយ “ខ្យល់ដង្ហើមទ្រង់” ។ ជីវិតរបស់យើងគឺ បានមកពីព្រះ។ សូមអាន ហើយបំពេញខទាំងនេះ :

- **យ៉ូប ៣៣:៤**

  ព្រះវិញ្ញាណនៃព្រះបានបង្កើតខ្ញុំ ហើយខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ព្រះចេស្តាបាន________________។

- **យ៉ូប ១២:១០**

  ដែលជីវិតនៃសត្វទាំងឡាយ សុទ្ធតែនៅក្នុងព្រះហស្តទ្រង់ ព្រមទាំង________________________ ដូច្នេះ។

- **កិច្ចការ ១៧:២៨**

  ដ្បិតគឺដោយសារទ្រង់ហើយ ដែល________________________ហើយមាននៅផង ដូចជាពួកអ្នកលើកកំណាព្យខ្លះរបស់អ្នករាល់គ្នា បាននិយាយដែរថា «មនុស្សយើងជាពូជព្រះដែរ»

តើយើងរៀនបានអ្វីអំពីព្រះ តាមរយៈខគម្ពីរទាំងនេះ?

____________________________________________________________________________
_____

____________________________________________________________________________
_____

**(៤) ព្រះអង្គគឺជាព្រះដែលទ្រទ្រង់ជីវិតទាំងអស់**

ជីវិតទាំងអស់ដែលមានវត្តមាន គឺសុទ្ធតែមានការពឹងផ្អែកទាំងស្រុងទៅព្រះ មិនមែនគ្រាន់តែពេលទាំងអស់បានចាប់កំណើតឡើងប៉ុណ្ណោះទេ ប៉ុន្តែពីមួយទៅមួយពេល ដើម្បីឲ្យអាចបន្តក្នុងការមានវត្តមាន។ ព្រះអង្គ បានបង្កើត និងទ្រទ្រង់អ្វីៗទាំងអស់នៅស្ថានសួគ៌ និងផែនដី។

នេហេមា ៩:៦

គឺទ្រង់តែ១ដែលជាព្រះឯកអង្គ ទ្រង់បានបង្កើតផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃ ព្រមទាំងពួកពលបរិវារនៅលើនោះ និងផែនដី ហើយសមុទ្រ និងរបស់សព្វសារពើដែលនៅស្ថានទាំងនោះផង ទ្រង់ក៏ទប់ទល់ជីវិតនៃរបស់ទាំងនោះ ហើយពួកពលនៅលើមេឃ ក៏ថ្វាយបង្គំដល់ទ្រង់។

ព្រះអង្គទ្រទ្រង់ជីវិតទាំងអស់គ្រប់ពេលវេលា។ ទ្រង់បន្តឲ្យភពផ្សេងៗ បន្តមានវត្តមាន ផែនដីបន្តវិល ព្រះអាទិត្យបន្តជះពន្លឺ ហើយបន្តមានភ្លៀងធ្លាក់។ គ្មានអ្វីអាចមានវត្តមានបានឡើយ ប្រសិនបើគ្មានព្រះ។

**<u>ការសិក្សាព្រះគម្ពីរ ទំនុកតំកើង: ១០៤</u>**

- អានទំនុកតម្កើង ១០៤

មានចំនុចណាខ្លះ ដែលលោកអ្នកអាចចាំពីទំនុកតម្កើង ដែលនិយាយអំពីការដែលព្រះអង្គប្រទានជីវិត ឬ ទ្រទ្រង់ពិភពលោកនេះ? សូមចំណាយពេល ពីរបីនាទី ក្នុងការសរសេរចំនុចទាំងច្រើនតាមលោកអ្នកអាច ចងចាំបាន ជាមួយនឹងដៃគូម្នាក់។

ព្រះអង្គគឺជាព្រះដែលទ្រទ្រង់ជីវិតទាំងអស់ គឺចាប់តាំងពីអ្វីដែលធំបំផុត ទៅកាន់អ្វីដែលតូចបំផុត

**ការពិភាក្សា:**

- តើការដែលព្រះអង្គទ្រង់គឺជាព្រះ ដែលទ្រទ្រង់កាឡាស៊ី ភពនានា ហើយទ្រង់ក៏ទ្រទ្រង់ជីវិតត្រីតូច និង បក្សាបក្សី បានប្រាប់ឲ្យយើងស្គាល់អ្វីអំពីព្រះ?
- តើអ្វីគឺជាការឆ្លើយតបត្រឹមត្រូវចំពោះ ការដែលយើងដឹងពីសេចក្ដីពិតនេះថា ជីវិតគឺមានការពឹងពាក់ទាំងស្រុង ទៅកាន់ព្រះ?

ពេលក្រោយ ដែលលោកអ្នកនៅខាងក្រៅផ្ទះ សូមចំណាយពេលសំលឹងមើលទៅកាន់ពិភពលោកនៅជុំវិញលោកអ្នក។ គ្រប់យ៉ាងទាំងអស់សុទ្ធតែស្ថិតស្ថេរ និងទ្រទ្រង់ដោយព្រះ។ ហើយប្រសិនបើព្រះអង្គឈប់ធ្វើ ការទាំងអស់នេះ សូមបីតែមួយភ្លែត គ្រប់ទាំងអស់នឹងលែងមានវត្តមាន។ ព្រះអង្គគឺជាព្រះ ដែលទ្រទ្រង់គ្រប់ ទាំងការបង្កើតទាំងអស់។ ទ្រង់គឺជាព្រះដ៏ធំធេងមហិមាដែលទ្រង់បានបង្កើត រាប់ពាន់លាន កាឡាក់ស៊ី ហើយ ទ្រទ្រង់អ្វីៗទាំងអស់នេះ ដោយគ្មានការខិតខំប្រឹងប្រែង នេះគឺជា អ្វីដែលធំធេងខ្ពង់ខ្ពស់ជាងការយល់ដឹងរបស់យើង។ ព្រះដែលបានធ្វើការទាំងនេះ គឺជាព្រះដែល សក្តិសម ទទួលកិត្តិនាម និង ការថ្វាយបង្គំ។ ប្រសិនបើយើងមានការស្ញប់ស្ញែងទៅកាន់អ្វីៗ ដែលទ្រង់បានបង្កើត តើយើងគួរមានភាពស្ញប់ស្ញែងខ្លាំងប៉ុណ្ណា ថែមទៀត ទៅកាន់ទ្រង់?

ទំនុកតម្កើង ៩៥:៣-៧

ដ្បិតព្រះយេហូវ៉ាទ្រង់ជាព្រះយ៉ាងធំ

ហើយជាមហាក្សត្រយ៉ាងខ្ពស់លើអស់ទាំងព្រះ

អស់ទាំងទីជំរៅនៃផែនដីនៅក្នុងព្រះហស្តទ្រង់

ហើយកំពូលភ្នំទាំងប៉ុន្មាន សុទ្ធតែជារបស់ផងទ្រង់ដែរ

សមុទ្រជារបស់ផងទ្រង់ គឺទ្រង់ដែលបានបង្កើតមក

ហើយគឺព្រះហស្តទ្រង់ដែលបានសូនធ្វើដីគោក

មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា

ចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា

ជាព្រះដ៏បង្កើតយើងខ្ញុំ

ដ្បិតទ្រង់ជាព្រះនៃយើងខ្ញុំហើយ

យើងខ្ញុំក៏ជាហ្វូងចៀមនៅទីគង្វាលរបស់ទ្រង់

គឺជារាស្ត្រដែលនៅក្នុងព្រះហស្តទ្រង់

នៅថ្ងៃនេះ បើឯងរាល់គ្នាឮសំឡេងទ្រង់

**(៥) ព្រះអង្គគឺជាម្ចាស់លើទាំងអស់**

ក្នុងនាមទ្រង់គឺជាព្រះអាទិករ ទ្រង់គឺជាម្ចាស់នៅលើគ្រប់របស់ទាំងអស់ ដែលទ្រង់បានបង្កើតឡើង

ចោទិយកថា ១០:១៤

មើល ផ្ទៃមេឃ ហើយអស់ទាំងជាន់ផ្ទៃមេឃខាងលើ និងផែនដី ព្រមទាំងរបស់សព្វសារពើ ដែលនៅស្ថានទាំងនោះ សុទ្ធតែជារបស់ផងព្រះយេហូវ៉ា ជាព្រះនៃឯង

១ របាក្សត្រ ២៩:១១

នឱព្រះយេហូវ៉ាអើយ ភាពដ៏ធំ និងព្រះចេស្ដា សិរីល្អ ជ័យជំនះ និងតេជានុភាព នោះសុទ្ធតែជារបស់ផងទ្រង់ ដ្បិតគ្រប់ទាំងអស់ដែលនៅលើមេឃ និងនៅផែនដី ជារបស់ផងទ្រង់ ឱព្រះយេហូវ៉ាអើយ រាជ្យនេះក៏ជារបស់ផងទ្រង់ដែរ ហើយទ្រង់បានដំកើងឡើង ជាប្រធានលើទាំងអស់

តើអ្វីខ្លះជារបស់ផងព្រះ? គ្រប់ទាំងអស់នៅលើ_________ និង គ្រប់ទាំងអស់ដែលនៅ_________។

ទំនុកតម្កើង ២៤:១

ផែនដី និងសារពើនៅផែនដី ជារបស់ផងព្រះយេហូវ៉ា ព្រមទាំងលោកីយ៍ និងបណ្ដាអ្នកដែលនៅលោកីយ៍ផង

តើលោកអ្នកនៅលើផែនដីនេះដែរ ឬទេ? តើលោកអ្នករស់នៅក្នុងពិភពលោកនេះទេ? អញ្ចឹងតើលោកអ្នកគឺជាកម្មសិទ្ធិរបស់អ្នកណា?

សេចក្ដីពិត ដែលនិយាយថាព្រះអង្គ គឺជាព្រះអាទិកររបស់យើង បង្ហាញថាយើងគឺជាកម្មសិទ្ធិរបស់ទ្រង់។ មូលហេតុដែលយើងម្នាក់ៗមានជីវិតរស់នៅ គឺដោយសារតែព្រះបានបង្កើតយើងមក ហើយទ្រទ្រង់យើងឲ្យបន្តមានជីវិត។ យើងទាំងអស់មានវត្តមានជីវិតរបស់យើង គឺដោយសារទ្រង់។ ដើម្បីឲ្យយើងអាចមានការយល់ ដឹងត្រឹមត្រូវ ពីព្រះអង្គ ហើយនិងតួនាទីរបស់យើងនៅក្នុងការបង្កើតរបស់ទ្រង់ យើងត្រូវតែដឹងពីសេចក្ដីពិត មួយថា យើងមិនមែនជាម្ចាស់លើជីវិតរបស់ខ្លួនឯងនោះទេ។ យើងគឺជាកម្មសិទ្ធិរបស់អង្គបុគ្គល ដែលបាន បង្កើតយើងមក។ នេះមានន័យថា យើងមានទំនួលខុសត្រូវ រស់នៅស្របតាមបំណងព្រះហឫទ័យទ្រង់ ហើយ ដើម្បីថ្វាយសិរីល្អទៅកាន់ទ្រង់។

នៅក្នុង រ៉ូម ១១:៣៦ លោកប៉ុលបានសរសេរ

*ដ្បិតរបស់សព្វសារពើបានកើតមកពីទ្រង់ ដោយសារទ្រង់ ហើយសំរាប់ទ្រង់ សូមឲ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន។*

ព្រះអង្គគឺជាព្រះអាទិករ (“កើតមកពីទ្រង់”) អង្គបុគ្គលទ្រទ្រង់ (“ដោយសារទ្រង់”) ហើយជាគោលបំណង (“សំរាប់ទ្រង់”) របស់ការបង្កើតទាំងអស់។ យើងគឺជាកម្មសិទ្ធិរបស់ទ្រង់ ដោយសារតែទ្រង់គឺជា ព្រះអាទិកររបស់យើង។ យើងពឹងផ្អែក លើទ្រង់ ដោយសារតែទ្រង់គឺជា ព្រះដែលទ្រទ្រង់ជីវិតរបស់យើង។ យើងរស់នៅដើម្បីស្គាល់ទ្រង់ ហើយរស់នៅ សម្រាប់ទ្រង់ និង សម្រាប់ជាការថ្វាយសិរីល្អទៅកាន់ទ្រង់ ដ្បិតទ្រង់ហើយគឺជាគោលបំណងនៃជីវិតរបស់យើង។

វិវរណៈ ៤:១១

“ឱព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្តា ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះ បានកើតមក ហើយមាននៅផង។

**ពិភាក្សា**

- តើលោកអ្នករៀនបានអ្វីខ្លះអំពីព្រះ តាមរយៈមេរៀននេះ?
- តើសេចក្តីពិតនេះ ធ្វើឲ្យមានលទ្ធផលទាក់ទងយ៉ាងណាមកកាន់ជីវិតលោកអ្នក?

**ចំនុចចំបង**

ចំនុចបំបង ដែលព្រះគម្ពីរបង្រៀនអំពីព្រះ ដែលទ្រង់គឺជាប្រភពជីវិត និង អង្គបុគ្គលទ្រទ្រង់ជីវិតគឺ :

1) ព្រះអង្គទ្រង់មានព្រះជន្មនៅក្នុងអង្គទ្រង់ផ្ទាល់។ ទ្រង់មានវត្តមានជារៀងរហូត។
2) ព្រះអង្គគឺជាព្រះ ដែលមានគ្រប់គ្រាន់នៅក្នុងអង្គទ្រង់ផ្ទាល់ ហើយគ្មានការត្រូវការណានោះទេ។
3) ព្រះអង្គ គឺជាប្រភពនៃជីវិតទាំងអស់។
1) ព្រះអង្គ គឺជាអង្គបុគ្គលទ្រទ្រង់ជីវិតទាំងអស់។
2) គ្រប់យ៉ាងដែលនៅលើមេឃ និង ផែនដីគឺជាកម្មសិទ្ធិរបស់ទ្រង់។

**ព្រះពរ**

ឥឡូវនេះ សូមព្រះនៃសេចក្ដីសង្ឃឹមប្រទានឲ្យអ្នករាល់គ្នាបានគ្រប់អស់ទាំងសេចក្ដីអំណរ និងសេចក្ដី សុខសាន្តដ៏ពោរពេញ ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឲ្យបានសេចក្ដីសង្ឃឹមជាបរិបូរ ដោយព្រះចេស្តា នៃព្រះវិញ្ញាណបរិសុទ្ធ។ (រ៉ូម ១៥:១៣)

# មេរៀនទី ៣ : ព្រះគង់នៅអស់កល្បជានិច្ច ហើយមិនប្រែប្រួល

ប្រសិនបើគោលដៅរបស់យើងគឺដើម្បីស្គាល់ព្រះ នោះយើងត្រូវតែស្គាល់ព្រះនាមរបស់ទ្រង់។ នៅក្នុងសៀវភៅទីពីរនៃព្រះគម្ពីរ គឺសៀវភៅនិក្ខមនំ ព្រះទ្រង់បានបង្ហាញអង្គទ្រង់ទៅកាន់បុរសម្នាក់ឈ្មោះថាម៉ូសេ ហើយទ្រង់បានបញ្ជូនឲ្យគាត់ទៅដឹកនាំជនជាតិអ៊ីស្រាអែល។ លោកម៉ូសេ មានអារម្មណ៍សង្ស័យថា ពួកអ៊ីស្រាអែល នឹងមិនស្ដាប់គាត់នោះទេ ដូច្នេះគាត់សួរព្រះអង្គ សំនួរយ៉ាងសំខាន់មួយ។

និក្ខមនំ ៣:១៣-១៥

ម៉ូសេក៏ទូលទៅព្រះថា មើល កាលណាទូលបង្គំទៅប្រាប់ពួកកូនចៅអ៊ីស្រាអែលថា ព្រះនៃឰយុកោអ្នករាល់គ្នាទ្រង់បានចាត់ ខ្ញុំឲ្យមកឯអ្នករាល់គ្នា ហើយគេសួរទូលបង្គំថា តើព្រះទ្រង់ព្រះនាមជាអ្វី នោះតើត្រូវឲ្យទូលបង្គំប្រាប់គេថាដូចម្តេច

ព្រះទ្រង់មានព្រះបន្ទូលទៅម៉ូសេថា «អញជាព្រះដ៏ជាព្រះ» រួចទ្រង់មានព្រះបន្ទូល ទៀតថា ឯងត្រូវឆ្លើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះដ៏ជាព្រះទ្រង់បានចាត់ឲ្យខ្ញុំមកឯង អ្នករាល់គ្នា

ព្រះទ្រង់ក៏ មានព្រះបន្ទូលនឹងម៉ូសេទៀតថា ចូរនិយាយនឹងពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះយេហូវ៉ាជាព្រះនៃពួកឰយុកោអ្នករាល់គ្នា គឺជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃយ៉ាកុប ទ្រង់បានចាត់ឲ្យខ្ញុំមកឯអ្នក រាល់គ្នា នោះជាឈ្មោះអញនៅអស់កល្បជានិច្ច ហើយក៏សំរាប់ជាសេចក្តីរំឭក ពីអញ ដល់គ្រប់ទាំងដំណរៀងរាបតទៅ

នៅក្នុងខ ១៥ ព្រះអង្គបង្ហាញព្រះនាមព្រះអង្គថា **יְהוָה** (មានន័យថា យ៉ាវេ)

ព្រះអង្គមានបន្ទូលថា នោះជាឈ្មោះទ្រង់នៅអស់កល្បជានិច្ច ហើយក៏សំរាប់ជាសេចក្ដីរំឭក ពីទ្រង់ដល់គ្រប់ ទាំងដំណរៀងរាបតទៅ។ ព្រះនាមទ្រង់ត្រូវបានសរសេរចំនួន ៦២១៨ដង នៅក្នុងព្រះគម្ពីរ លើសជាងពាក្យណាផ្សេងៗទៀតសម្រាប់ព្រះ។ នៅក្នុងភាសាខ្មែរ ត្រូវបានគេបកប្រែថា ព្រះយេហូវ៉ា នៅក្នុងព្រះគម្ពីរបកប្រែចាស់ (OV) ហើយព្រះអម្ចាស់នៅក្នុងគម្ពីរបកប្រែថ្មី (KHSV)។ នៅក្នុងភាសាអង់គ្លេស ត្រូវបានបកប្រែថា 'the LORD' ដែលសរសេរជាអក្សរធំទាំងអស់ជាភាសាអង់គ្លេស។

**តើព្រះនាមព្រះអង្គមានអត្ថន័យយ៉ាងដូចម្ដេច?**

ព្រះនាមរបស់ព្រះ មានភាពស្រដៀងគ្នាទៅកាន់ពាក្យក្នុងភាសាហេព្រើរ ដែលមានន័យថា 'I AM' «អញជាព្រះដ៏ជាព្រះ» (យើងគឺជាយើង)។ ទោះបីវាជាការមិនអាចទៅរួចក្នុងការបកប្រែឲ្យចំត្រឹមត្រូវក៏ដោយ ព្រះនាមរបស់ព្រះអង្គមានន័យថា 'អង្គបុគ្គលដ៏នៅអស់កល្បជានិច្ច' 'គឺជាអង្គបុគ្គលដែលតែងតែមានវត្តមានតាំងពីណាពីណែមក' 'គឺជាអង្គបុគ្គល ដែលបានមានវត្តមានតាំងពីមុនមក រហូតដល់សព្វថ្ងៃ ហើយជារៀងរហូតតទៅ' ។ ដូច្នេះព្រះនាម ព្រះអង្គពណ៌នាពី ភាពជាព្រះរបស់ទ្រង់ ដែលទ្រង់គង់នៅស្ថិតស្ថេរ អស់ កល្បជានិច្ច ហើយគ្មានការប្រែប្រួល នោះឡើយ។ ចូរឲ្យយើងមើលទៅកាន់សេចក្ដីពិតទាំងនេះ ដែលប្រាប់ មកកាន់យើងអំពីព្រះ។

## (១) ព្រះអង្គគ្មានទីចាប់ផ្ដើម

យើងបានឃើញនៅក្នុងមេរៀនទីមួយរបស់យើងថា ចក្រវាឡមានទីចាប់ផ្ដើម តែព្រះអង្គគ្មានទីចាប់ផ្ដើមទេ។ ព្រះអង្គទ្រង់តែងតែមានវត្តមានជានិច្ច មុនពេលវេលាបានចាប់ផ្ដើម មុនពេលចក្រវាឡត្រូវបានបង្កើតឡើង ហើយមុនអ្វីៗទាំងអស់បានមានវត្តមានឡើង។ ទ្រង់មានវត្តមានគង់នៅស្ថិតស្ថេរ អស់កល្បជានិច្ច។

> ទំនុកតម្កើង ៩៣:១-២
>
> ព្រះយេហូវ៉ាទ្រង់ជាអ្នកគ្រប់គ្រង
>
> ទ្រង់ប្រដាប់អង្គដោយភាពដ៏រុងរឿងឧត្តម
>
> ព្រះយេហូវ៉ាទ្រង់ប្រដាប់អង្គ ដោយតេជានុភាព

ព្រមទាំងក្រវាត់អង្គ ដោយសេចក្ដីនោះដែរ

ឯលោកីយ៍នោះបានតាំងមាំមួន និងរង្គើមិនបានឡើយ

បល្ល័ង្កទ្រង់បានតាំងនៅ ចាប់តាំងពីចាស់បូរាណ

គឺមានទ្រង់តាំងតែពីអស់កល្បរៀងមក

ព្រះអង្គមក "ពីអស់កល្បរៀងមក" ។ នៅពេលដែលនរណាម្នាក់សួរលោកអ្នកថា "តើលោកអ្នកមកពីណា?" តើលោកអ្នក ឆ្លើយយ៉ាងដូចម្ដេច?

ពួកយើងតែងនិយាយពីកន្លែងដែលយើងកើត ឬ កន្លែងដែលយើងធំធាត់ឡើង ដោយសារតែកន្លែងនោះគឺជា ទីចាប់ផ្ដើម នៃជីវិតរបស់យើង។ ប៉ុន្តែព្រះអង្គទ្រង់គ្មានពេលវេលា និងទីកន្លែងនៃការចាប់ផ្ដើមនោះទេ។ ព្រះអង្គទ្រង់មក "ពីអស់កល្បរៀងមក" ។

គ្មានពេលណាមួយ ដែលព្រះអង្គគ្មានជីវិត ឬ វត្តមាននោះទេ។ ប្រសិនបើលោកអ្នកមានម៉ាស៊ីនពេលវេលា ហើយត្រលប់ទៅកាន់អតីតកាល ទៅកាន់ពេលវេលាដំបូងបំផុត នោះនឹងឃើញថា ព្រះអង្គមានវត្តមានតាំង ពីពេលនោះមកម្លេះ។ ហើយប្រសិនបើលោកអ្នកអាចត្រលប់ទៅគ្រា មុនពេលវេលាចាប់ផ្ដើមឡើង ទ្រង់ក៏ មានព្រះជន្មគង់នៅគ្រានោះដែរ។ ទ្រង់មានព្រះជន្មគង់នៅ មានវត្តមាន អស់កល្បជានិច្ច។

## (២) ព្រះអង្គគ្មានទីបញ្ចប់

តើលោកអ្នកធ្លាប់ឮពាក្យគេនិយាយថា "គ្មានអ្វីដែលស្ថិតស្ថេរជារៀងរហូតនោះទេ" ដែរឬទេ? នៅពេលដែលមនុស្ស និយាយដូច្នេះ ពួកគេមានន័យថា អ្វីៗទាំងអស់នៅក្នុងជីវិត តែងតែរមានការប្រែប្រួល។ មនុស្សមក ហើយទៅមាន ការសាងសង់ មានការរុះចោល ជំនួញអាជីវកម្មចាប់ផ្ដើមឡើង ហើយក្រោយមកត្រូវបញ្ចប់... ដូច្នេះតើវាគឺជាការពិតដែរ ឬទេ ដែលថា គ្មានអ្វីដែលស្ថិតស្ថេរជារៀងរហូត? ទេ វាមិនពិតទេ ព្រោះព្រះអង្គ ទ្រង់គង់នៅស្ថិតស្ថេរអស់កល្បជានិច្ច។ ព្រះអង្គគឺជាព្រះអស់កល្ប ហើយគ្មានទីបញ្ចប់។

ទំនុកតម្កើង ១០២:២៥-២៧

កាលដើមដំបូងទ្រង់បានតាំងឫសផែនដី

ហើយផ្ទៃមេឃក៏ជាស្នាដៃរបស់ព្រះហស្តទ្រង់ដែរ

របស់ទាំងនោះនឹងវិនាសសូន្យទៅពិត

តែទ្រង់នឹងស្ថិតស្ថេរនៅវិញ

អើ របស់ទាំងនោះនឹងចាស់ទៅ ដូចជាសំលៀកបំពាក់

ហើយទ្រង់នឹងផ្លាស់ចេញដូចជាផ្លាស់អាវ

ដូច្នេះនឹងបានផ្លាស់ចេញជាពិត

ប៉ុន្តែ ឯទ្រង់ៗនៅដដែល

ហើយព្រះជន្មទ្រង់មិនចេះផុតឡើយ

ទំនុកតម្កើង ១០២:១១-១២

អស់ទាំងថ្ងៃអាយុនៃទូលបង្គំ

ដូចជាស្រមោលដែលជ្រេទៅ

ហើយទូលបង្គំក្រៀមទៅដូចជាស្មៅ។

១ ប៉ុន្តែ ឱព្រះយេហូវ៉ាអើយ ទ្រង់នឹងគង់សោយរាជ្យ

នៅអស់កល្បជានិច្ច

ហើយនឹងមានសេចក្តីនឹកចាំពីទ្រង់

នៅអស់ទាំងដំណមនុស្សតទៅ

១ ធីម៉ូថេ ១:១៧

រីឯស្តេចនៃអស់ទាំងកល្ប ដែលទ្រង់មិនចេះសុគត ហើយមើលទ្រង់មិនឃើញ គឺជាព្រះតែ១ព្រះអង្គ
នោះសូមឲ្យទ្រង់ បានល្បីព្រះនាម និងសិរីល្អអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន។

តើខគម្ពីរទាំងបានបង្រៀនយើងអ្វីអំពីព្រះ?

__________________________________________________________________________________

_____

តើខគម្ពីរទាំងនេះប្រាប់អ្វីមកកាន់យើងអំពី មនុស្ស និង ចក្រវាឡ? តើមានអ្វីផ្សេងទៀតទេ ដែលគ្មានទីបញ្ចប់?

__________________________________________________________________________________

____

**(៣) ព្រះអង្គមានព្រះជន្មគង់នៅជានិរន្ត**

**ព្រះអង្គគឺជាភាពពិតជាក់ស្តែងគង់វង្ស ទៀងត្រង់តែមួយគត់។** អ្វីៗគ្រប់យ៉ាងផ្សេងទៀតគឺបណ្តោះអាសន្ន មានវត្តមាននៅក្នុងគ្រាមួយ តែប៉ុណ្ណោះ។ ប៉ុន្តែព្រះអង្គគ្មានដែនកំណត់នៅក្នុងពេលវេលានោះទេ។ ទ្រង់ហើយជាព្រះ "ចាប់តាំងពីអស់ កល្ប រៀងទៅដល់អស់កល្បជានិច្ច"។

ទំនុកតម្កើង ៤១:១៣

សូមលើកសរសើរដល់ព្រះយេហូវ៉ា

ជាព្រះនៃសាសន៍អ៊ីស្រាអែល

ចាប់តាំងពីអតីតទៅដល់អនាគត អស់

កល្បជានិច្ច អាម៉ែន ហើយអាម៉ែន។

ទំនុកតម្កើង ៩០:១-២

ឱព្រះអម្ចាស់អើយ

ទ្រង់បានធ្វើជាទីអាស្រ័យនៅនៃយើងខ្ញុំ

នៅអស់ទាំងដំណតមក

គឺមុនដែលអស់ទាំងភ្នំបានកើតឡើង

ក្នុងកាលដែលទ្រង់មិនទាន់បង្កើតផែនដី

និងមនុស្សលោកនៅឡើយ

ចាប់តាំងពីអស់កល្ប រៀងទៅដល់អស់កល្បជានិច្ច

នោះគឺទ្រង់ហើយជាព្រះ

សូមឲ្យយើងស្រមៃថានេះគឺជាខ្សែបន្ទាប់ពេលវេលា តាំងពីដើមដំបូងនៃពិភពលោករហូតដល់ទីបញ្ចប់នៃ ពិភពលោក។

---

ព្រះអង្គមានព្រះជន្មគង់នៅតាំងពីមុនពេលវេលា ឥឡូវនេះ និង ជារៀងរហូតតទៅ។

យូដាស ២៥

គឺជាព្រះអង្គដ៏ជាព្រះតែមួយ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង នោះសូមឲ្យទ្រង់បានសិរីល្អ ឫទ្ធានុភាព ព្រះចេស្តា និងអំណាច តាំងពីមុនអស់កល្ប នៅជាន់ឥឡូវនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ។ អាម៉ែន។

**ពិភាក្សា: តើលោកអ្នកគិតការមានភាពអស់កល្បអាចមានលក្ខណៈយ៉ាងណា?**

**(៤) ព្រះអង្គមិនប្រែប្រួល**

ព្រះអង្គមិនមែនគ្រាន់តែមានព្រះវត្តមានគង់នៅជារៀងរហូតតែប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គទ្រង់ក៏មិនប្រែប្រួល អស់កល្បជានិច្ចតទៅផងដែរ។ គ្រប់យ៉ាងដែលជាសេចក្តីពិតអំពីទ្រង់ គឺជាសេចក្តីពិតជារៀងរហូតតទៅ។

នៅក្នុងជីវិតរបស់យើងឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន : កើត លូតលាស់ ពេញវ័យ កើនអាយុ ស្លាប់។ ប៉ុន្តែ**គ្មានការផ្លាស់ប្តូរប្រែប្រួលនៅក្នុងទ្រង់ ក្នុងនាមទ្រង់គឺជាអង្គបុគ្គលឡើយ**។ ពេលវេលាគ្មានការជះឥទ្ធិពលទៅកាន់ ទ្រង់នោះទេ។ វាមិនអាច ធ្វើឲ្យព្រះអង្គមានការប្រែប្រួលបាននោះឡើយ។ ព្រះអង្គមិនដែលធ្លាប់មាន ភាពវ័យក្មេង ឬ វ័យចាស់នោះឡើយ។ ព្រះអង្គក៏មិនពេញវ័យ ឬ អន់ថយដែរ។ ព្រះអង្គក៏មិនចេះ នឿយអត់ដែរ។ គ្មានការផ្លាស់ប្តូរ

គុណភាពជាមួយនឹងព្រះអង្គនោះទេ។ ព្រះអង្គគឺឥតខ្ចោះ។ ព្រះអង្គមិនរីក ចម្រើននោះទេ ព្រោះថាព្រះអង្គឥតខ្ចោះ ហើយ។ ព្រះអង្គក៏មិនអន់ខ្សោយជាងមុនដែរ ដោយព្រោះថាព្រះអង្គ គឺជាព្រះល្អឥតខ្ចោះ។

**គ្មានការប្រែប្រួលនៅក្នុងសមាសភាព (ភាពជាព្រះ)របស់ទ្រង់ទេ។** គឺគ្រប់ទាំងសមាសភាពជាព្រះរបស់ ទ្រង់តាំង ពីមុនមកដល់ឥឡូវ និង រហូតអស់កល្បជានិច្ចតទៅ។ តើព្រះអង្គមានគ្រប់ទាំងអំណាចចេស្តា ដែរឬទេ នៅពេលដែលទ្រង់បង្កើតចក្រវាឡ? បាទទ្រង់មាន ហើយទ្រង់ក៏នៅតែមានគ្រប់ទាំងអំណាចចេស្តា ដូចគ្នា រហូតមកដល់ពេល សព្វថ្ងៃនេះ។ អំណាចចេស្តារបស់ទ្រង់ មិនកើនឡើង ហើយក៏មិនថយចុះដែរ។ ទ្រង់មានគ្រប់ទាំងអំណាច ព្រះចេស្តាតាំងពីមុនមកមកដល់ពេលឥឡូវនេះ នឹងរហូតតរៀងទៅ។ ហើយនេះក៏ជាការពិតអំពីសមាសភាព (ភាពជាព្រះ) របស់ទ្រង់ដែរ។ គ្មានពេលណាមួយ ដែលទ្រង់គ្មាន ព្រះសព្វវត្តមាន ឬ មិនមានគ្រប់ទាំងប្រាជ្ញា សព្វញ្ញុតញាណ និយាយឲ្យខ្លីគឺទ្រង់មិនដែលបាត់បង់ សមាសភាព (ភាពជាព្រះ)របស់ទ្រង់ ឡើយ។

**គ្មានការប្រែប្រួលនៅក្នុងចរិតលក្ខណៈរបស់ទ្រង់ឡើយ។** ព្រះអង្គគឺជាព្រះ សុចរិត យុត្តិធម៌ ល្អ ពេញដោយសេចក្តីស្រលាញ់ ពេញដោយព្រះគុណ និង ពេញដោយសេចក្តីស្មោះត្រង់។ ចរិតលក្ខណៈទាំងអស់នេះ របស់ទ្រង់នៅតែមានភាពទៀងត្រង់ជានិច្ច ដូចដែលពួក អ្នកសរសេរគម្ពីរទំនុកតម្កើង ពួកហោរា និង ពួក សាវ័កបានសរសេររៀបរាប់អំពីទ្រង់ រាប់ពាន់ឆ្នាំមុន។ ហើយសព្វថ្ងៃនេះទ្រង់ក៏នៅតែមានចរិតលក្ខណៈទាំង អស់នេះដែរ ហើយទ្រង់ក៏នឹងបន្តមានចរិតលក្ខណៈទាំងអស់តទៅ រាប់ពាន់ឆ្នាំខាងមុខ។ គ្មានថ្ងៃដែលទ្រង់ ឈប់មាន ភាពសុចរិតយុត្តិធម៌ សេចក្តីស្រលាញ់ ល្អឧត្តម ពេញដោយព្រះគុណ និង សេចក្តីស្មោះត្រង់ ឡើយ។

ទំនុកតម្កើង ១០០:៥

ពីព្រោះព្រះយេហូវ៉ាទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច

ហើយសេចក្តីស្មោះត្រង់របស់ទ្រង់ ក៏នៅអស់ទាំងដំណមនុស្សតទៅ។

ម៉ាឡាគី ៣:៦

ដ្បិតអញគឺយេហូវ៉ា អញមិនប្រែប្រួលឡើយ ហេតុនោះ ឱពួកកូនចៅយ៉ាកុបអើយ ឯងរាល់គ្នាមិនបានត្រូវវិនាសទេ។

យ៉ាកុប ១:១៧

រប់ទាំងរបស់ដ៏ល្អ ដែលព្រះប្រទានមក និងអស់ទាំងអំណោយទានដ៏គ្រប់លក្ខណ៍ នោះសុទ្ធតែមកពី ស្ថានលើ គឺមកពីព្រះវរបិតានៃពន្លឺ ដែលទ្រង់មិនចេះប្រែប្រួល សូម្បីតែស្រមោលនៃសេចក្ដីផ្លាស់ប្រែ ក៏គ្មានដែរ។

សេចក្ដីពិតដែលនិយាយថាព្រះអង្គជាព្រះ ដែលមិនចេះប្រែប្រួល ទ្រង់នៅតែដដែលគឺមាននៅក្នុង ព្រះគម្ពីរ។ ដូច្នេះ នៅពេលដែលយើងអានព្រះគម្ពីរ យើងមិនគ្រាន់តែអំពីរឿងចាស់ៗ ដែលមិនមាន ការពាក់ព័ន្ធមកកាន់ស្ថានភាពសព្វថ្ងៃនេះនោះទេ។ នៅពេលដែលយើងអានព្រះគម្ពីរ យើងកំពុងតែ សិក្សាស្វែងយល់អំពីចរិតលក្ខណៈរបស់ទ្រង់ របៀបព្រះអង្គធ្វើការ ព្រះហឫទ័យទ្រង់ និង គោលបំណង របស់ព្រះដ៏មានព្រះជន្មរស់! គ្មានអ្វីដែលមានការពាក់ព័ន្ធមកកាន់ស្ថានភាពនៃជីវិតរបស់យើង ជាងការសិក្សាអំពីទ្រង់ឡើយ។ ព្រះអង្គដដែល ដែលបានគង់ជាមួយនឹង អ័ប្រាហាំ ម៉ូសេ នាងរស់ ដាវីឌ អេសធើរ ម៉ារា និង ប៉ុល ទ្រង់ក៏គង់នៅ ជាមួយនឹងលោកអ្នកនាពេលសព្វថ្ងៃនេះដែរ។ ទ្រង់មិនប្រែប្រួលឡើយ។ ទ្រង់នៅតែមានគ្រប់ទាំងអំណាចចេស្ដាពេញដោយប្រាជ្ញា និង មានព្រះទ័យ ល្អសប្បុរស។ គ្រប់ទាំងសេចក្ដីពិត ដែលយើងបានសិក្សាអំពីទ្រង់ សុទ្ធតែមានតំលៃដោយសារតែសេចក្ដីពិតទាំងនោះទៀងត្រង់ ជារៀងរហូត មិនហួសសម័យ ឬ ជាអ្វីដែល ចាស់កំរិលឡើយ។

**ការសរុបសេចក្ដី:** ព្រះអង្គមិនទទួលការជះឥទ្ធិពលនៃ ពេលវេលា។ ព្រះអង្គគឺជាព្រះ ដែលទ្រង់ទៀងត្រង់ គង់ នៅស្ថិតស្ថេរអស់កល្បជារៀងរហូត។ ចូរឲ្យយើងបញ្ចប់ជាមួយគ្នា ដោយពិចារណាទៅលើ ការជាប់ទាក់ទងជាមួយនឹងការយល់ដឹងទាំងអស់នេះអំពីព្រះ។

**ដំបូងព្រះអង្គគ្មានព្រំដែននៅក្នុងពេលវេលា។** គ្មានដើមដំបូង គ្មានទីបញ្ចប់ ព្រះអង្គមិននៅជាប់ក្រោមអំណាចព្រំដែនរបស់ពេលវេលានោះឡើយ។ ព្រះអង្គជាអ្នកដែលបង្កើតពេលវេលា។ ពេលវេលា បម្រើទៅកាន់ព្រះអង្គ ហើយមិនមែនជាម្ចាស់របស់ទ្រង់នោះទេ។ ព្រះអង្គបានរៀបចំផែនការនៅក្នុង ភាពអស់កល្បជានិច្ច មុនពេលអ្វីៗទាំងអស់បានកើតមានឡើង ហើយឥឡូវទ្រង់ធ្វើការនៅក្នុងពេលវេលា។ ព្រះអង្គមិនដែលយឺតពេល ហើយព្រះអង្គ ក៏មិនដែល ប្រញាប់ដែរ។ ព្រះអង្គមិនដែលអស់ពេល ហើយទ្រង់ក៏មិនដែលរវល់ពេកក្នុងការធ្វើអ្វីមួយដែរ។ ព្រះដ៏អស់កល្បជានិច្ចរបស់យើងទ្រង់មានការអត់ធ្មត់

ក្នុងការសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់។

២ពេត្រុស ៣:៨-៩

តែពួកស្ងួនភ្ងាអើយ កុំឲ្យភ្លេចសេចក្តី១នេះឡើយ គឺថា នៅចំពោះព្រះអម្ចាស់១ថ្ងៃទុកដូចជា១ពាន់ឆ្នាំ ហើយ១ពាន់ឆ្នាំ ក៏ទុកដូចជា១ថ្ងៃដែរ ព្រះអម្ចាស់មិនផ្អាកសេចក្តីសន្យារបស់ទ្រង់ ដូចជាមានអ្នកខ្លះ គិតស្មាន នោះទេ គឺទ្រង់មាន ព្រះហឫទ័យអត់ធ្មត់នឹងយើងរាល់គ្នាវិញ ដោយមិនចង់ឲ្យអ្នកណាមួយវិនាស ឡើយ គឺចង់ឲ្យមនុស្សទាំងអស់បានប្រែចិត្តវិញ

**ទីពីរ ព្រះអង្គគង់នៅជាមួយនឹងមនុស្សគ្រប់ជំនាន់ទាំងអស់។** ព្រះអង្គបានទតឃើញប្រវត្តសាស្ត្ររបស់ មនុស្ស ទាំងអស់នៅគ្រប់ជំនាន់ តាំងតែរពីដំបូងមកម្ល៉េះ។

អេសាយ ៤១:៤

តើអ្នកណាបានធ្វើហើយសំរេចការនេះ

ដោយហៅអស់ទាំងដំណមនុស្សតាំងពីដើមមក គឺអញ

យេហូវ៉ានេះ ដែលជាដើម ហើយជាអ្នកនៅជាមួយនឹង

មនុស្សជាន់ក្រោយបង្អស់ដែរ គឺអញនេះហើយ

ទំនុកតម្កើង ១០៣:១៧

តែសេចក្តីសប្បុរសនៃព្រះយេហូវ៉ាស្ថិតស្ថេរនៅ

តាំងពីអស់កល្បជាបដល់អស់កល្បជានិច្ច

ចំពោះអស់អ្នកដែលកោតខ្លាចដល់ទ្រង់

សេចក្តីសុចរិតរបស់ទ្រង់ ក៏នៅរហូតដល់កូនចៅគេតទៅ

វាគឺជាការយ៉ាងប្រពៃដែលយើងដឹងថា ព្រះអង្គទ្រង់គង់ជាមួយយើងអស់មួយជីវិត ទ្រង់ដឹកនាំ ផ្គត់ផ្គង់ ហើយស្រឡាញ់ លោកអ្នក ហើយទ្រង់ក៏នឹងគង់ជាមួយនឹងកូនចៅរបស់លោកអ្នកផងដែរ។ ទ្រង់គង់នៅជាមួយនឹងមនុស្សគ្រប់ជំនាន់ ទាំងអស់ ត្រាស់ហៅពួកគេឲ្យឆ្ពោះទៅមុខ។ យើងនឹងមិននៅទីនេះជារៀងរហូតនោះទេ តែ ទ្រង់វិញ ទ្រង់នឹងគង់នៅ ជារៀងរហូត។ កេរ្តិ៍ដំណែលដ៏ធំបំផុត ដែលយើងអាចឲ្យទៅកាន់កូនចៅជំនាន់ក្រោយ របស់យើងបាន នោះគឺជា កេរ្តិ៍ដំណែលនៃសេចក្តីជំនឿជឿលើព្រះ។

ទីបី ដោយសារតែព្រះអង្គមិនប្រែប្រួល គ្រប់យ៉ាងដែលមាននៅក្នុងសមាសភាព(ភាពជាព្រះ)របស់ទ្រង់ និងចរិតលក្ខណៈរបស់ទ្រង់ គ្មានការប្រែប្រួលឡើយ។ នេះមានន័យថា **ព្រះបន្ទូលទ្រង់ ព្រះដំរិះទ្រង់ ផែនការ របស់ទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់មិនមានការប្រែប្រួលឡើយ**។ នេះហើយគឺជា ប្រភពនៃស្ថេរភាព និង សុខសុវត្ថិភាពយ៉ាងធំធេងសម្រាប់អស់អ្នកណាដែល ទុកចិត្តទៅលើព្រះអង្គ។ យើងអាចទុកចិត្តពឹងផ្អែក ទៅលើព្រះបន្ទូលរបស់ទ្រង់ដែលជាគ្រឹះនៃជីវិតរបស់យើង ហើយកាន់ជាប់ទៅកាន់សេចក្តីសន្យារបស់ទ្រង់ ដោយសារតែ គ្រប់ទាំងសេចក្តីសន្យារបស់ទ្រង់ មិនដែលប្រែប្រួលឡើយ។

អេសាយ ៤០:៨

ស្មៅក៏ស្វិតក្រៀម ហើយផ្កាពោយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងរាល់គ្នាវិញ នោះស្ថិតស្ថេរនៅ ជាដរាប។

ទំនុកតម្កើង ១១៩:៨៩

ឱព្រះយេហូវ៉ាអើយ ព្រះបន្ទូលទ្រង់បានតាំងនៅស្ថានសួគ៌ ដរាបដល់អស់កល្បជានិច្ច

១ សាំយូអែល ១៥:២៩

១ទៀត ព្រះដ៏ជាកំឡាំងនៃសាសន៍អ៊ីស្រាអែលទ្រង់មិនចេះកុហក ឬប្រែប្រួលឡើយ ដ្បិតទ្រង់មិនមែន ជាមនុស្សដែលចេះប្រែប្រួលទេ

ទំនុកតម្កើង ៣៣:១១

ឯដំបូន្មានផងព្រះយេហូវ៉ាវិញ នោះជាប់ជានិច្ច

ហើយដំរិះក្នុងព្រះហឫទ័យទ្រង់ក៏នៅជាដរាប ដល់អស់ទាំងដំណតទៅ

ទីបួន ព្រះអង្គអាចប្រទានជីវិតអស់កល្បទៅកាន់មនុស្ស។ នគររបស់ព្រះគង់នៅស្ថិតស្ថេរជារៀងរហូត ហើយទ្រង់ប្រទានជីវិតទៅកាន់អស់អ្នកណាដែលមកឯទ្រង់ដោយសេចក្តីជំនឿ។ តាមរយៈការទទួលជីវិតអស់ កល្បជាពីទ្រង់ ដែលមានតែទ្រង់ទេ ដែលប្រទានការនេះមកកាន់យើងបាន យើងនឹងមានបទពិសោធន៍ជា មួយនឹងភាពធំឧត្តម របស់ព្រះនៃយើង

ជាច្រើនឆ្នាំជារៀងរហូត។

យ៉ូហាន ៦:៤៧

ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលជឿដល់ខ្ញុំ នោះមានជីវិតអស់កល្បជានិច្ច

យ៉ូហាន ១៧:៣

នេះជាជីវិតដ៏អស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ដ៏ជាព្រះពិតតែ១ នឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឲ្យមកផង

ទំនុកតម្កើង ៤៨:១៤

ទ្រង់ជាព្រះនៃយើងខ្ញុំនៅអស់កល្បជានិច្ច ទ្រង់នឹងធ្វើជាអ្នកនាំមុខយើងខ្ញុំ ដរាបដល់អស់ជីវិតផង។

**ពិភាក្សា**

- តាមរយៈមេរៀននេះ តើលោកអ្នករៀនបានអ្វីអំពីព្រះ?
- តើមានលទ្ធផលទាក់ទងយ៉ាងណាខ្លះពីសេចក្តីពិតនេះ មកកាន់ជីវិតរបស់លោកអ្នក?

**ចំនុចគន្លឹះចំបង**

1) ព្រះនាមរបស់ទ្រង់គឺ យ៉ាវេ
2) ព្រះអង្គគឺជាព្រះអស់កល្ប គ្មានដើមដំបូង និងទីបញ្ចប់។
3) ព្រះអង្គគឺជាភាពពិតជាក់ស្តែងគង់វង្ស ទៀងត្រង់ជារៀងរហូត។ ពេលវេលាគ្មានអំណាចជះឥទ្ធិ ពលមកលើទ្រង់នោះឡើយ ហើយទ្រង់មិនមានការផ្លាស់ប្តូរភាពជាអង្គបុគ្គលរបស់ទ្រង់ សមាសភាព (ភាពជាព្រះ) និង ចរិតលក្ខណៈរបស់ទ្រង់ឡើយ។

**ព្រះពរ**

"សូមឲ្យព្រះយេហូវ៉ាប្រទានពរ ហើយរក្សាឯង  សូមឲ្យព្រះយេហូវ៉ាធ្វើឲ្យព្រះភក្ត្រទ្រង់ភ្លឺមកដល់ឯង ព្រមទាំងផ្តល់ព្រះគុណដល់ឯងផង សូមឲ្យព្រះយេហូវ៉ាងើបព្រះនេត្រទ្រង់មកចំពោះឯង ហើយប្រទានឲ្យឯងបាន សេចក្តីសុខ"

(ជនគណនា ៦:២៤-២៦)

# មេរៀនទី៤ : ព្រះអង្គគឺជាព្រះសព្វវត្តមាន (ទ្រង់មានព្រះវត្តមានគ្រប់ទីកន្លែងក្នុងពេលតែមួយ)

នៅពេលក្នុងឆ្នាំ ៩៥៧ (ម.គ.ស= មុនគ្រីស្តសករាជ) គឺជាលើកដំបូងដែលព្រះវិហាររបស់ព្រះបានសាងសង់ឡើង។ មានហ្វូងមនុស្សយ៉ាងច្រើនកុះករ មកពីគ្រប់ទីកន្លែងទូទាំងប្រទេសអ៊ីស្រាអែល ដើម្បីចូលរួមពិធីថ្វាយព្រះវិហារទៅកាន់ព្រះ។ ស្តេចសាឡូម៉ូន បានអធិស្ឋានថា "ទូលបង្គំបានស្អាងព្រះវិហារនេះថ្វាយទ្រង់គង់ ទុកជាទីលំនៅឲ្យទ្រង់គង់នៅអស់កល្បជានិច្ច"។ យ៉ាងណាមិញ សូម្បីតែនៅថ្ងៃ អប់អរសាទរយ៉ាងប្រពៃនេះ ស្តេចសាឡូម៉ូនដឹងពីដែនកំណត់នៃព្រះវិហារ ដែលទ្រង់បានស្អាង។ សូមស្តាប់ ទៅកាន់អ្វី ដែលស្តេចទ្រង់មានបន្ទូល :

> "យីអើ តើព្រះនឹងគង់លើផែនដីជាប្រាកដឬ មើល ផ្ទៃមេឃ និងអស់ទាំងជាន់នៃផ្ទៃមេឃ នោះមិនល្មម ឲ្យទ្រង់គង់ចុះទៅហើយ ចំណង់បើព្រះវិហារដែលទូលបង្គំបានស្អាងនេះ តើនឹងចង្អៀតអម្បាលម៉ាន ទៅទៀត" (១ពង្សាវតារក្សត្រ ៨:២៧)

នេះគឺជាការយល់ដឹងដំបូងអំពីព្រះសព្វវត្តមានរបស់ព្រះ : **គ្មានកន្លែងណាអាចផ្ទុកទ្រង់បានឡើយ។** គ្មានកន្លែងណាដែលអាចបង្អាក់ ឬ ឃាត់ឃាំងទ្រង់បានឡើយ។ បើកន្លែងណាមួយអាចផ្ទុកព្រះវត្តមានទាំង អស់របស់ព្រះអង្គបាន នោះមានន័យថាកន្លែងនោះមានទំហំធំជាងព្រះអង្គទៅទៀត! នោះមានន័យថា កន្លែងនោះមានទំហំធំជាងព្រះអង្គទៅទៀត! ប៉ុន្តែព្រះអង្គគឺជាព្រះដែលគ្មានអ្វីអាច ផ្ទុកព្រះអង្គបានឡើយ។ ដូចជាការដែលទ្រង់គ្មានដែនកំណត់នៅក្នុងពេលវេលា (ទ្រង់គឺជាព្រះអស់ កល្ប) ទ្រង់ក៏គ្មានដែនកំណត់ជាមួយនឹង ទីតាំងផងដែរ (ទ្រង់គឺជាព្រះសព្វវត្តមាន)

ស្តេចសាឡូម៉ូនជ្រាបថា ព្រះអង្គជាព្រះដែលមិនអាចផ្ទុកផ្តាក់នៅតែមួយកន្លែងឡើយ នៅលើផែនដីនេះ - ដូច ជាព្រះវិហារនៅយេរូសាឡិម។ ប៉ុន្តែផ្ទៃមេឃក៏មិនអាចផ្ទុកផ្តក់ទ្រង់បានដែរ។ "ផ្ទៃមេឃ" គឺជាអ្វីគ្រប់យ៉ាង ដែលខ្ពង់ខ្ពស់ជាងផែនដីទៅទៀត។ វារាប់បញ្ចូ ទាំងផ្ទៃមេឃដែលយើងមើលឃើញ កាឡាស៊ីដ៏ធំធេង ដែលឆ្ងាយលើសពីការមើលឃើញ

ហើយអាណាចក្រខាងវិញ្ញាណ ( "ស្ថានសួគ៌ដ៏ខ្ពស់បំផុត" ) ដែលខ្ពង់ខ្ពស់លើស ជាចក្រវាឡ - ជាអ្វីដែលខ្ពង់ខ្ពស់លើសជាងពេវេលា និងទីកន្លែងទៅទៀត។

ព្រះអង្គបានមានព្រះវត្តមានមុនពេល ដែលទ្រង់បានបង្កើតចក្រវាឡ។ មុនពេលដែលមានចក្រវាឡ ទ្រង់បានមានព្រះវត្តមានរួចទៅហើយ។ ដូច្នេះព្រះអង្គមានវត្តមាន នៅក្រៅចក្រវាឡ ដែលទ្រង់បានបង្កើត។ ព្រះគម្ពីរ តែងនិយាយថាព្រះអង្គគង់នៅស្ថានសួគ៌ (ឬនៅ "ស្ថានសួគ៌ដ៏ខ្ពស់បំផុត" ឬ "ខ្ពង់ខ្ពស់លើសពីផ្ទៃមេឃ ទាំងអស់" ការនេះបាននិយាយយ៉ាងច្បាស់ណា នេះមិនមែនសំដៅទៅលើផ្ទៃមេឃ ឬ ទីកន្លែងនោះទេ)។ ស្ថានសួគ៌មិនមែនជាកន្លែងណាមួយនៅក្នុងចក្រវាឡនោះទេ។ ទោះបីជាលោកអ្នកមានយានអវកាស លោកអ្នកក៏មិនអាច ធ្វើដំណើរទៅកកាន់កន្លែងនោះបានដែរ ដោយសារតែកន្លែងនោះមិនមែនជាទីកន្លែងខាងរូបកាយ ដែលទ្រង់បានបង្កើត នៅក្នុងចក្រវាឡទេ។ ដូច្នេះ ព្រះទ្រង់មានវត្តមាននៅក្រៅចក្រវាឡ ប៉ុន្តែចុះនៅក្នុង ចក្រវាឡវិញ?

តើព្រះអង្គមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងចក្រវាឡ ដែលទ្រង់បង្កើត? តើព្រះអង្គគ្មានវត្តមាននៅក្នុង ចក្រវាឡដែលទ្រង់បង្កើត ឬ យ៉ាងណា? ឧទាហរណ៍ទូទៅមួយគឺជា អ្នកផលិតនាឡិកា ដែលគាត់ផ្លិតវាហើយ ធ្វើឲ្យវាដើរហើយគាត់ក៏ចេញទៅ។ ត្រនិចនាឡិកានោះបន្តដើរទៅមុខ ទោះបីជាអ្នកផលិតនាឡិកាមិនបាន ធ្វើអ្វីសោះ។ អ្នកផលិតនាឡិកានោះអាចទៅសម្រាកនៅឆ្នេរសមុទ្រកោះកុង នៅកំឡុងពេលដែលនាឡិកានៅខេត្តកំពត ហើយបន្តមានដំណើរការ។ តើនេះគឺជាទំនាក់ទំនងរវាង ទ្រង់ និង របស់គ្រប់យ៉ាង ដែលទ្រង់បាន បង្កើតឡើងតើមែនទេ? ចូរឲ្យយើងស្តាប់ទៅកាន់អ្វី ដែលព្រះអង្គមានបន្ទូលទៅកាន់ហោរាយេរេមា។

យេរេមា ២៣:២៣-២៤

"ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលសួរថា តើអញជាព្រះដែលនៅឆ្ងាយ ឥតនៅជិតបង្កើយផងដែរឬអី ព្រះយេហូវ៉ាទ្រង់សួរដូច្នេះទៀតថា តើមានអ្នកណានឹងពួនខ្លួននៅទីសំងាត់ឯណា ឲ្យអញមើលមិនឃើញ បានឬ តើអញមិននៅពេញស្ថានសួគ៌ និងផែនដីផងទេឬអី នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា"

**ព្រះអង្គគង់នៅពេញស្ថានសួគ៌ និង ផែនដី។** នេះគឺជាគន្លឹះទីពីរក្នុងការយល់ដឹងពី ភាពសព្វវត្តមានរបស់ព្រះ។ គ្មានកន្លែងណា ដែលផ្ទុកព្រះអង្គបានឡើយ។ ទ្រង់គង់នៅពេញគ្រប់ទីកន្លែង។

ព្រះអង្គគង់នៅពេញស្ថានសួគ៌ និង ផែនដី។ ទ្រង់មានវត្តមានគង់នៅពាសពេញចក្រវាឡ ដែលទ្រង់បង្កើត។ ទ្រង់មិនមែនដូចជាអ្នកផលិតនាឡិកា ដែលទៅឈប់សម្រាកនៅកោះកុងនោះទេ។ ទ្រង់មានព្រះវត្តមានយ៉ាង សកម្មនៅក្នុងអ្វីៗដែលទ្រង់បង្កើត នៅពាសពេញគ្រប់ទីកន្លែង ហើយទ្រទ្រង់ទៅកាន់គ្រប់ទាំងអស់ គ្រប់ ពេលវេលាជារៀងរាល់ថ្ងៃ។

នៅពេលដែលព្រះបានបង្កើតចក្រវាឡ ទ្រង់បានបំពេញចក្រវាឡ ដោយព្រះវត្តមានរបស់ទ្រង់។ ព្រះអង្គមិន បានធ្វើការនេះដោយពន្លាតអង្គទ្រង់ ដើម្បីឲ្យមានផ្នែកខ្លះរបស់ទ្រង់ នៅគ្រប់ទីកន្លែងនោះទេ។ ព្រះអង្គទ្រង់ មានវត្តមានពេញលេញនៅគ្រប់ទីកន្លែងនៅក្នុងចក្រវាឡ។ ទ្រង់មានភាពពេញលេញក្នុងភាពជាព្រះរបស់ទ្រង់ នៅគ្រប់ទីកន្លែងទាំងអស់។

ចូរឲ្យយើងគិតអំពីសំនួរ ដែលយើងបានពិភាក្សាគ្នា នៅដើមដំបូងនៃមេរៀនរបស់យើង ដែលសួរថាតើវាអាច មានលក្ខណៈយ៉ាងណា ក្នុងការដែលយើងនៅកន្លែងពីរក្នុងពេលតែមួយ។ យើងមិនមែនមានន័យថា ផ្នែកនៃរាងកាយរបស់អ្នក នៅកន្លែងផ្សេងៗនោះទេ ដូចជាការ ដែលលោកអ្នកអង្គុយនៅក្នុងការិយាល័យ នៅពេលដែលជើងរបស់លោកអ្នកកំពុងសប្បាយលេងបាល់ទាត់ ឬ ទៅរាំនៅក្លឹបឡើយ។ ទេ យើងកំពុងមានន័យថា នៅកន្លែងនិមួយៗ ត្រូវមានអ្នក ១០០% នៅទី នោះ។ នៅក្នុងរបៀបដូចគ្នា ព្រះអង្គមានព្រះវត្តមាន ១០០% ក្នុងភាពជាព្រះរបស់ទ្រង់ នៅគ្រប់ផ្នែកទាំងអស់របស់ចក្រ វាឡ។

សូមស្រមៃថា រង្វង់នេះគឺជាចក្រវាឡ។ ហើយចាត់ទុកថាទំព័រនេះគឺជាព្រះ។ ពិភាក្សា តើការនេះឆ្លុះបញ្ចាំង ពីសេចក្ដីពិតណាខ្លះ? តើលោកអ្នកអាចពណ៌នាពី សព្វវត្តមានរបស់ព្រះ ដោយរបៀបណាតាមរយៈការប្រើ ឧទាហរណ៍នេះ?



មានចំនុចខុសឆ្គងមួយ ដែលយើងត្រូវជៀសវៀង។ ហើយនោះគឺជាការគិតថា ប្រសិនបើព្រះអង្គមានព្រះវត្តមាននៅគ្រប់ទីកន្លែង នោះមានន័យថាគ្រប់យ៉ាងគឺជាព្រះ។ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា **ព្រះអង្គមានវត្តមាននៅក្នុងចក្រវាឡ ហើយទ្រង់ក៏នៅក្រៅចក្រវាឡដែរ ដោយសារតែទ្រង់ដាច់ដោយឡែកពីចក្រវាឡ។** ការនេះមិនបានបង្រៀនយើងថា ចក្រវាឡគឺ ជាព្រះនោះទេ ឬ ថាចក្រវាឡគឺជាផ្នែកនៃព្រះនោះទេ។ ព្រះអង្គទ្រង់ដាច់ដោយឡែកពីចក្រវាឡ ហើយទ្រង់ មានឯករាជ្យ មិនពឹងទៅលើចក្រវាឡ ដែលទ្រង់បង្កើតឡើយ។

ចូរឲ្យយើងត្រលប់ទៅកាន់យេរេមាវិញ។ ហេតុអ្វីបានជាវាគឺជាការសំខាន់ ក្នុងការទ្រង់មានបន្ទូលប្រាប់ទៅកាន់រាស្ត្ររបស់ទ្រង់ថា ទ្រង់មិនមែនគ្រាន់តែជាព្រះ ដែលគង់នៅក្បែរ ប៉ុន្តែទ្រង់ក៏ជាព្រះដែលគង់នៅឆ្ងាយ ដែរ? នៅក្នុងជំនាន់របស់លោកយេរេមា ប្រជាជាតិដែលនៅក្នុងជុំវិញអ៊ីស្រាអែល មានជំនឿជឿលើព្រះក្លែង ក្លាយជាច្រើន។ ពួកគេជឿថាព្រះនិមួយៗ មានអំណាចបារមី ទៅលើតំបន់ដែលមាន ដែនកំណត់ តែប៉ុណ្ណោះ។ ដូច្នេះ បើសិនជាលោកអ្នកអាចធ្វើ ដំណើរឆ្ងាយគ្រប់គ្រាន់ លោកអ្នកនឹងអាចរកកន្លែង ដែលព្រះរបស់ពួកគេ មិនអាចមានវត្តមានទៅដល់បាន។ មានពួកយូដាមួយចំនួន មានការគិតមិនត្រឹមត្រូវ ដោយពួកគាត់គិតថា ព្រះអង្គមានលក្ខណៈដូច្នេះដែរ : ព្រះរបស់ពួកគេនៅតែក្នុងតំបន់របស់ពួកគេ ហើយគង់នៅតែក្បែរពួកគេ ប៉ុន្តែមិនមែនជាព្រះ ដែលគង់នៅឆ្ងាយឡើយ។ ប៉ុន្តែព្រះអង្គមិនមែន អញ្ចឹងនោះទេ។ ទ្រង់មានព្រះវត្តមាន ពាសពេញចក្រវាឡទាំងមូល។

**ព្រះអង្គជាព្រះសព្វវត្តមាន នោះមានន័យគ្មានកន្លែងណា ដែលគ្មានព្រះវត្តមានទ្រង់ឡើយ។** ចំនុចដែលទ្រង់ចង់បង្ហាញឲ្យយល់ច្បាស់នៅក្នុងគម្ពីរយេរេមា ២៣:២៣-២៤ គឺ គ្មានកន្លែងណាមួយ ជិត ឬ ឆ្ងាយ ដែលមានភាពធំធេងហួសលើសពីព្រះវត្តមានទ្រង់នោះឡើយ។ នេះមានន័យថាគ្មានអ្វី អាចមានវត្តមាននៅក្រៅពីទ្រង់បានឡើយ។

សូមស្តាប់ពីអ្វីដែលស្តេចដាវីឌបានសរសេរ :

ទំនុកតម្កើង ១៣៩:៥-១០

ទ្រង់បានព័ទ្ធទូលបង្គំជិតពីមុខពីក្រោយ

ហើយបានដាក់ព្រះហស្តលើទូលបង្គំ

ការដឹងច្បាស់យ៉ាងនេះ ក៏អស្ចារ្យហួសល្បត់ទូលបង្គំ

ហើយខ្ពស់ដល់ម្ល៉េះ បានជាទូលបង្គំ

ឈោងមិនដល់សោះ

តើទូលបង្គំនឹងទៅឯណា ឲ្យរួចពីព្រះវិញ្ញាណទ្រង់

តើនឹងរត់ទៅឯណា ឲ្យរួចពីព្រះភក្ត្រទ្រង់

ទោះបើទូលបង្គំនឹងឡើងទៅឯស្ថានសួគ៌

ក៏មានទ្រង់សណ្ឋិតនៅទីនោះ

ទោះបើទូលបង្គំនឹងរៀបដំណេកនៅស្ថានឃុំ

ព្រលឹងមនុស្សស្លាប់

នោះក៏ឃើញមានទ្រង់សណ្ឋិតនៅដែរ

ទោះបើទូលបង្គំនឹងយកស្លាបនៃបច្ចូសកាល

ហោះទៅនៅឯទីបំផុតនៃសមុទ្រ

គង់តែព្រះហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះ

ហើយព្រះហស្តស្តាំទ្រង់នឹងក្តាប់ទូលបង្គំដែរ

ស្តេចដាវីឌបានសរសេរថា គ្មានអ្វីអាចគេចចេញពីព្រះវត្តមានរបស់ព្រះបានឡើយ។ គាត់បាននិយាយពីទី តាំងប្រាំកន្លែង ដើម្បីពន្យល់យ៉ាងច្បាស់លាស់ពីការនេះ។ ចូរឲ្យលោកអ្នក គូសបន្ទាប់ពីក្រោមទីតាំង ដែលសេចក្តីដាវីឌបានលើកឡើយ នៅក្នុងអត្ថបទនេះ។

តើព្រះអង្គទ្រង់បានព័ទ្ធលោកអ្នក ហើយបានដាក់ព្រះហស្តលើអ្នកមានន័យយ៉ាងណា?

______________________________________________________________________________

តើការដែលព្រះអង្គនៅស្ថានសួគ៍មានន័យយ៉ាងណា?

______________________________________________________________________________

តើមានន័យយ៉ាងណា ដែលព្រះអង្គទ្រង់គង់នៅស្ថានឃុំព្រលឹងមនុស្សស្លាប់?

______________________________________________________________________________

តើមានន័យយ៉ាងណា ដែលព្រះអង្គគង់នៅឯទីបំផុតនៃសមុទ្រ?

______________________________________________________________________________

ស្តេចដាវីឌបានដឹងថាទោះជាកន្លែងណាក៏ដោយ ដែលគាត់ទៅ ព្រះអង្គមានព្រះវត្តមាននៅទីនោះរួចទៅ ហើយ។ ទៅលើ ឬ ក្រោម ខាងកើត ឬ លិច ស្ថានសួគ៌ ឬ ផែនដី ព្រះអង្គមានវត្តមាននៅទីនោះរួចទៅហើយ។ ប្រសិនបើ លោកអ្នកដឹងពីរឿងរបស់លោក យ៉ូណាស លោកអ្នកនឹងចងចាំ ពីការដែលគាត់ព្យាយាមរត់គេច ចេញពីព្រះ។ ប៉ុន្តែក្រោយមក គាត់បានដឹងថា វាគឺជាការដែលមិនអាចទៅរួចឡើយ។ គ្មានកន្លែងណា ដែល លោកអ្នកអាចទៅដើម្បីលាក់ខ្លួន ឬ រត់ចេញផុតពីព្រះវត្តមានរបស់ទ្រង់ ដែលទ្រង់គឺជាព្រះគង់នៅពាស ពេញស្ថានសួគ៌ និង ផែនដីឡើយ។

**ពិភាក្សា: ហេតុអ្វីបានជាវា គឺជាការដែលមិនអាចទៅរួចក្នុងការរត់ ឬ លាក់ខ្លួន ឲ្យផុតពី ព្រះវត្តមានព្រះបាន?**

**តើលោកអ្នកចង់ផ្តល់ដំបូន្មានណាខ្លះ ទៅកាន់អស់អ្នកដែលព្យាយាមធ្វើការនេះ?**

ព្រះអង្គមិនដែលអវត្តមាននៅកន្លែងណាមួយឡើយ ទោះជានៅស្ថានសួគ៌ ឬ ផែនដី។ យើងមិនត្រូវគិតថា ដោយសារតែព្រះអង្គគង់នៅលើបល្ល័ងនៅស្ថានសួគ៌ នោះមានន័យថាព្រះអង្គមិនគង់នៅទីនេះនោះទេ។ ហើយយើងក៏មិនត្រូវគិតថា ព្រះអង្គគង់នៅតែកន្លែងមួយចំនួនប៉ុណ្ណោះដែរ ឧទាហរណ៍ដូចជាកន្លែងអាគារ សាសនា ហើយទ្រង់មិនគង់នៅកន្លែងធ្វើការរបស់លោកអ្នក ឬ នៅផ្ទះរបស់លោកអ្នក ហើយនៅឯទីផ្សារ នោះឡើយ។ ព្រះអង្គមានវត្តមាននៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងចក្រវាឡ ហើយទ្រង់អាចធ្វើការបង្ហាញ ព្រះចេស្តារបស់ទ្រង់ និង ព្រះដំរិះប្រាជ្ញារបស់នៅក្នុងគ្រប់ទាំងស្ថានភាពទាំងអស់ គ្រប់ទីកន្លែង និង គ្រប់ពេលវេលា។ យើងតែងតែរនៅក្នុង ព្រះវត្តមានរបស់ព្រះ ជានិច្ច។

**ពិភាក្សា : តើមានន័យយ៉ាងសម្រាប់លោកអ្នក ដែលថាព្រះអង្គទ្រង់តែងតែរមានព្រះវត្តមានជានិច្ច?**

ចូរឲ្យយើងធ្វើការបញ្ចប់ជាមួយនឹង លទ្ធផលយ៉ាងសំខាន់ពីរ ដែលមានការទាក់ទងជាមួយនឹងសេចក្តីពិត នេះ។

ដំបូង, **ព្រះអង្គសន្យាជាមួយនឹងរាស្ត្ររបស់ទ្រង់ថា ទ្រង់តែងតែរគង់នៅជាមួយនឹងពួកគេជានិច្ច។**

> ទ្រង់មានព្រះបន្ទូលថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ» ៦ បានជាយើងរាល់គ្នាអាចនឹងនិយាយ ដោយក្លាហានថា «ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន»។ (ហេព្រើរ ១៣:៥a-៦)

ព្រះអង្គតែងតែរគង់នៅជាមួយនឹងរាស្ត្ររបស់ទ្រង់ជានិច្ច ហើយត្រៀមក្នុងជួយមកកាន់យើង។ លោកអ្នកដែលគឺជាអ្នកជឿលើទ្រង់ត្រូវដឹងថា ព្រះអង្គមានវត្តមានគង់នៅជាមួយនឹងលោកអ្នក ទ្រង់ពេញដោយអំណាចចេស្តា និងព្រះដំរិះប្រាជ្ញានៅកន្លែងណាក៏ដោយ ដែលលោកអ្នកកំពុងស្ថិតនៅ។ ទ្រង់បានសន្យាថានឹងជួយយើង។ ដូច្នេះ យើងមិនត្រូវព្យាយាម តស៊ូរស់ពីមួយថ្ងៃទៅមួយថ្ងៃ ដោយមិនអើពើទៅកាន់ព្រះវត្តមានរបស់ទ្រង់ ដោយគិតថា យើងត្រូវតែប្រើប្រាស់កម្លាំង ខ្លួនឯង ធ្វើការ

ដែលមានតែទ្រង់ទេ ដែលអាចធ្វើទៅរួច។

ចំនុចទីពីរ, **ព្រះអង្គមិនគង់នៅឆ្ងាយពីនរណាម្នាក់នោះទេ។** នៅត្រង់នេះ យើងមានសេចក្តីសន្យា សម្រាប់ពួក អ្នកមិនជឿ។

> នទ្រង់បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែ១ ឲ្យបាននៅពេញលើផែនដី ព្រមទាំងសំរេចកំណត់ ពេលវេលា ដែលបានតាំងជាមុន និងព្រំទីលំនៅរបស់គេគ្រប់គ្នា ដើម្បីឲ្យគេស្វែងរកព្រះ ក្រែងគេនឹងរកទ្រង់ ឃើញ ដោយខំរាវរកមែននោះទេដឹង ទោះបើទ្រង់មិនគង់ឆ្ងាយពីយើងនិមួយៗក៏ដោយ ដ្បិតគឺដោយសារទ្រង់ ហើយ ដែលយើងរាល់គ្នាបានរស់ កំរើក ហើយមាននៅផង ដូចជាពួកអ្នកលើកកំណាព្យខ្លះរបស់អ្នករាល់គ្នា បាននិយាយដែរថា «មនុស្សយើងជាពូជព្រះដែរ»។ (កិច្ចការ ១៧:២៦-២៨)

អ្នកមិនជឿត្រូវដឹងថា ព្រះអង្គទ្រង់គង់នៅក្បែរ ហើយពួកគេជួបជាមួយនឹងទ្រង់បាន។ ប្រសិនបើលោកអ្នក ស្វែងរកទ្រង់ ហើយចង់ជួបទ្រង់ លោកអ្នកនឹងរកទ្រង់ឃើញ ដោយព្រោះថាទ្រង់មិនគង់នៅឆ្ងាយពីយើង ម្នាក់ៗឡើយ។

**ប្រសិនបើមាននរណាម្នាក់សួរលោកអ្នកថា "តើព្រះនៅឯណា?" តើលោកអ្នកនឹងឆ្លើយថាម៉េច?**

**ចំនុចគន្លឹះចំបង**

សង្ខេប : ខាងក្រោមនេះគឺជាចំនុចគន្លឹះចំបង ដែលព្រះគម្ពីរបង្រៀនយើងអំពីព្រះអង្គគឺជាព្រះសព្វវត្តមាន

(1) គ្មានកន្លែងណា ដែលអាចផ្ទុកព្រះវត្តមានទ្រង់បានឡើយ ហើយទ្រង់មិនដែលអវត្តមាននៅកន្លែង ណាមួយឡើយ។

(2) ព្រះអង្គគង់នៅពាសពេញស្ថានសួគ៌ និង ផែនដី។

(3) ព្រះអង្គមានព្រះវត្តមានគង់នៅគ្រប់ទីកន្លែង - គ្មានកន្លែងណា ទ្រង់អវត្តមាន ហើយគ្មានកន្លែង ណាដែលមានភាពធំធេងខ្ពង់ខ្ពស់ជាងព្រះឡើយ។

**ការពិភាក្សា**

- តើលោកអ្នករៀនបានអ្វីអំពីព្រះ តាមរយៈមេរៀននៅថ្ងៃនេះ?

- តើផ្នែកណាមួយនៃ ការសព្វព្រះវត្តមានរបស់ព្រះ ដែលគួរឲ្យកត់សំគាល់មកកាន់ លោកអ្នកខ្លាំង ជាងគេ?

# មេរៀនទី៥ ព្រះអង្គគឺជាព្រះសព្វញ្ញូតញ្ញាណ (ជ្រាបគ្រប់ការទាំង អស់)

ព្រះគម្ពីរប្រាប់ និងបើកសំដែងមកកាន់យើងថា ព្រះអង្គគឺជាព្រះសព្វញ្ញូតញ្ញាណ។ ទៅក្នុងទំព័រជាច្រើននៅក្នុងព្រះគម្ពីរ យើងឃើញថាព្រះអង្គមានចំនេះដឹងឥតខ្ចោះ នៃអ្វីៗគ្រប់យ៉ាងទាំងអស់នៅក្នុងចក្រវាឡ អំពីមនុស្សគ្រប់គ្នា អំពីគ្រប់យ៉ាង នៅអតីតកាល បច្ចុប្បន្ន និង អនាគត។

**(១) ព្រះអង្គមានចំនេះដឹងយ៉ាងឥតខ្ចោះអំពីចក្រវាឡ**

> ...ព្រះទ្រង់បានបង្កើតផែនដី ដោយឫទ្ធិតេជះរបស់ទ្រង់ ទ្រង់បានតាំងលោកីយ៍ឡើង ដោយសារប្រាជ្ញា របស់ទ្រង់ ហើយបានលាតផ្ទៃមេឃ ដោយសារយោបល់។ (យេរេមា ១០:១២)

ព្រះអង្គបានបង្កើតចក្រវាឡ ដោយអំណាចចេស្តា ព្រះបញ្ញា និង ព្រះតំរិះរបស់ទ្រង់។ ក្នុងនាមទ្រង់គឺជា ព្រះអាទិករ ទ្រង់ជ្រាបដឹងគ្រប់យ៉ាងអំពីចក្រវាឡ ដែលទ្រង់បានបង្កើត។ ទ្រង់ជ្រាបដឹងទាំងអំពីទាំងការពិតយ៉ាងសំខាន់ៗ (ដូចចំនួនផ្កាយទាំងអស់) ទៅចំនុចលំអិតតូចៗ (ដូចជា ពេលដែលកូនចាបតូចមួយបានទៅលើដី)។ គ្មានអ្វីដែលតូចពេក សម្រាប់ឲ្យទ្រង់កត់សំគាល់ ហើយគ្មានអ្វី ដែលធំពេក ដែលធ្វើឲ្យទ្រង់មិនអាចយល់បានឡើយ។ ព្រះអង្គទ្រង់ជ្រាបដឹងពីគ្រប់ការទាំងអស់។ ការជ្រាបដឹងរបស់ទ្រង់គ្មានដែនកំណត់ ឡើយ។

> ទំនុកតម្កើង ១៤៧:៤-៥
>
> ទ្រង់រាប់ចំនួននៃអស់ទាំងផ្កាយ
>
> ក៏ហៅបានតាមឈ្មោះទាំងអស់
>
> ព្រះអម្ចាស់នៃយើងខ្ញុំទ្រង់ធំប្រសើរ ហើយមានឫទ្ធានុភាពក្រៃលែង

ឯប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់

ផ្កាយមានចំនួនច្រើនពេក ដែលធ្វើឲ្យយើងមិនអាចរាប់អស់បានទេ។ ប៉ុន្តែព្រះអង្គជ្រាបពីចំនួនទាំងអស់របស់ ផ្កាយ ហើយស្គាល់ឈ្មោះរបស់ផ្កាយនិមួយៗ។ តើព្រះអង្គជ្រាបដឹងពីចំនួនផ្កាយទាំងអស់ដោយរបៀបណា? តើព្រះអង្គរាប់ផ្កាយទាំងនោះឬអី? ទេ ព្រះអង្គមិនរាប់ផ្កាយទាំងនោះទេ។ មូលហេតុដែលទ្រង់ជ្រាបពីការពិត នៅក្នុងចក្រវាឡ ដោយសារតែទ្រង់ គឺជាអ្នក ដែលកំណត់ពីការពិតនៃចក្រវាឡ។ យើងដឹងថាព្រះអាទិត្យមាន ចំងាយឆ្ងាយពីផែនដី ចំនួន ១៥០ លាន គីឡូម៉ែត ដោយសារតែតារាវិទូ បានគណនាពីចំងាយនេះ។ ប៉ុន្តែ ព្រះអង្គជ្រាបដឹងថា ព្រះអាទិត្យមានចំងាយ ១៥០ លាន គីឡូម៉ែតពីផែនដី ដោយសារ តែទ្រង់ជា អ្នកដែលបានដាក់ ព្រះអាទិត្យ និង ផែនឲ្យនៅឆ្ងាយពីគ្នា! ព្រះអង្គមិនចាំបាច់ដឹងពីការពិតនៃ ចក្រវាឡ នោះទេ ទ្រង់គឺជាអ្នក ដែលកំណត់ការពិតទាំងអស់។

យ៉ូប ៣៧:១៤-១៦

“ឱយ៉ូបអើយ សូមស្តាប់សេចក្តីនេះចុះ សូមឈរឲ្យនឹង ហើយពិចារណាអស់ទាំងការអស្ចារ្យរបស់ព្រះសិន តើលោកជ្រាបពីព្រះទ្រង់ដាក់កំរិតរបស់ទាំងនោះជាយ៉ាងណា ពីទ្រង់ធ្វើឲ្យផ្លេកបន្ទោរនៃពពកទ្រង់ភ្លឺផ្លេកៗ ដូចម្តេចឬទេ តើលោកយល់ពីទំងន់នៃពពកជាយ៉ាងណា គឺជាកិច្ចការអស្ចារ្យរបស់ព្រះដ៏មានដំរិះសព្វគ្រប់ ឬទេ”

លោកយ៉ូបមិនដឹងពីរបៀប ដែលព្រះអង្គធ្វើការគ្រប់គ្រងទៅកាន់ពពក ឬ ធ្វើឲ្យមានផ្លេកបន្ទោលយ៉ាងណានោះទេ។ ទោះបីជាសព្វថ្ងៃនេះក្តី បួនពាន់ឆ្នាំក្រោយមក ពួកយើងភាគច្រើនក៏នៅតែមិនដឹង។ លោកយ៉ូបបានបន្ទាបខ្លួនគាត់ចុះ នៅពេលដែលគាត់ដឹងថាចំនេះដឹងរបស់គាត់ អំពីដំណើរការរបស់ចក្រវាឡមានកម្រិតទៀបប៉ុណ្ណា នៅពេលដែល ប្រៀបធៀបជាមួយនឹង ចំនេះដឹងរបស់ព្រះ។ វាគឺជាការពិតនៅក្រោយ រាប់ពាន់ឆ្នាំ នៃការសិក្សាស្រាវជ្រាវ មនុស្សនៅគ្រាន់តែ ស្ថិតដើមដំបូងនៃការស្រាវជ្រាវរកឃើញ “កិច្ចការអស្ចារ្យរបស់ ព្រះដ៏មាន ដំរិះសព្វគ្រប់”។

**ព្រះអង្គគឺជាព្រះសព្វញ្ញុតញាណមានន័យថា:**

- ព្រះអង្គមានព្រះដំរិះសព្វគ្រប់ នេះមានន័យទ្រង់ជ្រាបដឹងគ្រប់ការទាំងអស់។/ ព្រះដ៏មានដំរិះសព្វគ្រប់/

God has **perfect** knowledge.

- ចំនេះដឹងព្រះដំរិះរបស់ទ្រង់**គ្មានដែនកំណត់**។ / ឯប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់/

His understanding has **no limit**.

**(២) ព្រះអង្គមានចំនេះដឹងយ៉ាងឥតខ្ចោះអំពីយើង**

ព្រះអង្គជ្រាបដឹងទាំងអស់ ទៅលើអ្វីៗដែលទ្រង់បានបង្កើត នោះមានន័យថាទ្រង់មានការជ្រាបដឹងទាំង ស្រុង យ៉ាងឥតខ្ចោះអំពីយើងម្នាក់ៗ។ ព្រះអង្គជ្រាបដឹងអំពី :

- យ៉ូប ៣៤:២១ - គ្រប់________របស់យើង
- ទំនុកតម្កើង ៣៣:១៣-១៥ - គ្រប់ការដែលយើង____
- ទំនុកតម្កើង ១៣៩:១-៣ - គ្រប់ទាំង____របស់យើង
- ម៉ាថាយ ៦:៨ - អ្វីដែលយើង____
- ម៉ាថាយ ១០:២៩-៣០ - ចំនួន____ដែល____________ !

ព្រះអង្គស្គាល់យើងម្នាក់ៗ ខ្លាំងជាងយើងស្គាល់ពីខ្លួនឯងទៅទៀត! **ពិភាក្សា: តើលោកអ្នកមានអារម្មណ៍យ៉ាងចំពោះសេចក្តីពិត ដែលនិយាយថាព្រះអង្គស្គាល់ដឹងគ្រប់យ៉ាងអំពីលោកអ្នក?**

ព្រះអង្គជ្រាបដឹងពីគ្រប់កន្លែង ដែលលោកអ្នកទៅ និង គ្រប់យ៉ាង ដែលលោកអ្នកធ្វើ។ ប៉ុន្តែព្រះដំរិះរបស់ទ្រង់មានភាពអស្ចារ្យលើសពីនេះទៅទៀត។ ព្រះអង្គទ្រង់ក៏ជ្រាបដឹងពី :

- ទំនុកតម្កើង ១៣៩:៤ - អ្វីដែលនឹងយើង________ មុនពេលដែលយើង________
- ១ ពង្សាវតា ៨:៣៨-៣៩; កិច្ចការ ១:២៤ - ____របស់មនុស្សទាំងអស់
- ១ របាក្សត្រ ២៨:៩ - ចិត្ត ________ និង ____របស់យើង

ព្រះអង្គមិនមែនជ្រាបដឹងតែ ពីអ្វីដែលបានកើតឡើង ឬ ការពិតជាក់ស្តែង ដែលអាចសង្កេតនោះទេ។ ចំនេះដឹងព្រះដំរិះរបស់ទ្រង់មានភាពជ្រាលជ្រៅជាងនេះទៅទៀត។ ទ្រង់ជ្រាបដឹងពី ចិត្ត ផែនការ គំនិត របស់ មនុស្សគ្រប់គ្នា។ ទ្រង់ជ្រាបដឹងពីអ្វីដែលលោកអ្នកនឹង និយាយ និង ធ្វើ មុនពេល ដែលលោកអ្នកដឹងពីការ ទាំងនោះទៅទៀត!

**ការពិភាក្សា**

- ព្រះអង្គជ្រាបដឹងគ្រប់យ៉ាងអំពីលោកអ្នក។ តើការដឹងពីសេចក្តីពិតនេះ ការជះឥទ្ធិពលយ៉ាងណា មក កាន់របៀប ដែលលោកអ្នករស់នៅ?
- តើការនេះដឹងពីសេចក្តីពិតនេះ នឹងមានការជៈឥទ្ធិពលយ៉ាងណា មកកាន់ទំនាក់ទំនងរបស់ លោកអ្នកជាមួយ នឹងព្រះអង្គ?

**(៣) ព្រះអង្គមានព្រះដំរិះជ្រាបដឹង ទាំងស្រុងទៅកាន់ បច្ចុប្បន្ន អតីតកាល និង អនាគត ព្រះអង្គជ្រាបដឹង ពីអ្វីៗគ្រប់យ៉ាងដែលកំពុងតែកើតឡើងនៅពេលនេះ។** ព្រះអង្គជ្រាបពីគ្រប់ការទាំងអស់ ដែលកំពុងកើតឡើង នៅទូទាំងពិភពលោកនាពេលឥឡូវនេះ។ ទ្រង់ទតឃើញ ការប្រកួតបាល់ទាត់នៅលើ ឆ្នេរសមុទ្រ នៃប្រទេសប្រេស៊ីល សិស្សនិស្សិតកំពុងធ្វើការប្រលងនៅទីបហ្រ៊ិច អ្នកម្តាយកំពុងតែចំអិនអាហារ នៅប្រទេសកម្ពុជា ទ្រង់ឃើញ ការទាំងអស់នេះក្នុងពេលតែមួយ។ គ្មានអ្វីដែលអាចលាក់កំបាំងទៅកាន់ទ្រង់ ឬ គ្មានអ្វីជាអាថ៌កំបាំងចំពោះទ្រង់ ឡើយ។

សុភាសិត ៥:២១

> ពីព្រោះអស់ទាំងផ្លូវរបស់មនុស្សសុទ្ធតែច្បាស់នៅចំពោះព្រះនេត្រព្រះយេហូវ៉ា ទ្រង់ក៏ស្ទង់មើលអស់ទាំងផ្លូវច្រករបស់គេដែរ
>
> យ៉ូប ២៨:២៤
>
> ដ្បិតទ្រង់ទតមើលទៅដល់ចុងផែនដីបំផុត ក៏ឃើញទាំងអស់ដែលនៅក្រោមផ្ទៃមេឃ

នាងហាការ មានផ្ទៃពោះ។ នាងបានរត់ចេញពីផ្ទះ ហើយនៅតែម្នាក់ឯងនៅឯវាលរហោស្ថាន។ គ្មានមនុស្ស ណាដឹងថានាងនៅកន្លែងណាឡើយ។ ប៉ុន្តែព្រះអង្គជ្រាបដឹង ហើយទ្រង់បានបញ្ជូនទេវតាឲ្យមកជួបនាង។ អានអំពីអ្វីដែលបានកើតឡើងនៅក្នុង **លោកុប្បត្តិ ១៦:៧-១៣**។

សូមឲ្យយើងមើលឲ្យល្អិតល្អន់ទៅកាន់អ្វី ដែលហាការបាននិយាយនៅ ខ១៣ :

> នោះនាងក៏ហៅព្រះនាមព្រះយេហូវ៉ា ដែលកំពុងមានព្រះបន្ទូលនឹងនាងថា «ព្រះដ៏ទតឃើញ» ដ្បិតនាងគិតថា នៅទីនេះអញបានឃើញព្រះដែលទ្រង់ទតឃើញអញទេតើ

ហាការបានហៅព្រះអង្គថា **אֵל רֳאִי** (អានថា អែល រូអី) ដែលមានន័យថា “ព្រះដែលទតឃើញ” ។ នៅពេលដែលកូននាងកើតមក នាងដាក់ឲ្យកូននោះថា អ៊ីសម៉ាអែល មានន័យថា ‘ព្រះដែលស្តាប់ឮ’ ។ នៅពេលដែលមនុស្សគ្រប់គ្នាបោះបង់ចោលហាការ នាងមានការកំសាន្តនៅក្នុងចិត្ត តាមរយៈសេចក្តីពិត ដែលថា ព្រះអង្គគឺជា ព្រះដែលទតឃើញ ហើយស្តាប់ឮគ្រប់ការទាំងអស់។

ព្រះអង្គមិនគ្រាន់តែជ្រាបដឹងពីអ្វីដែលកំពុងកើតឡើងនាពេលនេះទេ **ប៉ុន្តែទ្រង់ក៏ជ្រាបដឹងពីគ្រប់ការទាំងអស់ដែលបានកើតឡើងដែរ**។ គ្មានចំនុចច្រលោះប្រហោងណាមួយ នៅក្នុងចំនេះដឹងព្រះឡើយ។ ទ្រង់ជ្រាបដឹងប្រវត្តសាស្ត្ររបស់ចក្រវាឡទាំងមូល។

ព្រះអង្គមានព្រះដំរិះជ្រាបដឹងទាំងស្រុង ទៅលើអ្វីគ្រប់យ៉ាង ដែលបានកើតឡើងនៅក្នុងអតីតកាល។ យើងបានឃើញការនេះយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរ នៅពេលដែលនរណាម្នាក់ បានធ្វើអ្វីមួយនៅក្នុងទីអាថ៌កំបាំង បន្ទាប់មកធ្វើការលាក់បាំងទៅកាន់ការនោះ។ គ្មាននរណាម្នាក់ដឹងថា ការនេះបានកើតឡើង ក្រោយមក បុគ្គលនោះ គិតថាខ្លួនមានភាពជោគជ័យក្នុងការលាក់លៀមការនេះ។ ប៉ុន្តែព្រះអង្គជ្រាបដឹងពីការនេះ។

មានឧទាហរណ៍មួយអំពីបុរសម្នាក់ ដែលមានឈ្មោះថា អេកាន បានលួចអាវមួយ ប្រាក់ មាស ហើយបានយកទៅកប់នៅកន្លែងសំងាត់។ ក្រោយមកព្រះអង្គបានបើកសំដែងទៅ រាស្ត្រអ៊ីស្រាអែលឲ្យដឹងពីការ ដែលអេកានបានធ្វើ (យ៉ូស្វេ ៧)។ ដូច្នេះយើងអាចនិយាយបានថា ព្រះអង្គបានទតឃើញពីអ្វី ដែលបានកើតឡើង ហើយទ្រង់ចងចាំការទាំងនោះ។

យ៉ាងណាមិញ នេះគ្រាន់របៀបសាមញ្ញក្នុងការគិតពី ព្រះដំរិះរបស់ព្រះតែប៉ុណ្ណោះ។ ការយល់ដឹងយ៉ាងជ្រាលជ្រៅជាងនេះទៅទៀត គឺថាព្រះអង្គមិនមែនដឹងពីការទាំងអស់ តាមរយៈការសង្កេតមើលនោះទេ។ ព្រះអង្គមិនមែនតែសិក្សាស្រាវជ្រាវអ្វីថ្មី ជារៀងរាល់ថ្ងៃ តាមរយៈការទតមើលមកកាន់អ្វីដែលយើងធ្វើជារៀងរាល់ថ្ងៃ នោះទេ។ ព្រះអង្គជ្រាបនឹងរួចទៅហើយ។ សូមចងចាំថា ព្រះអង្គជ្រាបដឹងពីគ្រប់យ៉ាង ដែលមនុស្សគ្រប់គ្នា នឹងគិតនឹកឃើញ និយាយធ្វើ *<u>មុនពេល</u>* ដែលការទាំងនោះបានកើតឡើង។ ទ្រង់មិនត្រូវការទតឃើញ ដើម្បី ឲ្យទ្រង់អាចជ្រាបដឹងនោះទេ។

របៀប ដែលទ្រង់មានការជ្រាបដឹងមានលក្ខណៈខុសពីយើង។ ចំនេះដឹងរបស់យើង គឺមានមូលដ្ឋានគ្រឹះពឹង ផ្អែកទៅលើការសង្កេតទៅលើពេលបច្ចុប្បន្ន ការចងចាំពីអតីតកាល និង ការប៉ាន់ស្មាននៃអនាគត។ ប៉ុន្តែ ចំនេះដឹងព្រះដំរិះរបស់ព្រះមិនមានលក្ខណៈដូច្នេះទេ។ ទ្រង់ជ្រាបដឹងពីគ្រប់ការទាំងអស់យ៉ាងឥតខ្ចោះ ហើយទ្រង់ជ្រាបតាំងតែពីដំបូង។

**ព្រះអង្គជ្រាបដឹងពីគ្រប់ការទាំងអស់ ដែលនឹងកើតឡើងនៅថ្ងៃអនាគត។** ព្រះអង្គមិនត្រូវការរង់ចាំមើលអ្វីដែលនឹងកើតឡើងឡើយ។ ទ្រង់ជ្រាបដឹងពីការទាំងអស់រួចទៅឡើយ។ ព្រះអង្គជ្រាបដឹងពីចុងបំផុតតាំងតែពីដើមដំបូងមកម្ល៉េះ។

អេសាយ ៤៦:៩-១០

នចូរនឹកចាំពីការដែលកន្លងទៅហើយ តាំងពីបុរាណ ដ្បិតអញនេះហើយជាព្រះ ឥតមានណាទៀតឡើយ អញជាព្រះ ហើយគ្មានអ្នកណាដូចជាអញសោះ តាំងតែពីដើមដំបូង អញរមែងសំដែងប្រាប់ពីការដែលត្រូវមក ខាងចុងបំផុត ហើយតាំងពីចាស់បុរាណក៏ប្រាប់ពីការដែលមិនទាន់មានមកដែរ

អេសាយ ៤២:៩

មើលការខាងដើមទាំងប៉ុន្មានបានកន្លងទៅ ហើយគឺជាការថ្មី ដែលអញថ្លែងប្រាប់នេះ អញប្រាប់ពីការ ទាំងនោះដល់ឯងរាល់គ្នា មុនដែលកើតមកផង។

ព្រះអង្គធ្វើការប្រកាសពីការ ដែលនឹងកើតឡើង មុនពេល ដែលការនោះកើតឡើង។ នៅពេលដែលព្រះអង្គបើកសំដែងព្រឹត្តិការណ៍ ដែលនឹងកើតឡើងនៅថ្ងៃអនាគត ទៅកាន់មនុស្ស យើងហៅការនោះថា "ទំនាយ" ។ សូមបំពេញចន្លោះខាងក្រោម ដោយប្រើប្រាស់ការប៉ាន់ស្មាន របស់លោកអ្នក ហើយប្រៀបធៀបជាមួយនឹង ដៃគូ។

- ____% នៃព្រះគម្ពីរគឺជាពាក្យទំនាយ។
- មានពាក្យទំនាយចំនួន ________ ទំនាយ។ (ចំនួនប៉ុន្មាន)
- ជាង ____% នៃពាក្យទំនាយទាំងនេះបានកើតឡើងដូចតាមការទាយទុក។ ហើយទំនាយ ដែលនៅសេសសល់គឺអំពីព្រឹត្តិការណ៍ ដែលនឹងកើតឡើងនៅចុងបំផុតនៃពិភពលោក។

ព្រះអង្គបានធ្វើការបង្ហាញពីព្រះដំរិះជ្រាបដឹងពីអនាគត តាមរយៈការសម្រេចពាក្យទំនាយ ជាង១ ពាន់ពាក្យ ទំនាយ។ ឧទាហរណ៍ ព្រះអង្គបានមានបន្ទូលទៅកាន់ពួកយូដាថា ពួកបាប៊ីឡូន ហើយចាប់យកពួកគេ នេរទេសធ្វើជាឈ្លើយសឹក រយៈពេល ៧០ឆ្នាំ ហើយក្រោយមក បាប៊ីឡូន នឹងត្រូវដួលរលំ (យេរេមា ២៥:៨០-១៣)។ ហើយនឹងមានស្តេចមួយអង្គឈ្មោះថា ស៊ីរូស (អ្នកជាម្នាក់ ដែលមិនទាន់ចាប់កំណើតផង នៅពេល ព្រះអង្គបានមានបន្ទូលពីការនេះនៅ អេសាយ

៤៤:២៤-៤៥:១) នឹងធ្វើការប្រកាសទៅកាន់ពួកគេ ពួកគេនឹងអាចត្រលប់ទៅស្រុកកំណើតខ្លួនវិញ ហើយសាងសង់ក្រុងយេរូសាឡិមឡើងវិញ (យេរេមា ២៩:១០-១៤)។ អ្វីៗគ្រប់យ៉ាង ដែលព្រះអង្គប្រកាសថានឹងកើតឡើងបានកើតឡើងត្រឹមត្រូវដូចតាម ការ ដែលព្រះអង្គមានបន្ទូលថានឹងកើតឡើង (២ របាក្សត្រ ៣៦:១៥-២៣)។

សូមឲ្យយើងធ្វើបញ្ចប់ការនេះជាមួយនឹងលទ្ធផលទាក់ទង ដែលយើងទទួលបានពី ព្រះដំរិះរបស់ព្រះ ដែលទ្រង់ជ្រាបដឹងពីគ្រប់ការទាំងអស់ ដើម្បីជួយឲ្យយើងមានការយល់ដឹងអំពីទ្រង់កាន់តែច្រើនឡើង។

ដំបូង យើងត្រូវដឹងថា ព្រះអង្គមិនដែលមានការភ្ញាក់ផ្អើលដោយសារអ្វីឡើយ។ ព្រះអង្គជ្រាបដឹងពីចុងបញ្ចប់ តាំងតែពីដំបូងមកម្ល៉េះ។ ផលប៉ះពាល់នៃការនេះគឺថា **ផែនការរបស់ព្រះ ១០០% ពិតជាកើតឡើងជាមិនខាន។** ជាធម្មតាយើងធ្វើការផ្លាស់ប្តូរផែនការ របស់យើងនៅពេលដែលយើងទទួលបានពត៌មានថ្មី។ ប៉ុន្តែ ព្រះអង្គមិនទទួលចំនេះដឹងថ្មីដែលទ្រង់មិនបានដឹងពីមុននោះទេ។ ដូច្នេះមានន័យថា ទ្រង់មិនដែលមានការផ្លាស់ផ្តូរផែនការរបស់ទ្រង់ឡើយ។ គ្រប់យ៉ាងដែលទ្រង់បានចាប់ផ្តើមឡើង ទ្រង់នឹងធ្វើការនោះឲ្យសម្រេច។ ទ្រង់បានរៀបចំផែនការរបស់ទ្រង់ ដោយចំនេះដឹងដ៏ល្អឥតខ្ចោះ នៃគ្រប់យ៉ាង ដែលមនុស្សគ្រប់គ្នាអាចគិត និយាយ និងធ្វើ។ ដូច្នេះ ប្រសិនបើព្រះអង្គ និយាយអ្វីម្យ៉ាងការនោះដឹងកើតឡើង ហើយយើងអាចប្រាកដ ក្នុងចិត្តថាវានឹងកើតឡើងជាមិនខាន។ ព្រះបន្ទូលទ្រង់ និងសេចក្តីសន្យាទ្រង់ ច្បាស់ជានឹងកើតឡើងជាមិន ខាន។

ចំនុចទីពីរ **ព្រះអង្គមានការយល់ដឹង យ៉ាងល្អបំផុត ខ្ពង់ខ្ពស់បំផុត និង ពិតបំផុតនៃអ្វីៗទាំងអស់។** ព្រះដំរិះចំនេះដឹងរបស់ទ្រង់គ្មាន ដែនកំណត់ដូចមនុស្សឡើយ។

អេសាយ ៥៥:៨-៩

"ពីព្រោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា គំនិតអញ មិនមែនដូចជាគំនិតរបស់ឯងរាល់គ្នាទេ ឯផ្លូវរបស់ឯងរាល់គ្នាក៏មិនមែនជាផ្លូវរបស់អញដែរ។ ដ្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះអស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯង ហើយគំនិតរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នាយ៉ាងនោះដែរ"

គ្រប់ទាំងគំនិតរបស់ទ្រង់ គឺកើតចេញចំនេះដឹងព្រះដំរិះដ៏ឥតខ្ចោះរបស់ទ្រង់ ប្រាជ្ញាដ៏ឥតខ្ចោះរបស់ទ្រង់ និងទស្សនៈដ៏អស់កល្បរបស់ទ្រង់។ តែគំនិតរបស់មនុស្សមានលក្ខណៈដូច្នេះនោះទេ។ គំនិតរបស់យើងគឺមានមូលដ្ឋានគ្រឹះចេញពីចំនេះដឹង មិនល្អឥតខ្ចោះរបស់យើង។ តែព្រះអង្គមានចំនេះដឹងព្រះដំរិះយ៉ាងល្អឥតខ្ចោះ ហើយយល់ដឹងអំពីគ្រប់ការទាំងអស់។ ដូច្នេះ អ្វីដែលព្រះអង្គមានបន្ទូលថាជាការពិត គឺជាការពិត។ សេចក្ដីពិតគឺជា ភាពពិតជាក់ស្តែង ដែលកើតមកពីព្រះដំរិះ និងទស្សនៈគ្មានព្រំដែនរបស់ព្រះ។ ប្រសិនបើយើងគ្រាន់តែពឹងទៅលើគំនិតរបស់យើងដើម្បីធ្វើ ការកំណត់ទៅកាន់អ្វីមួយថាជាការពិត នោះយើងពិតជាមានគំនិតខុសឆ្គង ទៅកាន់ចំនុចណាមួយជាមិនខាន។ នៅពេលដែលលោកអ្នកប្រលងសាលា តើលោក អ្នកបានពិន្ទុ ១០០% គ្រប់ពេល ដែលលោកអ្នក ប្រលងដែរឬទេ? អត់ទេ គ្មាននរណាម្នាក់បានពិន្ទុះ ១០០ រហូតនោះទេ។ ការយល់ដឹងរបស់យើង មានដែនកំណត់។ ចំនេះដឹងរបស់យើង មិនល្អឥតខ្ចោះនោះទេ។ ប៉ុន្តែព្រះអង្គជ្រាប គ្រប់ការទាំងអស់។ ដូច្នេះ ធ្វើយ៉ាង ដើម្បីឲ្យយើងអាចស្គាល់សេចក្តីពិតបាន? ចម្លើយគឺតាមរយៈការបើក សំដែងមកពីព្រះ។

យ៉ូហាន ១៧:១៧

សូមញែកគេចេញជាបរិសុទ្ធ ដោយសារសេចក្ដីពិតរបស់ទ្រង់ ឯសេចក្ដីពិត គឺជាព្រះបន្ទូលរបស់ទ្រង់

ទំនុកតម្កើង ២៥:៥

នសូមនាំ ហើយបង្រៀនទូលបង្គំ

ក្នុងសេចក្ដីពិតរបស់ទ្រង់ផង

ដ្បិតទ្រង់ជាព្រះដ៏ជួយសង្គ្រោះទូលបង្គំ

ទូលបង្គំសង្ឃឹមដល់ទ្រង់ដរាបរាល់ថ្ងៃ

យ៉ូហាន ១៦:១៣

កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុង គ្រប់ទាំងសេចក្តីពិត ដ្បិតទ្រង់នឹងមានព្រះបន្ទូល មិនមែនដោយអាងព្រះអង្គទ្រង់ទេ គឺនឹងមានព្រះបន្ទូល ចំពោះតែសេចក្តីណាដែលទ្រង់ឮ ហើយនិងសំដែង ឲ្យអ្នករាល់គ្នាដឹងការដែលត្រូវមក

យ៉ូហាន ៨:៣២

អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច

ទីពីរ **ព្រះអង្គគឺជាមគ្គុទេសក៍ដ៏ល្អបំផុតសម្រាប់ជីវិត។** សូមស្រមៃថា លោកអ្នកទៅទស្សនាប្រាសាទអង្គរវត្ត។ លោកអ្នកដឹងពីពិតខ្លះៗអំពី ប្រាសាទអង្គរវត្ត ប៉ុន្តែលោកអ្នកអាចនឹងរៀនបានពីការពិតច្រើនលើសពីនេះ ប្រសិនបើលោកអ្នកមានមគ្គុទេសក៍។ ឥឡូវចូរស្រមៃថាលោកអ្នកមានអ្នកមគ្គុទេសក៍ ដែលគាត់គឺជា ស្ថាបត្យករ បានរចនាម៉ូតរបស់ប្រាសាទអង្គរវត្ត ហើយគឺជាអ្នកមើលការខុសត្រូវទៅលើការសាងសង់ រយៈ ពេលរាប់រយសតវត្សមុន។ គាត់អាចប្រាប់លោកអ្នកអំពីហេតុការណ៍ការពិត ដែលគ្មាននរណាដឹង ក្រៅពី គាត់។ ការនេះអាចជាឯកសិទ្ធិយ៉ាងធំធេង។

ព្រះអង្គគឺជាស្ថាបត្យករនៃចក្រវាឡ។ យើងមានឯកសិទ្ធិ ដែលមានទ្រង់ជាព្រះអាទិករ ធ្វើជាមគ្គុទេសក៍ មកកាន់ជីវិតរបស់យើង! នេះគឺជាអំណោយយ៉ាងធំធេងប៉ុណ្ណា ដែលយើងមានព្រះបន្ទូលរបស់ព្រះ! តើវាគឺជាឯកសិទ្ធិ ប៉ុណ្ណាក្នុងការស្គាល់គំនិតរបស់ទ្រង់។ តាមរយៈការអានព្រះបន្ទូលរបស់ព្រះ យើងអាចស្គាល់ពី ទស្សនៈវិស័យ របស់ព្រះអំពីជីវិត។

យេរេមា ៣៣:២-៣

"ព្រះយេហូវ៉ាដែលធ្វើការទាំងនេះ គឺព្រះយេហូវ៉ាដែលជបសូនបង្កើត ដើម្បីនឹងតាំងឡើង ដែលមានព្រះនាម ជាព្រះយេហូវ៉ា ទ្រង់មានព្រះបន្ទូលថា ចូរអំពាវនាវដល់អញ នោះអញនឹងឆ្លើយតប ហើយនឹងបង្ហាញ ឲ្យឯងឃើញការយ៉ាងធំ ហើយមុតមាំ ដែលឯងមិនដឹង"

ទំនុកតម្កើង ១៣៩:១៧-១៨ក

ឱព្រះអង្គអើយ ព្រះដំរិះរបស់ទ្រង់មានដំឡៃវិសេស ដល់ទូលបង្គំណាស់ហ្ន៎ ក៏មានចំនួនច្រើនណាស់ផង បើសិនជាទូលបង្គំនឹងខំរាប់ចំនួន នោះមានច្រើនជាងគ្រាប់ខ្សាច់ទៅទៀត

**ឃ្លាដកស្រង់យ៉ាងល្បីល្បាញ :** *"ខ្ញុំចង់ស្គាល់គំនិតរបស់ព្រះ ហើយអ្វីៗផ្សេងៗទៀតគ្រាន់តែជាចំនុច លំអិត" - ដោយលោក អាល់បើត អាញស្តាញ*

**ការពិភាក្សា**

សូមមានដៃគូម្នាក់ហើយធ្វើការពិភាក្សា :

- តើលោកអ្នករៀនបានអ្វីអំពីព្រះ តាមរយៈមេរៀននៅថ្ងៃនេះ?
- តើទិដ្ឋភាពណាមួយ នៃព្រះដំរិះរបស់ព្រះ គឺជាចំនុចប្រពៃលេចធ្លោមកកាន់លោកអ្នក ខ្លាំងជាងគេ?
- តើទិដ្ឋភាពមួយនេះ នៃព្រះដំរិះរបស់ព្រះ មានលទ្ធផលប៉ះពាល់យ៉ាងណាមកកាន់ជីវិតរបស់ លោកអ្នក?

**ចំនុចគន្លិះ**

ដើម្បីធ្វើការសង្ខេប ចំនុចគន្លិះចំបង ដែលព្រះគម្ពីរបានបង្រៀនយើងអំពីព្រះដំរិះរបស់ព្រះគឺ :

1) ព្រះអង្គមានព្រះដំរិះយ៉ាងឥតខ្ចោះ ហើយការយល់ដឹងរបស់ទ្រង់គ្មានដែនកំណត់ឡើយ។
2) ព្រះអង្គជ្រាបស្គាល់គ្រប់យ៉ាងអំពីចក្រវាឡ ដែលទ្រង់បានបង្កើត។
3) ព្រះអង្គជ្រាបដឹងពីចិត្ត គំនិត ផែនការ ពាក្យសំដី ហើយសកម្មភាពរបស់មនុស្សគ្រប់គ្នា។
4) ព្រះអង្គមានចំនេះជ្រាបដឹងយ៉ាងឥតខ្ចោះអំពីគ្រប់អ្វីៗទាំងអស់ - អតីតកាល បច្ចុប្បន្ន និង អនាគត។

# មេរៀនទី ៦ : ព្រះអង្គគឺជាព្រះដ៏មានគ្រប់ព្រះចេស្ដា

ព្រះអង្គគឺជាព្រះដ៏មានគ្រប់ចេស្ដា។ នេះគឺជាសេចក្ដីពិត ដែលបានប្រកាស និង បានបើកបង្ហាញឲ្យឃើញតាំងតែពីដើមដំបូង រហូតដល់ចុងបំផុតនៃព្រះគម្ពីរ។ តើព្រះគម្ពីរមានន័យយ៉ាងណា នៅពេលដែលនិយាយថាព្រះអង្គគឺជាព្រះដែលមានគ្រប់ទាំងព្រះចេស្ដា?

### (១) ព្រះចេស្ដាទ្រង់គ្មានដែនកំណត់

ព្រះចេស្ដាទ្រង់គ្មានដែនកំណត់ឡើយ។ ដូចជាការ ដែលទ្រង់គ្មានដែនកំណត់ ក្នុងពេលវេលា (ទ្រង់ជាព្រះមានព្រះជន្មអស់កល្ប) ហើយគ្មានដែនកំណត់ជាមួយនឹងទីតាំងដែរ (ទ្រង់ជាព្រះសព្វព្រះវត្តមាន) ព្រះដំរិះរបស់ទ្រង់ក៏គ្មានដែនកំណត់ដែរ (ទ្រង់ជាព្រះសព្វញ្ញូវញាណ) ហើយព្រះចេស្ដារបស់ទ្រង់ក៏គ្មានដែនកំណត់ដែរ ទ្រង់គឺជាព្រះដ៏មានគ្រប់ព្រះចេស្ដា!

ព្រះអង្គបានបើកសំដែងអំណាចព្រះចេស្ដា ដ៏គ្មានដែនកំណត់របស់ទ្រង់ជាលើកដំបូង គឺពេលដែលទ្រង់បានបង្កើតអ្វីៗទាំងអស់។ ការនេះអាចរាប់ថាគឺជាការបង្ហាញពីអំណាចចេស្ដាយ៉ាងល្អប្រពៃបំផុត នោះគឺជា ការដែលបង្កើតអ្វីៗទាំងអស់ ឲ្យកើតចេញពីភាពទទេ។ ដើម្បីឲ្យការទាំងនេះអាចកើតឡើងបាន គឺត្រូវទាមទារឲ្យមានអំណាចចេស្ដាដ៏លើសលប់ ដែលមិនអាចយល់បាន។ យ៉ាងណាមិញ ព្រះអង្គបានធ្វើការនេះ ដោយសារ ព្រះបន្ទូលរបស់ទ្រង់។ អ្វីក៏ដោយដែលទ្រង់ចង់បង្កើតឡើង ទ្រង់បានបង្កើតវាឡើង។

លោកុប្បត្តិ ១:៣

នោះព្រះទ្រង់មានព្រះបន្ទូលថា ចូរឲ្យមានពន្លឺឡើង ដូច្នេះ ពន្លឺក៏មានឡើង។

នៅពេលដែលព្រះអង្គមានបន្ទូលថា “ចូរឲ្យមានពន្លឺឡើង” ពន្លឺក៏កើតមានឡើងក្នុងល្បឿន ៣០០០០០ គីឡូម៉ែត ក្នុងមួយវិនាទី។ នេះគឺជាល្បឿនពន្លឺ!

លោកុប្បត្តិ ១:១៦

ទ្រង់ធ្វើពន្លឺធំជា២តួ ១ដែលធំជាង នោះសំរាប់បំភ្លឺក្នុងពេលថ្ងៃ ហើយ១ដែលតូចជាងសំរាប់បំភ្លឺក្នុងពេលយប់ ក៏ធ្វើឲ្យមាន ផ្កាយទាំងប៉ុន្មានដែរ។

“ទ្រង់ធ្វើ...ឲ្យមានផ្កាយទាំងប៉ុន្មានដែរ” - ឃ្លាដ៏សាមញ្ញនេះបានពណ៌នាពីកិច្ចការ យ៉ាងអស្ចារ្យមហិមា។ តារាវិទូបានប៉ាន់ស្មានថា នៅក្នុងចក្រវាឡមានផ្កាយចំនួនជាង ១,000,000,000,000,000, 000,000,000 (a ‘septillion’ , ដប់កោដិបកោដិ)។ ចូរឲ្យយើងផ្អាកបន្តិច ហើយគិតពិចារណាអំពីព្រះអង្គ ដែលទ្រង់បានអំណាចចេស្តា មហិមាប៉ុណ្ណា ដែលទ្រង់គ្រាន់តែមានបន្ទូល ធ្វើឲ្យផ្កាយទាំងអស់មានវត្តមាន ឡើង ហើយស្គាល់ឈ្មោះរបស់ផ្កាយនិមួយ!

ទំនុកតម្កើង ៣៣:៦

ផ្ទៃមេឃបានកើតមក ដោយសារព្រះបន្ទូលព្រះយេហូវ៉ា

ហើយពួកបរិវារនៅលើនោះ បានកើតដោយសារខ្យល់ ពីព្រះឱស្ឋទ្រង់

អេសាយ ៤០:២៥-២៦

ដូច្នេះ ព្រះដ៏បរិសុទ្ធទ្រង់មានព្រះបន្ទូលថា ឯងរាល់គ្នានឹងប្រៀបផ្ទឹមអញដូចជាអ្នកណា ឲ្យអញបាន ស្មើនឹង គេនោះ ចូរងើយភ្នែកឯងមើលទៅលើ ហើយពិចារណាពីអ្នកណាដែលបានបង្កើតរបស់ទាំងនេះ ដែលនាំឲ្យ ពួកពលបរិវារចេញមកតាមចំនួនដូច្នេះ ទ្រង់ក៏ហៅរបស់ទាំងនោះតាមឈ្មោះរៀងរាល់តួ ដោយព្រះចេស្តា ដ៏ធំរបស់ទ្រង់ ហើយគ្មានណាមួយខានឡើយ ដោយព្រោះតេជានុភាពដ៏ខ្លាំងក្លាដែរ។

មនុស្សយើងគ្មាននរណាស្គាល់ឈ្មោះផ្កាយទាំងអស់នោះទេ ប៉ុន្តែយើងស្គាល់ឈ្មោះផ្កាយមួយ គឺជា ព្រះអាទិត្យ។ ព្រះអាទិត្យមានបរិមាត្រ ៤.៣ លានគីឡូម៉ែត ហើយស្នូលព្រះអាទិត្យមានសីតុណ្ហភាព ១៥លាន អង្សារសេ។ ក្នុងរយៈពេលវិនាទី ព្រះអាទិត្យអាចបញ្ចេញថាពល ច្រើនជាងថាមពលទាំងអស់ ដែល មនុស្សអាចបង្កើតបាន នៅក្នុងប្រវត្តសាស្ត្រនៃផែនដីនេះ!

យ៉ាងណាមិញ ព្រះអាទិត្យមិនមែនជាផ្កាយមួយ ដែលពិសេសនោះទេ។ មានផ្កាយជាច្រើន នៅក្នុងកាឡាស៊ី របស់យើង ដែលមានទំហំធំជាងព្រះអាទិត្យរហូតដល់ ១៥០០ ដងឯនោះ! នៅក្នុងកាឡាស៊ីរបស់យើងមាន ផ្កាយចំនួន ១០០ ពាន់លានផ្កាយ។

## (២) គ្មានអ្វីដែលពិបាកពេកសម្រាប់ទ្រង់ឡើយ

សមត្ថភាពរបស់ទ្រង់គ្មានដែនកំណត់។ ទ្រង់អាចធ្វើអ្វីក៏ដោយ ឲ្យតែទ្រង់ចង់ធ្វើ។ ទ្រង់មិនដែលបរាជ័យ ឡើយ។ គ្មានដែលអ្វីដែលទ្រង់ព្យាយាមក្នុងការធ្វើ ហើយធ្វើមិនរួច ដោយសារតែទ្រង់ខ្វះអំណាចចេស្តាឡើយ។

យេរេមា ៣២:២៧

មើល អញនេះជាព្រះយេហូវ៉ា ជាព្រះនៃគ្រប់ទាំងសាច់ តើមានការអ្វីដែលពិបាកពេកដល់អញដែរឬ

យេរេមា ៣២:១៧

ឱព្រះអម្ចាស់យេហូវ៉ាអើយ មើល ទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី ដោយសារព្រះចេស្តាដ៏ធំរបស់ទ្រង់ និងព្រះពាហុដ៏លើកសំរេច គ្មានអ្វីដែលពិបាកពេកដល់ទ្រង់ទេ

សេចក្តីពិតមួយដែលព្រះគម្ពីរបានធ្វើការបើកសំដែង គឺជាការដែលព្រះអង្គគឺជាព្រះ ដែលធ្វើការសកម្មភាព នៅក្នុងជីវិត របស់មនុស្ស។ នៅក្នុងគម្ពីរលោកុប្បត្តិ យើងបានអានពីការ ដែលទ្រង់បានជ្រើសរើសបុរសម្នាក់ ដែលមានឈ្មោះថា

អាប់រ៉ាម។ តាមរយៈលោកអាប់រ៉ាម ព្រះអង្គទ្រង់បានបង្កើតជាតិសាសន៍មួយ ដែលនឹងស្គាល់ទ្រង់។ ទ្រង់បានសន្យាទៅកាន់អាប់រ៉ាមថា គាត់នឹងមានពូជពង្សកូនចៅ ចំនួនច្រើនជាងដែលគាត់អាចរាប់បាន ហើយលោកអ្នកអាប់រ៉ាមជឿទៅលើព្រះ។

២៤ ឆ្នាំបានកន្លងផុតទៅ ហើយលោកអាប់រ៉ាមមិនបានមានកូនចៅច្រើនជាង ដែលគាត់អាចរាប់បាន។ ហើយ ជាក់ស្តែងលោកអ័ប្រាហាំ និង ប្រពន្ធរបស់គាត់ សារ៉ា គ្មានកូនសូម្បីតែមួយ។ ហើយពេលនោះ អាប់រ៉ាមមាន អាយុ ៩៩ឆ្នាំ ហើយសារ៉ាមានអាយុ ៩០ឆ្នាំ។ ដូច្នេះពួកគាត់បានចាប់ផ្តើមសង្ស័យទៅកាន់សេចក្តីសន្យា របស់ព្រះ។ ដោយពួកគាត់បានគិតប្រាកដក្នុងចិត្តថា វាជាការហួសពេលហើយសម្រាប់ឲ្យពួកគេមានកូន។ ហើយតាមធម្មតា វាកើតឡើងដូច្នេះមែន។ ប៉ុន្តែគាត់មិនបានដឹងថា គ្មានដែលពិបាកពេកសម្រាប់ព្រះឡើយ។ ដូច្នេះព្រះអង្គបានបង្ហាញអង្គទ្រង់ ទៅជួបជាមួយនឹងអាប់រ៉ាមម្តងទៀត។

> លោកុប្បត្តិ ១៧:១
>
> លុះដល់អាប់រ៉ាមអាយុ៩៩ឆ្នាំ នោះព្រះយេហូវ៉ាទ្រង់លេចមកឯ គាត់ប្រាប់ថា អញជាព្រះដ៏មានគ្រប់ព្រះចេស្តា ចូរឯងដើរនៅមុខអញ ហើយឲ្យបានគ្រប់លក្ខណ៍ចុះ។

ព្រះអង្គបានមានបន្ទូលប្រាប់ទៅកាន់ លោកអាប់រ៉ាមថា ទ្រង់គឺជា **אֵל שַׁדַּי** “អែល ស្សាដៃ” ជាឈ្មោះរបស់ ទ្រង់ ដែលមានន័យថា “ព្រះដ៏មានគ្រប់ព្រះចេស្តា” ។ នេះគឺជាសេចក្តីពិត ដែលលោកអាប់រ៉ាមត្រូវការចងចាំ ខ្លាំងជាងគេនាពេលនេះ : ព្រះអង្គគឺជាព្រះដ៏មានគ្រប់ព្រះចេស្តា។ ព្រះទ្រង់បានដូរឈ្មោះ របស់អាប់រ៉ាម ហើយទៅជា “អ័ប្រាហាំ” វិញ ដែលមានន័យថា ‘ឪពុករបស់មនុស្សជាច្រើន’ ហើយទ្រង់មានបន្ទូលថាសារ៉ា នឹងមានកូនមួយនៅឆ្នាំក្រោយ។ ទាំងលោកអ័ប្រាហាំ និង អ្នកស្រីសារ៉ាបានសើចចំអកទៅកាន់គំនិតមួយនេះ ដោយសារតែពួកយល់ឃើញថាវាគឺជាការដែលមិនអាចទៅរួច។

លោកុប្បត្តិ ១៨:១៣-១៤

តែព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលនឹងអ័ប្រាហាំថា ហេតុអ្វីបានជាសារ៉ាសើចដូច្នេះថា ដែលចាស់ប៉ុណ្ណោះ ហើយតើនឹងមានកូនដែរឬ តើមានការអ្វីដែលព្រះយេហូវ៉ាធ្វើមិនកើតដែរឬអី ដល់វេលាកំណត់ នោះអញនឹង មកឯងឯង លុះគ្រប់ខែហើយ សារ៉ានឹងបង្កើតបានកូនប្រុស១

តើមានអ្វីដែលពិបាកពេកសម្រាប់ព្រះដែរ ឬទេ? ទេ គ្មានអ្វី ដែលពិបាកពេកសម្រាប់ទ្រង់ឡើយ។ ព្រះអង្គគឺជាព្រះដែលមានព្រះចេស្ដាអាចបង្កើតចក្រវាឡ ដែលមានផ្កាយដប់កោដិបកោដិបាន វាពិតជាការយ៉ាងងាយស្រួលសម្រាប់ទ្រង់ ក្នុងការជួយឲ្យប្តីប្រពន្ធចំនាស់មួយគូអាចមានកូនបាន។ ព្រះអង្គអាចធ្វើអ្វីក៏ដោយ ឲ្យតែ ទ្រង់ចង់ធ្វើ។ ប្រសិនបើព្រះអង្គមានបន្ទូល ការណាមួយនឹងកើតឡើង វាពិតជានឹងកើតឡើងជាមិនខាន។ ហើយវានឹងកើតឡើងដោយសារអំណាចចេស្ដារបស់ទ្រង់។ មួយឆ្នាំក្រោយមកសារ៉ាក៏មានកូនមួយ ដូចជា ការដែលព្រះទ្រង់បានសន្យា។

## (៣) ព្រះអង្គមានអំណាចចេស្ដាគ្រប់គ្រង លើអ្វីៗទាំងអស់ ដែលទ្រង់បានបង្កើត

ព្រះអង្គមានចំណាចចេស្ដា ដែលគ្មានដែនកំណត់ សមត្ថភាពរបស់ទ្រង់គ្មានដែនកំណត់ ហើយភាពគ្មានដែនកំណត់របស់ទ្រង់ គឺជាការមានអំណាចនៅគ្រប់ទីកន្លែង។ ព្រះចេស្ដារបស់ទ្រង់ មានអំណាចគ្រប់ដណ្ដប់ ទៅលើគ្រប់អ្វីៗទាំងអស់ ដែលទ្រង់បានបង្កើត។ គ្មានកន្លែងណាមួយនៅចក្រវាឡ ដែលទ្រង់គ្មានអំណាច គ្រប់គ្រងទៅលើនោះឡើយ។ ព្រះគម្ពីរបានបើកបង្ហាញពីអំណាចចេស្ដារបស់ព្រះ គ្រប់ដណ្ដប់ទៅ លើអ្វីៗទាំងអស់ ក្នុងរបៀបអស្ចារ្យ និង គួរឲ្យចងចាំជាច្រើន។ ព្រះអង្គបានបញ្ជា ធ្វើឲ្យសមុទ្រពុះជាពីរ ធ្វើឲ្យដែនដីហាមាត់ ឡើង ព្រះអាទិត្យឈប់ស្ងៀម ឬ ប្រលប់ថយក្រោយ ទឹកហូរចេញពីថ្ម ភ្នំរង្គើ ភ្លើងឆេះមិនចេះអស់ មនុស្សស្លាប់ រស់ឡើងវិញ សត្វតោក្លាយជាស្លូត សត្វលាចេះនិយាយ សត្វបក្សីចេះជញ្ជូនអាហារ។ នៅពេលដែលព្រះអង្គ ធ្វើការ ទ្រង់អាចធ្វើការទាំងនោះ នៅក្នុងរបៀបដែលទ្រង់ចង់ធ្វើ។ ព្រះអង្គគឺប្រៀបដូចជាជាងស្មូន ហើយ ចក្រវាឡគឺប្រៀបដូចជាដីឥដ្ឋរបស់ទ្រង់។

នៅពេលដែលព្រះអង្គធ្វើការក្នុងរបៀបយ៉ាងវិសេសវិសាល យើងហៅការទាំងនោះថាជា "ការអស្ចារ្យ" ។ ការអស្ចារ្យបង្ហាញ ពីអំណាចចេស្ដារបស់ព្រះគ្រប់ដណ្ដប់លើ អ្វីៗគ្រប់យ៉ាងដែលទ្រង់បានបង្កើត។

តើលោកអ្នកគិតថាព្រះគម្ពីរបានកត់ត្រា ពីការអស្ចារ្យចំនួនប៉ុន្មានដង? សូមបំពេញចន្លោះខាងក្រោម ដោយប្រើប្រាស់ការប៉ាន់ស្មានរបស់លោកអ្នក។ ហើយប្រៀបធៀបជាមួយនឹងដៃគូរបស់អ្នក។

- មានការអស្ចារ្យចំនួនជាង ____ ដង ដែលបានកត់ត្រាទុកនៅក្នុងសញ្ញាចាស់។
- មានកំណត់ត្រា ពីការអស្ចារ្យចំនួន ______ ដង ដែលព្រះយេស៊ូវបានធ្វើ ដើម្បីបង្ហាញពី ព្រះចេស្តា របស់ព្រះ។
- នៅក្នុងគម្ពីរកិច្ចការ ពួកសាវ័កបានធ្វើការអស្ចារ្យចំនួន ______ ដង ដោយពឹងអាងអំណាចចេស្តា របស់ព្រះ។

ដូច្នេះមានការអស្ចារ្យជាង ________ ដង ដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ។ យ៉ាងណាមិញ មានការអស្ចារ្យច្រើនជាងនេះទៅទៀត។ អត្ថបទផ្សេងៗនៅក្នុងព្រះគម្ពីរ បានប្រាប់យើងថាមានហ្វូងមនុស្សជាច្រើន បាននាំមនុស្សដែលមានជំងឺឲ្យមកទទួលការព្យាបាល តាមរយៈអំណាចចេស្តារបស់ព្រះ។ គ្មាននរណាម្នាក់បានធ្វើ ការកត់ត្រាចំនួនមនុស្សដែលបានទទួលការអស្ចារ្យនោះទេ។

> ដែលទ្រង់ធ្វើការយ៉ាងធំ រកគិតមិនយល់ជាការយ៉ាងអស្ចារ្យឥតគណនា (យ៉ូប ៥:៩)

**<u>ការសិក្សាព្រះគម្ពីរ និក្ខមនំ</u>**

នៅពេលដែលយើងអាននៅគម្ពីរសញ្ញាចាស់ យើងឃើញថានៅក្នុងគម្ពីរសញ្ញាចាស់មានការកត់ត្រា អំពីការ ដឹកនាំ ការផ្គត់ផ្គង់ និង សេចក្តីស្មោះត្រង់របស់ព្រះទៅកាន់អ៊ីស្រាអែល ដែលជាប្រជាជាតិមួយ ដែលទ្រង់បានបង្កើតឡើងតាមរយៈពូជពង្សរបស់ លោកអ័ប្រាហាំ និង អ្នកស្រីសារ៉ា។ នៅពេលដែលពួកអ៊ីស្រាអែលបានក្លាយជាទាសករនៅក្នុងប្រទេសអេហ្ស៊ីប ព្រះអង្គរំដោះជួយសង្គ្រោះពួកគេ "ដោយព្រះហស្តដ៏មានព្រះចេស្តា និងព្រះពាហុលើកសំរេច" (ចោទិយកថា ២៦:៨)។ នៅពេលពួកអ៊ីស្រាអែលចាកចេញពីស្រុក អេហ្ស៊ីប ស្តេច ផារ៉ោនជាត្រួតត្រាប្រទេសអេហ្ស៊ីប បានព្យាយាមរារាំងពួកគេ។ អាន និក្ខមនំ ១៤:៥-៣១ ដើម្បីមើលពីការ ដែលបានកើតឡើង។

**ពិភាក្សា**

- តើព្រះអង្គធ្វើការអ្វី នៅក្នុងស្ថានភាពនេះ?
- តើនេះនេះបង្រៀនយើងអ្វីខ្លះអំពីព្រះចេស្ដារបស់ព្រះ?
- តើអ្វីជាមេរៀននៃសេចក្តីជំនឿសម្រាប់យើងនៅថ្ងៃនេះ?

## (៤) គ្មានអ្វីអាចយកឈ្នះទៅព្រះចេស្ដារបស់ព្រះបានឡើយ

សូមស្តាប់ទៅកាន់ពាក្យរបស់លោក ម៉ូសេមុនពេល ដែលព្រះបានញែកសមុទ្រក្រហម :

> “តែម៉ូសេតប ឆ្លើយថា កុំខ្លាចអី ឈប់សិន ចាំមើលសេចក្តីសង្គ្រោះរបស់ព្រះយេហូវ៉ា ដែលទ្រង់នឹងប្រោសដល់អ្នករាល់គ្នា នៅថ្ងៃនេះ ដ្បិតពួកសាសន៍អេស៊ីព្ទដែលអ្នករាល់គ្នាឃើញនៅថ្ងៃនេះ នោះនឹងលែងឃើញទៀតជាដរាបទៅ ព្រះយេហូវ៉ាទ្រង់ នឹងច្បាំងជំនួសអ្នករាល់គ្នា ឯអ្នករាល់គ្នានឹងនៅតែស្ងៀមវិញ។” (និក្ខមនំ ១៤:១៣-១៤)

ព្រះអង្គច្បាំងជំនួសរាស្ត្ររបស់ទ្រង់។ អ៊ីស្រាអែលមានបទពិសោធន៍ជាមួយនឹងសេចក្តីពិតនេះ ម្ដងហើយម្ដងទៀត នៅពេលដែលពួកគេបានចូលទៅក្នុងទឹកដីសន្យា ដែលព្រះបានសន្យាថានឹងប្រគល់ឲ្យពួកគេ។ សេចក្តី ពិតនេះដឹកនាំឲ្យមានយុទ្ធសាស្ត្រកងទ័ព ដែលមិនធម្មតា។ ទីក្រុងទីមួយ ដែលពួកគេបានជួបប្រទះគឺជា ក្រុងយេរីខូរ គឺជាទីក្រុង មានការពារដោយកំផែងយ៉ាងធំ។ ជំនួសឲ្យការទៅតតាំង ព្រះបានបង្គាប់បញ្ជាពួក អ៊ីស្រាអែល ឲ្យដើរដង្ហែជុំវិញ ខាងក្រៅទីក្រុង ១ ជុំមួយថ្ងៃ ហើយធ្វើការនេះរយៈពេល ៦ថ្ងៃ។ ហើយនៅថ្ងៃទី ៧ ព្រះអង្គបានមានបន្ទូល ឲ្យដើរដង្ហែជុំវិញខាងក្រៅទីក្រុងចំនួន ៧ដង។ មិនទាន់ចាប់ផ្តើមការប្រយុទ្ធផង ពួកគេប្រហែល ជាមានការនឿយហត់យ៉ាងខ្លាំងរួចទៅហើយ! ប៉ុន្តែនៅពេលដែលពួកគេបានធ្វើតាមការ ដែល ព្រះអង្គបង្គាប់ទៅកាន់ពួកគេ នោះកំផែងក្រុងនេះបានរលំដួល ហើយពួកអ៊ីស្រាអែល

បានចាប់យកទីក្រុង នោះ។ រាស្ត្ររបស់ព្រះចាប់ផ្ដើមរៀនបានថា នៅពេលដែលពួកគេធ្វើតាមការ ដែលព្រះអង្គបានត្រាស់ហៅ ឲ្យ ពួកគេធ្វើនោះ "ចម្បាំងស្រេចនៅព្រះយេហូវ៉ា" ។

**<u>ការសិក្សាព្រះគម្ពីរ : ព្រះអង្គច្បាំងជំនួសរាស្ត្ររបស់ទ្រង់</u>**

នៅគ្រានោះ លោកយ៉ូស្វេ គឺជាអ្នកដឹកនាំរបស់រាស្ត្រអ៊ីស្រាអែល។ សាសន៍គីបៀនគឺជាបាវបម្រើរបស់ពួក អ៊ីស្រាអែល។ អាន យ៉ូស្វេ ១០:៥-១៤ ដើម្បីមើលពីព្រឹត្តិការណ៍ ដែលបានកើតឡើងនៅពេលដែល ស្ដេចប្រាំ អង្គច្បាំងជាមួយនឹងសាសន៍គីបៀន។

**ពិភាក្សា**

- តើព្រះអង្គធ្វើអ្វី នៅក្នុងស្ថានភាពនេះ?
- តើការនេះបង្រៀនយើងអ្វីខ្លះអំពីព្រះចេស្ដារបស់ព្រះ?
- តើអ្វីគឺជាមេរៀននៃសេចក្ដីជំនឿសម្រាប់យើងនៅថ្ងៃនេះ?

ព្រះចេស្ដារបស់ព្រះមានគោលបំណង។ ដោយសារទ្រង់មានឫទ្ធានុភាពខ្លាំងក្លាបំផុត ទ្រង់អាចសម្រេច គោលបំណងរបស់ទ្រង់ ហើយធ្វើអ្វីទាំងអស់ដែលទ្រង់សម្រេចព្រះហឫទ័យនឹងធ្វើ។ គ្មានអំណាចណាអាច ប្រឆាំងនឹងព្រះបានដោយជោគជ័យឡើយ។

> ២ របាក្សត្រ ២០:៦
>
> "ឱព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោយើងខ្ញុំរាល់គ្នាអើយ តើទ្រង់មិនមែនជាព្រះនៅស្ថានសួគ៌ទេឬអី តើទ្រង់មិនគ្រប់គ្រងលើអស់ទាំងនគររបស់សាសន៍ដទៃទេឬអី ហើយនៅព្រះហស្តទ្រង់ នោះក៏មានព្រះចេស្ដា និងឥទ្ធិឫទ្ធិដែរ ដល់ម្ល៉េះបានជាគ្មានអ្នកណាអាចនឹងទប់ទល់នឹងទ្រង់បានឡើយ"។

ទំនុកតម្កើង ៧៧:១១-១៤

ទូលបង្គំនឹងរឭកពីអស់ទាំងការនៃព្រះយេហូវ៉ា

ដ្បិតទូលបង្គំនឹកឃើញអស់ទាំងការអស្ចារ្យ

ដែលទ្រង់បានធ្វើកាលពីដើម

ទូលបង្គំនឹងរំពឹងគិតពីគ្រប់ទាំងការរបស់ទ្រង់

ហើយពិចារណាពីកិច្ចដែលទ្រង់ធ្វើទាំងប៉ុន្មាន

ឱព្រះអង្គអើយ ផ្លូវទ្រង់ជាផ្លូវបរិសុទ្ធ

តើមានព្រះឯណាដែលធំដូចជាទ្រង់

ទ្រង់ជាព្រះដែលធ្វើការយ៉ាងអស្ចារ្យ

ទ្រង់បានសំដែងឲ្យស្គាល់ឥទ្ធានុភាពនៃទ្រង់

នៅកណ្តាលអស់ទាំងសាសន៍

**ប្រសិនបើលោកអ្នកមានបទពិសោធន៍ (ទីបន្ទាល់) ជាមួយនឹងព្រះចេស្តារបស់ព្រះ នៅក្នុងជីវិតលោកអ្នក សូមចែកចាយឥឡូវនេះដើម្បី លើកទឹកចិត្តទៅកាន់មិត្តរួមថ្នាក់។**

**ពិភាក្សា**

ជាមួយនឹងដៃគូ សូមពិភាក្សាសំនួរខាងក្រោម។

- តើលោកអ្នករៀនបានអ្វីខ្លះអំពីព្រះ តាមរយៈមេរៀនថ្ងៃនេះ?
- តើចំនេះដឹង ដែលលោកអ្នកដឹងថាព្រះគឺជាព្រះដ៏មានគ្រប់ព្រះចេស្តា ជះឥទ្ធិពលយ៉ាងណាមកកាន់ជីវិតរបស់លោកអ្នក?
- តើមានផ្នែកណាមួយនៃជីវិតរបស់លោកអ្នក ដែលលោកអ្នកគិតថាព្រះមិនអាចធ្វើការបានទេ? តើមានបញ្ហាណាមួយ ដែលលោកអ្នកគិតថាពិបាកពេកសម្រាប់ព្រះដែរ ឬទេ? សូមអធិស្ឋានសម្រាប់ការទាំងនេះជាមួយគ្នា។

**ចំនុចគន្លឹះ**

ការសង្ខេប ចំនុចគន្លឹះដែលព្រះគម្ពីរបង្រៀនអំពីគ្រប់ព្រះចេស្តារបស់ព្រះគឺ :

1) ព្រះចេស្តារបស់ព្រះគ្មានដែនកំណត់

2) គ្មានអ្វីដែលពិបាកពេកសម្រាប់ព្រះឡើយ។ ទ្រង់មានសមត្ថភាព ដែលគ្មានដែនកំណត់។

3) ព្រះចេស្តារបស់ទ្រង់គ្របដណ្តប់គ្រប់ទីកន្លែង គឺលើគ្រប់របស់សព្វសារពើរ។

4) គ្មានអ្វីអាចទាស់ប្រឆាំង យកឈ្នះ ទៅកាន់ព្រះចេស្តារបស់ព្រះបានឡើយ។

**បញ្ចប់ដោយការអធិស្ឋាន**

សូមឲ្យកិច្ចការរបស់ទ្រង់សំដែងមកច្បាស់ ដល់ពួកអ្នកបំរើទ្រង់

ហើយឲ្យឃើញសិរីល្អនៃទ្រង់ស្ថិតលើកូនចៅគេផង

សូមឲ្យព្រះគុណនៃព្រះយេហូវ៉ា ជាព្រះនៃយើងខ្ញុំ

បានសណ្ឋិតលើយើងខ្ញុំ ហើយតាំងការនៃដៃយើងខ្ញុំ ឲ្យខ្ជាប់ខ្ជួនឡើង

អើ សូមតាំងការនៃដៃយើងខ្ញុំឲ្យស្ថិតស្ថេរចុះ។ (ទំនុកតម្កើង ៩០:១៦-១៧)

# មេរៀនទី ៧: ព្រះអង្គទ្រង់សោយរាជ្យលើគ្រប់ទាំងអស់

ព្រះគម្ពីរបើកសំដែងថាព្រះទ្រង់សោយរាជ្យលើគ្រប់ទាំងអស់។

ទំនុក ៩៧:១

ព្រះយេហូវ៉ាទ្រង់គ្រប់គ្រង

គួរឲ្យផែនដីអរសប្បាយឡើង

គួរឲ្យពួកកោះដ៏មានជាច្រើន មានសេចក្តីអំណរដែរ

១របាក្សត្រ ១៦:៣១

ចូរឲ្យផ្ទៃមេឃមានសេចក្តីអំណរ

ហើយឲ្យផែនដីបានត្រេកអរឡើង

ឲ្យបានថ្លែងនៅគ្រប់ទាំងសាសន៍ថា

ព្រះយេហូវ៉ាទ្រង់សោយរាជ្យ

តើព្រះអង្គសោយរាជ្យទៅលើអ្វីខ្លះ? សូមអានខគម្ពីរខាងក្រោមនេះ ហើយស្វែងរកចម្លើយ។

ទំនុកតម្កើង ៤៧:៧-៨

ដ្បិតព្រះទ្រង់ជាមហាក្សត្រលើផែនដីទាំងមូល

ចូរច្រៀងសរសើរយ៉ាងពីរោះចុះ។

ព្រះទ្រង់គ្រប់គ្រងលើអស់ទាំងសាសន៍

ព្រះទ្រង់គង់លើបល្ល័ង្កបរិសុទ្ធនៃទ្រង់

ទំនុកតម្កើង ១០៣:១៩

ព្រះយេហូវ៉ាទ្រង់បានតាំងបល្ល័ង្កទ្រង់នៅលើស្ថានសួគ៌

ហើយរាជ្យទ្រង់ក៏គ្រប់គ្រងលើទាំងអស់

ព្រះអង្គសោយរាជ្យលើផែនដីទាំងមូល លើគ្រប់ជាតិសាសន៍ លើគ្រប់ទាំងអស់។ ព្រះអង្គគឺជាស្តេចលើគ្រប់ ជាតិសាសន៍។

ទំនុកតម្កើង ២២:២៧-២៨

គ្រប់ទាំងទីបំផុតនៃផែនដី នឹងនឹកដល់ព្រះយេហូវ៉ា

ហើយត្រឡប់បែរមកឯទ្រង់

អស់ទាំងពូជពង្សនៃនគរទាំងឡាយ

នឹងថ្វាយបង្គំនៅចំពោះទ្រង់

ដ្បិតអំណាចគ្រប់គ្រងជារបស់ផងព្រះយេហូវ៉ា

ទ្រង់ជាចៅហ្វាយលើអស់ទាំងនគរ

យេរេមា ១០:៦-៧

ឱព្រះយេហូវ៉ាអើយ គ្មានណាឲ្យដូចទ្រង់ឡើយទ្រង់

ធំប្រសើរ ហើយព្រះនាមទ្រង់ក៏មានឥទ្ធានុភាព

យ៉ាងខ្លាំងដែរ ឱមហាក្សត្រនៃអស់ទាំងសាសន៍ អើយ

តើមានអ្នកឯណាដែលមិនត្រូវកោតខ្លាច ដល់ព្រះយេហូវ៉ា

ដ្បិតសេចក្តីកោតខ្លាចសំណាំតែ នឹងទ្រង់ប៉ុណ្ណោះ

ពីព្រោះក្នុងបណ្តាមនុស្សប្រាជ្ញា

ទាំងឡាយនៅគ្រប់ទាំងសាសន៍ ហើយក្នុងនគរ

របស់គេទាំងប៉ុន្មាន នោះគ្មានអ្នកណាមួយឲ្យដូច

ទ្រង់ឡើយ

ប្រទេសជាច្រើនមានស្តេចគ្រប់គ្រង ប៉ុន្តែព្រះអង្គគឺជាស្តេចលើអស់ទាំងស្តេច។

១ធីម៉ូថេ ៦:១៥b

ស្តេចចក្រតែ១ព្រះអង្គដ៏មានពរ ជាស្តេចលើអស់ទាំងស្តេច ហើយជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់

ព្រះអង្គគឺជាព្រះសោយរាជ្យលើគ្រប់ទាំងអស់ នេះមានន័យថាទ្រង់មានសិទ្ធិអំណាចកំពូល ខ្ពង់ខ្ពស់ លើគ្រប់ សិទ្ធិអំណាចទាំងអស់។ ព្រះអង្គសោយរាជ្យលើចក្រវាឡទាំងមូល ហើយទៅលើគ្រប់យ៉ាងដែលកើតឡើង ដែលកើតឡើងនៅក្នុងចក្រវាឡ។

ចូរឲ្យយើងសិក្សាអំពីរឿងរបស់ស្តេចដ៏មានអំណាចមួយអង្គ ដែលទ្រង់បានរៀនពីមេរៀនយ៉ាងមានតម្លៃ។

<u>ការសិក្សាព្រះគម្ពីរ : ស្ដេចនេប៊ូក្នេសា</u>

នេប៊ូក្នេសាគឺជាស្ដេចរបស់អាណាចក្របាប៊ីឡូន នៅក្នុងពេលដែលអាណាចក្រនេះ គឺជាអាណាចក្រដែលមានអំណាចខ្លាំងជាងគេនៅលើពិភពលោក។ បាប៊ីឡូនគឺជាទីក្រុងធំជាងគេនៅពេលនោះ ហើយនៅក្នុងទីក្រុង នេះនេប៊ូក្នេសាសោយរាជ្យទៅលើអាណាចក្រ ដែលមានទំហំ ៥០០,០០០ គីឡូម៉ែតការេ (ធំជាងប្រទេសកម្ពុជា ជិត៣ ដង)។

- **សូមអាន ដានីយ៉ែល ៤:២៨-៣៧**

1. តើស្ដេចនេប៊ូក្នេសា បាននិយាយអ្វីនៅដើមដំបូងនៃរឿងនេះ? ហេតុអ្វីបានជា លោកអ្នកគិតថាគាត់ និយាយដូច្នេះ?

   ______________________________________________________________________

   ______________________________________________________________________

   __________

2. នៅក្នុងការអួតអាងរបស់ទ្រង់ ទ្រង់បរាជ័យក្នុងការទទួលស្គាល់ថា នរណាគឺជាស្ដេចយ៉ាងពិតប្រាកដ - នោះគឺជាព្រះ។ តើព្រះអង្គឆ្លើយតបទៅកាន់ការនេះ ដោយរបៀបណា? ហេតុអ្វី?

   ______________________________________________________________________

   ______________________________________________________________________

   __________

3. តើស្ដេចនេប៊ូក្នេសារៀនបានអ្វីខ្លះ ដោយសារការនេះ?

   ______________________________________________________________________

___________________________________________________________________________

__________

***ពិភាក្សា : តើលោកអ្នករៀនបានអ្វីតាមរយៈរឿងនេះ?***

ដានីយ៉ែល ៤:៣៤-៣៥ គឺជាខគន្លឹះក្នុងការយល់ដឹងពី អំណាចគ្រប់គ្រងលើទាំងអស់របស់ព្រះ។ សូមចំណាយពេលខ្លះក្នុងការអានខគម្ពីរទាំងអស់នេះ ពួៗ ដើម្បីស្ដាប់ឮពីការដែល ស្ដេចនេប៊ូក្នេសា បានយល់ដឹងស្គាល់ ពីព្រះ។

ខគម្ពីរទាំងនេះ ប្រាប់យើងពីសេចក្ដីពិតចំបង ៣ អំពីអំណាចគ្រប់គ្រងលើទាំងអស់របស់ព្រះ។

**(១) អំណាចគ្រប់គ្រងរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ហើយរាជ្យទ្រង់ក៏នៅអស់ទាំងដំណមនុស្សតរៀងទៅ**

ព្រះអង្គមានអំណាចគ្រប់គ្រងលើទាំងអស់ នេះមានន័យថាទ្រង់គ្រប់គ្រង់លើទាំងអស់ ទាំងនៅស្ថានសួគ៌ និង ផែនដី។ ព្រះអង្គគឺជាស្ដេចដ៏គង់នៅអស់កល្បជានិច្ច។ ទ្រង់សោយរាជ្យតាំងតែមុន អ្វីៗទាំងអស់ចាប់កំណើត ឡើង ទ្រង់កំពុងសោយរាជ្យនាពេលបច្ចុប្បន្ននេះ ហើយទ្រង់នឹងសោយរាជ្យជារៀងរហូតតទៅ។

ទំនុកតម្កើង ១៤៥:១៣a

រាជ្យទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ច

ហើយអំណាចទ្រង់ក៏នៅ ដរាបដល់អស់ទាំងដំណតទៅ

បរិទេវ ៥:១៩

ឱព្រះយេហូវ៉ាអើយ ទ្រង់គង់នៅអស់កល្បជានិច្ច

រាជ្យទ្រង់ក៏ស្ថិតស្ថេរនៅដល់អស់ទាំងដំណមនុស្សតរៀងទៅ

ទំនុកតម្កើង ៤៥:៦

ឱព្រះអង្គអើយ បល្ល័ង្កទ្រង់ស្ថិតស្ថេរនៅអស់កល្ប

ជានិច្ចរៀងរាបតទៅ ឯព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត

រាជ្យរបស់ទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ច។ អាណាចក្របាប៊ីឡូន ត្រូវបានបំផ្លាញ និងបោះបង់ចោលអស់ រយៈកាលជាយូរមកហើយ។ សព្វថ្ងៃនេះវាគ្រាន់តែជាកន្លែង បោះបង់ចោលតែប៉ុណ្ណោះ។ គ្រប់ទាំងនគរ និងស្ដេចរបស់មនុស្សនឹងកន្លងបាត់ទៅ តែព្រះអង្គទ្រង់សោយរាជ្យជារៀងរហូតតទៅ។ ទោះបីជា បន្ទាប់ពីផែនដី នេះបានកន្លងផុតទៅ នគររបស់ព្រះនឹងស្ថិតស្ថេរនៅអស់កល្បជានិច្ច។

**ពិភាក្សា : តើការដែលដឹងថានគររបស់ព្រះ គង់នៅស្ថិតស្ថេរ អស់កល្បជានិច្ច មានសារៈសំខាន់ យ៉ាងណាមកកាន់ជីវិតយើង? តើការដឹងពីការនេះជះឥទ្ធិពលយ៉ាងណាមកការរស់នៅរបស់យើង?**

**(២) ព្រះអង្គធ្វើការទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់**

ព្រះអង្គមានផែនការ និង គោលបំណងអស់កល្បជានិច្ច ដែលទ្រង់ធ្វើគ្រប់ការទាំងអស់ឲ្យស្របតាមការទាំង នោះ។ នេះគឺជាការ ដែលយើងហៅថា "បំណងព្រះហឫទ័យរបស់ព្រះ" ។ តើគម្ពីរ រ៉ូម ១២:២ ប្រាប់អ្វីមកកាន់យើងអំពីបំណងព្រះហឫទ័យរបស់ព្រះ?

**បំណងព្រះហឫទ័យនៃព្រះ ដែល ___ ________ ហើយ________**

ព្រះអង្គមានអំណាចគ្រប់គ្រងទៅលើទាំងអស់ មានន័យថា ទ្រង់អាចធ្វើគ្រប់ការទាំងអស់ ដែលទ្រង់ចង់ធ្វើ ដោយគ្មានដែនកំណត់ឡើយ។ ទ្រង់មានអំណាច សិទ្ធិអំណាច និង សិទ្ធិក្នុងការធ្វើអ្វីក៏ដោយ ដែលទ្រង់ចង់ធ្វើ។ ទ្រង់អាចជ្រើសរើសធ្វើអ្វីក៏បាន ស្រេចតែបំណងព្រះហឫទ័យរបស់ទ្រង់ ទាំងនៅស្ថានសួគ៌ និង នៅលើ ផែនដី។

ទំនុកតម្កើង ១១៥:៣

ចំណែកព្រះនៃយើងខ្ញុំ ទ្រង់គង់នៅស្ថានសួគ៌ ទ្រង់បានធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ហើយ

ទំនុកតម្កើង ១៣៥:៦

ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើ នោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅផែនដី នៅក្នុងសមុទ្រ ហើយនៅទីជំរៅទាំងប៉ុន្មានផង

បើសិនមនុស្សយើងណាម្នាក់អាចធ្វើអ្វីក៏បាន ស្រេចតែចិត្ត យើងនឹងធ្វើអ្វីដែលមានភាពអាត្មានិយម ហើយល្ងីល្ងើ។ ប៉ុន្តែដោយសារតែទ្រង់ គឺជាព្រះដ៏ល្អឥតខ្ចោះ ទ្រង់គាប់ព្រះហឫទ័យធ្វើតែការល្អ។ ទ្រង់មានព្រះទ័យ រីករាយក្នុងការបង្ហាញសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេរ យុត្តិធម៌ និង សេចក្តីសុចរិតនៅលើផែនដី។

យេរេមា ៩:២៣-២៤

ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលដូច្នេះថា កុំបីឲ្យអ្នកប្រាជ្ញអួតពីប្រាជ្ញារបស់ខ្លួនឡើយ ក៏កុំឲ្យមនុស្សខ្លាំងពូកែអួតពីកំឡាំងខ្លួន ឬអ្នកមាន អួតពីទ្រព្យសម្បត្តិរបស់ខ្លួនដែរ ឯអ្នកដែលអួត នោះត្រូវឲ្យអួតតែពីសេចក្តី នេះវិញ គឺថាខ្លួនមានយោបល់ ហើយក៏ស្គាល់ដល់អញថា អញជាព្រះយេហូវ៉ាដែលប្រោសផ្សាយសេចក្តី សប្បុរស សេចក្តីយុត្តិធម៌ និងសេចក្តីសុចរិតនៅផែនដី ដ្បិតអញរីករាយចិត្តចំពោះសេចក្តីទាំងនោះហើយ នេះជា ព្រះបន្ទូលនៃព្រះយេហូវ៉ា។

ព្រះអង្គគឺជាព្រះ ដែលមានអំណាចគ្រប់គ្រងលើទាំងអស់ គឺជាសេចក្តីពិតយ៉ាងអស្ចារ្យ សម្រាប់អស់អ្នកដែល ស្គាល់ និង យល់ពីព្រះ។ នេះគឺជាការដែលមានសន្តិភាពដ៏ធំធេង នៅក្នុងចិត្ត ក្នុងការដឹងថាចក្រវាឡនេះនៅ ក្រោមអំណាចគ្រប់គ្រងរបស់ព្រះ ដែលពោរពេញដោយសេចក្តីស្រលាញ់ យុត្តិធម៌ សុចរិត ជាព្រះដែលធ្វើ គ្រប់យ៉ាងទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ព្រះអង្គសោយរាជ្យលើគ្រប់ទាំងអស់នៅលើផែនដី មានន័យថា ជីវិតមិនមែនកើតឡើងដោយចៃដន្យនោះទេ។ ផ្ទុយទៅវិញ ព្រះអង្គកំពុងធ្វើការយ៉ាងសកម្មភាពក្នុង ការសម្រេចបំណង ព្រះទ័យរបស់ទ្រង់ ដែលការទាំងនោះនឹងកើតឡើងជាដាច់ខាត។

អេសាយ ៤៦:៩-១១

ចូរនឹកចាំពីការដែលកន្លងទៅហើយ តាំងពីបុរាណ ដ្បិតអញនេះហើយជាព្រះ ឥតមានណាទៀតឡើយ អញជាព្រះ ហើយគ្មានអ្នកណាដូចជាអញសោះ តាំងតែពីដើមដំបូង អញរមែងសំដែងប្រាប់ពីការដែល ត្រូវមក ខាងចុងបំផុត ហើយតាំងពីចាស់បុរាណក៏ប្រាប់ពីការដែលមិនទាន់មានមកដែរ ដោយពាក្យថា គំនិត សំរេចរបស់អញនឹង ស្ថិតស្ថេរនៅ អញនឹងធ្វើតាមបំណងចិត្តអញគ្រប់ប្រការ អញបានហៅតន្ត្រី១ មកពីទិស ខាងកើត ជាមនុស្ស ដែលនឹងសំរេចតាមគំនិតរបស់អញ ឲ្យមកពីស្រុកឆ្ងាយ អើ អញបានចេញវាចាហើយ អញនឹងធ្វើឲ្យករនោះ កើតឡើងផង អញបានគិតសំរេចស្រេចហើយ អញនឹងធ្វើការនោះឯង។

អេសាយ ៥៥:១១

នោះពាក្យអញ ដែលចេញពីមាត់អញទៅ ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាងដូច្នោះដែរ គឺនឹង ធ្វើសំរេចតាមសេចក្ដីប៉ងប្រាថ្នានៅក្នុងចិត្តអញ ហើយនឹងចំរើនកើនឡើង ក្នុងការអ្វី ដែលអញចាត់ ទៅធ្វើនោះ

***ពិភាក្សា : សូមចែកចាយពីបំណងព្រះហឫទ័យខ្លះៗ ដែលទ្រង់មានសម្រាប់រាស្ត្ររបស់ទ្រង់។***

**(៣) "ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់បានឡើយ"**

ព្រះអង្គសោយរាជ្យលើគ្រប់ទាំងអស់មានន័យថា គ្មានអ្វីអាចរាំងមិនឲ្យទ្រង់អាចសម្រេចទៅតាមបំណង ព្រះហឫទ័យរបស់ទ្រង់បានឡើយ។ នៅពេល ដែលព្រះគម្ពីរនិយាយពី "ព្រះហស្ត" របស់ព្រះ ព្រះគម្ពីរកំពុង និយាយសំដៅទៅលើសិទ្ធិអំណាច និង ព្រះចេស្ដារបស់ព្រះ។ ដូច្នេះការដែលនិយាយថា "ឥតមានអ្នកណា អាចឃាតត់ព្រះហស្តទ្រង់បាន" ការនេះមានន័យថា គ្មាននរណាម្នាក់ អាចបញ្ឈប់ មិនឲ្យព្រះអង្គធ្វើអ្វី ដែល ទ្រង់បានសម្រេចព្រះហឫទ័យក្នុងការធ្វើបានឡើយ។

អេសាយ ១៤:២៦-២៧

នោះហើយជាការ ដែលបានសំរេចនឹងធ្វើ នៅលើផែនដីទាំងមូល ហើយនេះជាព្រះហស្ត ដែលបានសន្ធឹងទៅលើនគរទាំងពួង ដ្បិតព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានសំរេចនឹងធ្វើហើយ តើអ្នកណានឹងរំលប់រំលាងបាន ព្រះហស្តនៃទ្រង់បានលូកទៅហើយ តើអ្នកណានឹងបង្វិលឲ្យត្រឡប់ទៅវិញបាន។

អេសាយ ៤៣:១៣

អើ ចាប់តាំងពីមានពេលថ្ងៃឡើងវេលាណា នោះគឺជាអញនេះហើយ ឥតមានអ្នកណាអាចនឹងដោះឲ្យរួចពីដៃអញបានទេ ឯការដែលអញធ្វើ តើអ្នកណានឹងឃាត់បាន។

ព្រះអង្គសោយរាជ្យលើគ្រប់ទាំងអស់ មានន័យថាគ្មាននរណាម្នាក់ គ្មានអ្វីមួយ អាចរារាំងព្រះអង្គបានឡើយ។ នៅពេលដែលព្រះអង្គមានបំណងព្រះហឫទ័យ ក្នុងការធ្វើអ្វីមួយ គ្មានអ្វីអាចទប់ស្កាត់ ការដែលព្រះអង្គសម្រេចព្រះហឫទ័យក្នុងការធ្វើបានឡើយ។ គ្មានអំណាចណាមួយនៅក្នុងចក្រវាឡនេះអាច បញ្ឈប់បំណងព្រះហឫទ័យរបស់ព្រះបានឡើយ។

យ៉ូប ៤២:២

“ទូលបង្គំដឹងថាទ្រង់ធ្វើទាំងអស់កើត ហើយថា នឹងឃាត់ព្រះដំរិះទ្រង់ណាមួយមិនបាន”

សុភាសិត ២១:៣០

គ្មានប្រាជ្ញាណា គ្មានយោបល់ណា ឬការប្រឹក្សាណា ដែលអាចទាស់នឹងព្រះយេហូវ៉ាបានឡើយ។

ការសោយរាជ្យលើទាំងអស់របស់ព្រះ បង្រៀនយើងថា មានគោលបំណងទៅលើគ្រប់ទាំងព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងនៅក្នុងជីវិតរបស់យើង។ ព្រះអង្គតែងតែរគ្រប់គ្រងលើគ្រប់ការទាំងអស់ជានិច្ច ហើយទ្រង់កំពុងធ្វើការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អទៅដល់រាស្ត្ររបស់ទ្រង់។

រ៉ូម ៨:២៨

តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់។

គ្មានអ្វីដែលកើតឡើងនៅក្រៅការគ្រប់គ្រងរបស់ព្រះ ឬ គ្មានអ្វីអាចទប់ស្កាត់ផែនការរបស់ទ្រង់មិនឲ្យកើត ឡើងឡើយ។ ជាការពិតជាក់ស្តែង ជាញឹកញាប់មនុស្សជួបជាមួយនឹងស្ថានភាពលំបាកផ្សេងៗ ដោយសារតែ ការទាំងនោះគឺជាជំហានប្រុងប្រៀបយ៉ាងចាំបាច់ត្រូវកើតឡើង ដើម្បីសម្រេចគោលបំណងរបស់ព្រះនៅក្នុង ជីវិតរបស់ពួកគេ។ នៅក្នុងព្រះគម្ពីរមានភស្តុតាងជាច្រើនដែលអះអាងថាការនេះគឺជាសេចក្តីពិត។

ឧទាហរណ៍

- ពួកបងប្រុសរបស់យ៉ូសែប បានលក់គាត់ឲ្យទៅធ្វើជាទាសករ ក្រោយមកគាត់ត្រូវគេចោទប្រកាន់ ហើយត្រូវគេចាប់ទៅដាក់គុក។ យ៉ាងណាមិញ ថ្ងៃមួយត្រូវបានផ្លាស់ប្រែទាំងស្រុងពី អ្នកជាប់គុក បានក្លាយជានាយករដ្ឋមន្ត្រី របស់ប្រទេសអេហ្ស៊ីប! តើការនេះកើតឡើងដោយរបៀបណា? ការនេះ កើតឡើងដោយសារតែ អំណាចសោយរាជ្យរបស់ព្រះលើគ្រប់ការទាំងអស់។

- នាងរស់គឺជាស្ត្រីមេម៉ាយក្រីក្រម្នាក់នៅក្នុងដែនដីស្រុកដទៃ ដែលថ្ងៃមួយគាត់បានទៅធ្វើការនៅ តាម វាលស្រែ។ បូអូសគាត់គឺជាម្ចាស់វាលស្រែទាំងនេះ ហើយគាត់គឺជាអ្នកមានស្តុកស្តម្ភ។ ក្រោយមក មិនយូរប៉ុន្មាន ពួកគេទាំងពីរបានរៀបការជាមួយគ្នា ហើយពូជពង្សខ្សែស្រឡាយស្តេចបានកើតចេញ ពីគាត់។ តើការនេះកើតឡើងដោយរបៀបណា? ការនេះ កើតឡើងដោយសារតែ អំណាចសោយរាជ្យរបស់ព្រះលើគ្រប់ការទាំងអស់។

- ដាវីឌគឺជាកូនពៅ នៅក្នុងគ្រួសារ ដែលមានកូនប្រុស ៧នាក់។ បងៗរបស់បម្រើការនៅក្នុងជួរកងទ័ព ហើយដាវីឌគឺជាគ្រាន់តែក្មេងឃ្វាលចៀម។ ថ្ងៃមួយ នៅពេលដែលគាត់បានយកអាហារនៅឲ្យបងៗ របស់គាត់ បានគាត់ទៅប្រយុទ្ធហើយយកឈ្នះទៅលើ យក្សដ៏ធំមួយ។ គាត់បានក្លាយជាវីរៈបុរស របស់ប្រទេសអ៊ីស្រាអែល។ តើការនេះកើតឡើងដោយរបៀបណា? ការនេះ កើតឡើងដោយសារតែ អំណាចសោយ

រាជ្យរបស់ព្រះលើគ្រប់ការទាំងអស់។

- ព្រះអង្គបានបញ្ជូនយ៉ូណាសទៅកាន់ក្រុងនីនីវេ ប៉ុន្តែគាត់បានសម្រេចចិត្តធ្វើដំណើរឆ្ងាយសែនឆ្ងាយ តាមតែគាត់អាចធ្វើបានពីទីក្រុងនីនីវេ។ ចុងក្រោយ គាត់នៅតែមកដល់ក្រុងនីនីវេនេះ ហើយគាត់ បាននាំមនុស្សទាំងអស់នៅក្នុងក្រុងនេះ បែរមករកព្រះ ហើយប្រែចិត្តលន់តួ សារភាពអំពើបាបចំពោះព្រះ។ តើការនេះកើតឡើងដោយរបៀបណា? ការនេះ កើតឡើងដោយសារតែ អំណាចសោយ រាជ្យរបស់ព្រះលើគ្រប់ ការទាំងអស់។

- អេសធើរគឺជាកូនកំព្រា រស់នៅជាឈ្លើយសឹកនៅក្នុងប្រទេសពើស៊ី។ នាងត្រូវបានគេចាប់យកទៅ ដាក់នៅក្នុងរាជ្យវាំង។ នៅទីនោះ នាងបានទទួលការយោគយល់ និងការគាប់ចិត្តពីស្តេច ហើយក៏បានក្លាយជាព្រះមហេសីរបស់ស្តេច។ ការនេះបានធ្វើឲ្យនាងអាចជួយទៅកាន់ជាតិសាសន៍របស់ នាងឲ្យរួចផុតពីការប្រល័យពូជសាសន៍។ តើការនេះកើតឡើងដោយរបៀបណា? លោកអ្នកបានដឹង ចម្លើយរួចទៅហើយ។

ការអស្ចារ្យដ៏ធំមួយដែល យើងអាចឃើញ គឺជាការដែលព្រះអង្គ ធ្វើការសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់ នៅក្នុងជីវិតរបស់អស់ អ្នកដែលស្រលាញ់ទ្រង់ ដោយអំណាចចេស្តា សោយរាជ្យលើគ្រប់ទាំងអស់ របស់ទ្រង់។

**សូមពិភាក្សាសំនួរទាំងនេះជាមួយដៃគូ:**

- តើលោកអ្នកបានរៀនអ្វីខ្លះអំពីព្រះ តាមរយៈមេរៀននៅថ្ងៃនេះ?

- ប្រសិនបើនរណាម្នាក់មកសួរលោកអ្នកថា “ព្រះអង្គសោយរាជ្យលើគ្រប់ទាំងអស់” មានន័យយ៉ាង ណា? តើលោកអ្នកនឹងឆ្លើយថាម៉េច?

- តើការដែលដឹងថា ព្រះអង្គកំពុងសោយរាជ្យលើគ្រប់ទាំងអស់ ហើយកំពុងធ្វើការដើម្បីសម្រេច បំណងព្រះហឫទ័យដ៏ល្អរបស់ទ្រង់ អាចជួយយ៉ាងណាទៅកាន់អ្នកជឿ ដែលកំពុងតែជួបជាមួយ នឹង ការរងទុក្ខលំបាក?

**ចំនុចគន្លឹះ**

ការសង្ខេប ចំនុចគន្លឹះដែលព្រះគម្ពីរបង្រៀនព្រះអង្គសោយរាជ្យលើគ្រប់ទាំងអស់គឺ :

1) ព្រះអង្គសោយរាជ្យលើគ្រប់អ្វីៗ ដែលទ្រង់បានបង្កើត ដោយអំណាចចេស្ដាដ៏កំពូល។
2) រាជ្យនិងអំណាចគ្រប់គ្រងរបស់ទ្រង់ ស្ថិតស្ថេរនៅជាដរាប
3) ព្រះអង្គធ្វើគ្រប់ការទាំងអស់ស្របតាមបំណងព្រះហឫទ័យរបស់ទ្រង់
4) គ្មានអ្វីការទប់ស្កាត់ព្រះអង្គមិនឲ្យសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់ឡើយ

# មេរៀនទី ៨ : ព្រះអង្គទ្រង់បរិសុទ្ធ

នៅក្នុងព្រះគម្ពីរមានពាក្យមួយ ដែលបានប្រើប្រាស់ក្នុងការពណ៌នាអំពីព្រះ ច្រើនជាងពាក្យណាៗទាំងអស់។ គឺជាពាក្យដែលពួកទេវតានៅជុំវិញបល្ល័ងនៃព្រះតែងនិយាយម្ដងហើយម្ដងទៀត។ ពាក្យនោះគឺ ‘បរិសុទ្ធ’ ។

**តើព្រះគម្ពីរមានន័យយ៉ាងណា ដែលថាព្រះអង្គទ្រង់បរិសុទ្ធ?**

មានគំនិតគន្លឹះចំបងពីរ។ ទីមួយគឺ **ការញែកដាច់ដោយឡែក**។

- ពាក្យបរិសុទ្ធ នៅក្នុងភាសាហេព្រើរ **שׁוֹדק** មានន័យថា ‘ញែកចេញ’ ឬ ‘ដាច់ដោយឡែក’ ។
- នៅក្នុងភាសាក្រិច ពាក្យថា បរិសុទ្ធគឺពាក្យ ἅγιος មានន័យថា ‘ផ្សេងគ្នា’ ។

នៅពេលដែលយើងនិយាយថាព្រះអង្គបរិសុទ្ធ យើងកំពុងមានន័យថា ទ្រង់មានលក្ខណៈដាច់ដោយឡែក ពីអ្វីៗ គ្រប់យ៉ាងទាំងអស់។

**ពិភាក្សា : តើលោកអ្នកគិតថាព្រះអង្គមានលក្ខណៈផ្សេង ដាច់ដោយឡែកយ៉ាងណាខ្លះ ពីអ្វីៗទាំងអស់?**

តើព្រះអង្គមានលក្ខណៈផ្សេង និងដាច់ដោយឡែកយ៉ាងណាខ្លះ? ចម្លើយគឺជាចំនុចគ្រប់យ៉ាង ដែលយើងបានសិក្សានៅក្នុងវគ្គសិក្សានេះ។ ព្រះអង្គគឺជាព្រះអាទិករ ហើយរបស់គ្រប់យ៉ាងគឺសុទ្ធតែជាអ្វី ដែលទ្រង់បានបង្កើត។ ដូច្នេះ ទ្រង់មានលក្ខណៈផ្សេងដាច់ដោយឡែក ពីអ្វីៗទាំងអស់។

លើសពីនេះ គ្រប់ទាំងសមាសភាពរបស់ទ្រង់ បង្ហាញថាទ្រង់ពិតជាពិសេសដាច់ដោយឡែក។ មានតែទ្រង់ទេ ដែលមានជីវិតនៅក្នុងទ្រង់ដោយខ្លួនឯង។ ហើយមានតែទ្រង់ទេ ដែលមានជីវិតអស់កល្បជានិច្ច។ មានតែទ្រង់ទេ ដែលមានភាពសព្វព្រះវត្តមាន។ មានតែទ្រង់ទេ ដែលជ្រាបដឹងគ្រប់ការទាំងអស់។ មានតែទ្រង់ទេដែលមានគ្រប់ទាំងព្រះចេស្តា។ មានតែទ្រង់ទេ ដែលសោយរាជ្យលើគ្រប់ទាំងអស់។ គ្រប់ទាំងសមាសភាពរបស់ទ្រង់ បង្ហាញថាទ្រង់បរិសុទ្ធដាច់ដោយឡែក មិនដូចជាអ្វីៗគ្រប់យ៉ាង ដែលទ្រង់បានបង្កើតឡើយ។ គ្មាននរណាដូចទ្រង់ឡើយ។

និក្ខមនំ ១៥:១១

ឱព្រះយេហូវ៉ាអើយ តើមានព្រះឯណាឲ្យដូចទ្រង់ តើមានអ្នកឯណាដែលមានសេចក្តីបរិសុទ្ធដ៏វិសេសដូចទ្រង់ ដែលគួរសរសើរដំកើង ហើយក៏ធ្វើការអស្ចារ្យផង

១សាំយូអែល ២:២

"គ្មានព្រះណាបរិសុទ្ធ ដូចព្រះយេហូវ៉ាឡើយ ដ្បិត ក្រៅពីទ្រង់គ្មានព្រះឯណាទៀតសោះ ក៏គ្មានព្រះឯណាដែលទុកជាថ្មដា ឲ្យដូចព្រះនៃយើងខ្ញុំដែរ

អេសាយ ៤០:២៥

"ដូច្នេះ ព្រះដ៏បរិសុទ្ធទ្រង់មានព្រះបន្ទូលថា ឯងរាល់គ្នានឹងប្រៀបផ្ទឹមអញដូចជាអ្នកណា ឲ្យអញបានស្មើនឹងគេនោះ"

ការដែលនិយាយ "ព្រះអង្គទ្រង់បរិសុទ្ធ" គឺជាការទទួលស្គាល់ថាទ្រង់មាន វិសេសដាច់ដោយឡែក គ្មានអ្វីអាចប្រៀបស្មើ ហើយគ្មានគូផ្ទឹម។ ពាក្យថា 'បរិសុទ្ធ' ពណ៌នាពីគ្រប់យ៉ាងអំពីទ្រង់ ហើយគ្មាននរណាម្នាក់ ដូចទ្រង់ឡើយ។

មានតែទ្រង់ទេ គឺជាអង្គបុគ្គលដ៏ល្អឥតខ្ចោះ ហើយមានផ្នែកពិសេសដោយឡែកផ្ទាល់ខ្លួន។ គ្មានព្រះឯណាទៀតក្រៅពីទ្រង់ឡើយ។

ចោទិយកថា ៤:៣៩

ដូច្នេះ ចូរដឹងនៅថ្ងៃនេះ ហើយកំណត់ទុកក្នុងចិត្តចុះថា ព្រះយេហូវ៉ា ទ្រង់ជាព្រះនៅលើស្ថានសួគ៌ ហើយនៅផែនដីនេះផង គ្មានព្រះឯណាទៀតសោះឡើយ

អេសាយ ៤៤:៦

“ព្រះយេហូវ៉ាដ៏ជាមហាក្សត្រនៃ សាសន៍អ៊ីស្រាអែល ហើយជាអ្នកដែលប្រោសលោះគេ គឺព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលដូច្នេះថាអញជាដើម ហើយជាចុង ក្រៅពីអញគ្មានព្រះណាទៀតឡើយ

អេសាយ ៤៥:២២

“អស់ទាំងមនុស្សនៅចុងផែនដីអើយ ចូរមើលមកអញ ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតអញនេះជាព្រះ ឥតមានណាទៀតឡើយ

**ពិភាក្សា : តើរបៀបណាខ្លះ ដែលលោកអ្នកចអាច ទទួលស្គាល់ថា ព្រះអង្គគឺជាបរិសុទ្ធ?**

គំនិតគន្លឹះចំបងទីពីរ នៃពាក្យ បរិសុទ្ធ គឺការមាន**សីលធម៌ល្អឥតខ្ចោះ**។ ការដែលមានភាពបរិសុទ្ធ គឺជាការ ដែលសីលធម៌ល្អវិសុទ្ធ ហើយនោះគឺជាការ ដែលគ្មានអំពើបាប និង គ្មានការអាក្រក់សោះឡើយ។

១ យ៉ូហាន ១:៥

នេះជាដំណឹង ដែលយើងខ្ញុំបានឮពីទ្រង់ ហើយក៏ប្រាប់មកអ្នករាល់គ្នា គឺថា ព្រះទ្រង់ជាពន្លឺភ្លឺ គ្មានសេចក្ដីងងឹតណា នៅក្នុងទ្រង់សោះ

នៅក្នុងការសរសេររបស់លោកយ៉ូហាន សេចក្តីងងឹត គឺជាការតំណាងឲ្យការអាក្រក់ ហើយពន្លឺតំណាងឲ្យ សេចក្តីពិត និង ការល្អ។ ដូច្នេះនៅក្នុងខនេះ បានប្រាប់យើងថា ព្រះអង្គល្អឥតខ្ចោះ ទ្រង់ពិតត្រង់ ហើយគ្មាន ការអាក្រក់នៅក្នុងទ្រង់ឡើយ។ គ្រប់មនុស្សទាំងអស់សុទ្ធតែមានការល្អ និង ការអាក្រក់នៅក្នុងជីវិតរបស់ ខ្លួន។ ប៉ុន្តែ ព្រះអង្គមានភាពល្អបរិសុទ្ធ សុទ្ធសាធ។ ទ្រង់ល្អ ១០០% ហើយអាក្រក់ 0% ។ ក្នុងនាមទ្រង់គឺជា ព្រះបរិសុទ្ធគ្មានព្រំដែន ទ្រង់មានភាពដាច់ដោយឡែកពីគ្រប់ទាំងការអាក្រក់ ឬ ភាពមិនបរិសុទ្ធទាំងអស់។

ទំនុកតម្កើង ៥:៤

ដ្បិតទ្រង់មិនមែនជាព្រះដែលសព្វព្រះហឫទ័យនឹងសេចក្តីល្មើសទេ

ឯសេចក្តីអាក្រក់នឹងនៅជាមួយនឹងទ្រង់មិនបាន

ហាបាគុក ១:១៣a

ទ្រង់មានព្រះនេត្របរិសុទ្ធក្រៃលែង និងទតមើលការអាក្រក់មិនបាន ក៏នឹងពិនិត្យមើលការទុច្ចរិតមិនបានដែរ

ព្រះអង្គមិនធ្វើអំពើបាប ទ្រង់មិនយល់ស្របចំពោះអំពើបាប ឬ រីករាយចំពោះការធ្វើបាបឡើយ ហើយទ្រង់មិនអាចមាន ការប្រកបជាមួយនឹងអំពើបាបឡើយ។ ការអាក្រក់គ្មាននៅក្នុងព្រះ វាក៏ដូចគ្មានជាមួយនឹង ការដែលងងឹត មិនអាច មានវត្តមាននៅក្នុងពន្លឺផងដែរ។

**សេចក្តីសង្ខេប:** នៅពេលដែលព្រះគម្ពីរប្រាប់យើងថា "ព្រះអង្គបរិសុទ្ធ" នោះមានន័យថាទ្រង់គឺជាព្រះ ដែលមាន ភាពដាច់ដោយឡែក នៅក្នុងភាពឥតខ្ចោះរបស់ទ្រង់ និង ភាពធំឧត្តមរបស់ទ្រង់ ហើយទ្រង់មានភាពកាត់ ផ្តាច់ចេញពី គ្រប់ទាំងការអាក្រក់ និង អំពើបាបទាំងអស់។

## <u>ការសិក្សាព្រះគម្ពីរ : និមិត្តរបស់លោកអេសាយ</u>

លោកអេសាយបានមើលឃើញភាពបរិសុទ្ធរបស់ព្រះ នៅពេលដែលគាត់បានឃើញនិមិត្តអំពីព្រះគង់នៅបល្ល័ងនៃស្ថានសួគ៍ ។ ចូរឲ្យយើងធ្វើការសិក្សាស៊ីជម្រៅជាមួយគ្នា។

- **សូមអាន អេសាយ ៦:១-៥**

១. លោកអេសាយឃើញព្រះអង្គគង់នៅបល្ល័ងរបស់ទ្រង់។ នៅពីលើបល្ល័ងទ្រង់មានពួកសេរភីម ដែលគឺជាពួកទេវតានៃភ្លើង។ តើពួកគាត់បន្លឺសំលេងនិយាយយ៉ាងដូចម្តេច?

______________________________________________________________________________

______

២. តើលោកអ្នកគិតថាអ្វី ដែលមូលហេតុ ដែលពួកគេនិយាយពាក្យ "បរិសុទ្ធ" បីដង?

______________________________________________________________________________

______

ការដែលសំខាន់បំផុតដែលត្រូវនិយាយអំពីទ្រង់ នោះគឺទ្រង់គឺជាព្រះបរិសុទ្ធ។ គ្រប់យ៉ាងអំពីទ្រង់ គឺបរិសុទ្ធ។ ព្រះរាជបុត្រារបស់ទ្រង់គឺ "ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល" ព្រះវិញ្ញាណដែលទ្រង់បានបញ្ជូនមកកាន់ យើងទាំងអស់ គ្នាគឺជា "ព្រះវិញ្ញាណបរិសុទ្ធ" ព្រះគម្ពីរគឺជា "ព្រះបន្ទូលដ៏បរិសុទ្ធរបស់ព្រះ" ហើយព្រះវិហារ ទ្រង់គឺជា "ព្រះវិហារបរិសុទ្ធ" ដែនដីនៃរាស្ត្ររបស់ទ្រង់ គឺជា "ដែនដីបរិសុទ្ធ" ហើយព្រះនាមរបស់ទ្រង់គឺជា "ព្រះនាមបរិសុទ្ធ" ។ ពួកទេវតានៅក្នុង ព្រះវត្តមានទ្រង់ថ្វាយបង្គំទ្រង់ ដោយព្រោះសារតែភាពបរិសុទ្ធរបស់ទ្រង់។ អស់អ្នកដែលមានភាពជិតស្និទ្ធិយ៉ាងខ្លាំង ជាមួយព្រះ ដឹងថាសេចក្តីពិតដ៏សំខាន់បំផុតអំពីព្រះ គឺថា ទ្រង់គឺជាព្រះបរិសុទ្ធ។

នៅក្នុងនិមិត្តនេះ មានការសំគាល់ជាច្រើនបង្ហាញមកកាន់យើងថា ទ្រង់ធំឧត្តម ហើយបរិសុទ្ធប៉ុណ្ណា ៈ

- ទីកំពស់នៃបល្ល័ង្ករបស់ស្តេច គឺជាសញ្ញាបង្ហាញពីអំណាចរបស់ទ្រង់។ ចូរកត់សំគាល់ថាបល្ល័ង្ករបស់ ទ្រង់ "នៅទីខ្ពស់ ហើយបានតំកើងឡើង" ។

- ស្តេចបំពាក់អង្គទ្រង់ដោយព្រះពស្ត្រក្សត្រ ហើយរំភាយព្រះពស្ត្រ គឺជាសញ្ញាសំគាល់មួយ នៃអំណាច របស់ទ្រង់។ ស្តេចដែលមានអំណាចកាន់តែខ្លាំង នោះរំភាយព្រះពស្ត្ររបស់ទ្រង់កាន់តែធំធេងដែរ។ ចូរកត់សំគាល់ថា រំភាយព្រះពស្ត្ររបស់ទ្រង់ធំធេងក្រៃលែង ដែលនៅពាសពេញព្រះវិហារ!

- សេរភីមមានស្លាបប្រាំមួយ ពួកគេបាំងមុខដោយស្លាប២ បាំងជើងដោយស្លាប២ ហើយប្រើ២សំរាប់ ហើរ នៅក្នុងព្រះវត្តមានរបស់ព្រះ។ ពួកគេបាំងជើងរបស់ពួកគេ ដោយសារតែពួកគេឈរនៅលើ ទីកន្លែងបរិសុទ្ធ (និក្ខមនំ ៣:៥)។ ពួកគេបាំងមុខដោយសារតែព្រះភ័ក្ត្រ និងសិរីល្អទ្រង់មានពន្លឺចញ្ចាំងចញ្ចែងពេក ដែលគ្មានអ្វីអាចសំលឹងចំទៅកាន់ព្រះភ័ក្ត្ររបស់ទ្រង់បានឡើយ (និក្ខមនំ ៣៣:២០)
- នៅពេលដែលពួកគេសេរភីមប្រកាសពីភាពបរិសុទ្ធរបស់ព្រះ ពេលនោះគ្រឹះនៃព្រះវិហារក៏រញ្ជួយ ហើយក៏មាន ផ្សែងនៅពាសពេញព្រះវិហារ។ ការរញ្ជួយ និង ផ្សែងបង្ហាញពីសិរីល្អ និង អំណាចចេស្តារបស់ព្រះ (និក្ខមនំ ១៩:១៦-២០; វិវរណៈ ១៥:៨)

**ការឆ្លើយតបរបស់លោកអេសាយ**

៣. តើលោកអេសាយពោលពាក្យយ៉ាងណា នៅពេលដែលគាត់ដឹងពីភាពបរិសុទ្ធ ដ៏ខ្ពង់ខ្ពស់ជាទីបំផុតរបស់ព្រះ?

__________________________________________________________________

_____

៤. ពួកហោរាតែងប្រើពាក្យ "វរហើយ" ដើម្បីនាំការកាត់ទោសរបស់ព្រះទៅកាន់ពួកមនុស្សប៉ះបោរ។ ប៉ុន្តែនៅត្រង់នេះ លោកអេសាយបានប្រកាស "វរហើយ" មកកាន់ខ្លួនឯង! តើលោកអ្នកគិតថា ហេតុអ្វីបានជាគាត់ធ្វើការនេះ?

__________________________________________________________________

_____________________________________________________________________________

__________

ការទទួលស្គាល់ភាពបរិសុទ្ធ និងសិរីល្អរបស់ព្រះ នាំឱ្យយើងមានការទទួលស្គាល់ថា យើងមានបាប។ ការ ធ្វើអំពើបាប គឺជាការខ្វះមិនដល់សិរីល្អរបស់ព្រះ (រ៉ូម ៣:២៣)។ មូលហេតុដែលមនុស្សភាគច្រើនមិនសូវទទួលស្គាល់ អំពើបាបរបស់ខ្លួន គឺដោយសារពួកគេមិនបានដឹងអំពី សិរីល្អរបស់ព្រះ។

ទំនុកដំកើង ៣៦:១-២

ការរំលងច្បាប់របស់មនុស្សអាក្រក់

នោះសំដែងក្នុងចិត្តខ្ញុំថា

នៅភ្នែកគេគ្មានសេចក្ដីកោតខ្លាចដល់ព្រះទេ

ដ្បិតនៅភ្នែកគេក៏មើលខ្លួនជាគួរបញ្ជើចបញ្ជើវិញ

ដោយថា សេចក្ដីទុច្ចរិតរបស់ខ្លួន មិនដែលមាន

អ្នកណាឃើញ ឬស្អប់ឡើ

អេសាយអាចប្រៀបធៀបខ្លួនគាត់ទៅនឹងអ្នកដទៃ ហើយមានអារម្មណ៍មោទកភាព ដែលគាត់សុច្ចរិត ជាង មនុស្សជាច្រើន។ ប៉ុន្តែ បើប្រៀបជាមួយភាពល្អឥតខ្ចោះរបស់ព្រះវិញ អេសាយដឹងខ្លួនថា គាត់មិនសុចរិតសោះឡើយ។ មើលឃើញភាពបរិសុទ្ធរបស់ព្រះមួយគ្រាឡេក អេសាយភ្ញាក់ដឹងខ្លួនថា ខ្លួនគាត់មិនស្អាតស្អំនោះទេ។ ចូរមើលអ្វី ដែលកើតឡើងបន្ទាប់ពីនេះ។ អាន [អេសាយ ៦:៦-៨]

**ការបញ្ជូនអេសាយ**

៥. តើសេរភីមបានធ្វើអ្វី ពេលអេសាយទទួលស្គាល់ អំពើបាបរបស់ខ្លួន? តើពួកគេប្រាប់អ្វីទៅគាត់?

____________________________________________________________________________

____________________________________________________________________________

____________

យើងឃើញថា មានតែព្រះមួយអង្គប៉ុណ្ណោះដែលអាចបន្សុទ្ធមនុស្សបាន។ ព្រះអង្គមិនបានប្រាប់អេសាយឱ្យខិតខំប្រឹងប្រែងជាងនេះ។ ព្រះអង្គមិនបានប្រាប់អេសាយឱ្យចេញទៅឆ្ងាយ ហើយត្រឡប់មកវិញ ពេលជីវិតរបស់គាត់ សុចរិតជាងនេះ។ ព្រះអង្គមិនបានមានបន្ទូលថា៖ "អញទទួលឯង ជាឯង អេសាយ" នោះទេ។ អត់ទេ ព្រះអង្គបានសម្តែងចេញជារបៀបមួយដែលអំពើបាបរបស់អេសាយត្រូវ បានអត់ទោស ហើយសេចក្តីទុចរិតរបស់គាត់ត្រូវដកចេញ។ ព្រះអង្គបន្សុទ្ធរាស្ត្ររបស់ទ្រង់ពេលពួកគេ សារភាពអំពើបាបរបស់ពួកគេ នៅចំពោះព្រះអង្គ។

តើរងើកភ្លើងរលាកអេសាយដែរទេ? ប្រហែលជារលាកមួយភ្លែត តែចូរយើងកត់សម្គាល់អំពី ពាក្យពេចន៍ដំបូងរបស់គាត់ដោយបបូរមាត់ដែលបានសម្អាតហើយ។

៦. នៅពេលព្រះជាម្ចាស់ត្រាស់ហៅគាត់ តើអេសាយឆ្លើយតបដូចម្តេច?

____________________________________________________________________________

______

អេសាយទទួលបានការបន្សុទ្ធ ហើយគាត់ត្រៀមខ្លួនរួចរាល់ ដោយចិត្តអន្ទះសារក្នុងការស្ម័គ្រចិត្ត បម្រើព្រះ។

សរុបសេចក្តីអំពី មេរៀនយើង សូមពិចារណាជាមួយគ្នាអំពី ជំហ៊ានរបស់អេសាយដែលបោះទៅរកព្រះ។

**ជំហ៊ានរបស់អេសាយបោះទៅកាន់ព្រះ**

ជំហ៊ានទី១៖ គាត់ទទួលការបើកសម្តែងអំពី ភាពបរិសុទ្ធរបស់ព្រះ

ជំហ៊ានទី២៖ ទទួលស្គាល់ថា ភាពបរិសុទ្ធរបស់ព្រះនាំមកនូវការទទួលស្គាល់បាប

ជំហ៊ានទី៣៖ ការទទួលស្គាល់បាប នាំទៅរកការលន់តួ

ជំហ៊ានទី៤៖ ព្រះអង្គសម្អាតគាត់ និងដកអំពើបាប និងសេចក្ដីទុចរិតពីគាត់

ជំហ៊ានទី៥៖ ព្រះអង្គត្រាស់ហៅគាត់ គាត់ឆ្លើយតប

ជំហ៊ានទី៦៖ ព្រះអង្គបញ្ជូនគាត់

ក្រាបសង្ខេបអំពី ជំហ៊ានទាំង ៦

| | | | | | |
|---|---|---|---|---|---|
| ការបើកសម្ដែង → | ការទទួលស្គាល់ → | ការលន់តួ /ការប្រែចិត្ត → | ការអត់ទោស → | ការត្រាស់ហៅ (ដើម្បីបម្រើ) → | ការបញ្ជូនចេញ |

**ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន**

សូមចំនាយពេលមួយភ្លែត ដើម្បីគិតអំពីសំនួរទាំងនេះ។

- តើអ្នកធ្លាប់មានបទពិសោធន៍អំពី ជំហ៊ានមួយណានៅក្នុងជីវិតអ្នកផ្ទាល់?
- តើអ្វីជាជំហ៊ានបន្ទាប់របស់អ្នក ក្នុងការដើរដោយជំនឿ?

**សូមពិភាក្សាសំនួរទាំងនេះជាមួយដៃគូ:**

- តើលោកអ្នកបានរៀនអ្វីខ្លះអំពីព្រះ តាមរយៈមេរៀននៅថ្ងៃនេះ?
- តើសេចក្តីពិតនេះ ធ្វើឲ្យមានលទ្ធផលទាក់ទងយ៉ាងណាមកកាន់ជីវិតលោកអ្នក?

**ចំនុចគន្លឹះ**

ការសង្ខេប ចំនុចគន្លឹះដែលព្រះគម្ពីរបង្រៀនអំពី ភាពបរិសុទ្ធរបស់ព្រះគឺ៖

(១) ព្រះជាម្ចាស់ មានភាពដាច់ដោយឡែក នៅក្នុងភាពឥតខ្ចោះរបស់ទ្រង់ និង ភាពធំឧត្តមរបស់ទ្រង់។

(២) ព្រះជាម្ចាស់ល្អឥតខ្ចោះនៅក្នុងសីលធម៌ ទ្រង់គ្មានអំពើបាប និងផ្តាច់ចេញពីគ្រប់ទាំងការអាក្រក់។

(៣) ភាពបរិសុទ្ធរបស់ព្រះ មានន័យថា ព្រះអង្គសាកសមនឹងការសរសើរតម្កើង ការបម្រើ និងថ្វាយបង្គំ។